អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលពីរ**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី៤៧០**

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 11-Jan-2017, 11:32

CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ស្តាវរូឡា ប៉ាប៉ាដូពូឡូស

*(Ms. Stavroula PAPADOPOULOS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក លីវ សុវណ្ណា | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ឡោ ជុនធី | ខ្មែរ |
| លោកស្រី ស៊ីន សុវ៉ន | ខ្មែរ |
| លោកស្រី ង៉ែត ចាត (2-TCCP-1067) | ខ្មែរ |
| លោកស្រី សយ ណារឿន (2-TCCP-1068) | ខ្មែរ |
| លោក ជួន ធី (2-TCW-859) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី ខែត ចាត** (2-TCCP-1067)


សួរបន្តដោយលោក ឡោ ជុនធី ផ្តើមពី.................................... ទំព័រ ៣

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី.................................... ទំព័រ ៧

សួរដោយលោក លីវ សុវណ្ណា ផ្តើមពី.................................... ទំព័រ ១៥

សួរដោយលោក គង់ សំអុន ផ្តើមពី.................................... ទំព័រ ២០

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី.................................... ទំព័រ ២២


**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី សយ ណារឿន** (2-TCCP-1068)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី.................................... ទំព័រ ២៤

សួរដោយលោកស្រី ស៊ីន សុវ៉ន ផ្តើមពី.................................... ទំព័រ ២៦

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី.................................... ទំព័រ ៣៥

សួរដោយលោក លីវ សុវណ្ណា ផ្តើមពី.................................... ទំព័រ ៣៩


**ការសួរសំណួរទៅសាក្សី៖ លោក ជួន ធី** (2-TCW-859)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី.................................... ទំព័រ ៥០

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី.................................... ទំព័រ ៥៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្ដាប់សេចក្ដីថ្លែងទុក្ខសោកវេទនា និងព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីររូបពាក់ព័ន្ធនឹងអង្គហេតុការចេញបទបញ្ជាអាពាហ៍ពិពាហ៍ ហើយនិងផ្ដើមធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី 2-TCW-859 ពាក់ព័ន្ធនឹងអង្គហេតុចរិតលក្ខណៈនៃជម្លោះប្រដាប់អាវុធ។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវមកថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោកស្រី ង៉ែត ចាត។ លោកស្រីនិងបុគ្គលិកអង្គការ ធី.ភី.អូ លោក ប៊ុន លឹមហួរ មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីបន្ទាប់ មានរហស្សនាម 2-TCCP-1068។ ដើមបណ្ដឹងរូបនេះ មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

ហើយសាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបន្ទាប់ ពីបញ្ចប់ការស្ដាប់សេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់ដើមបណ្ដឹងរដ្ឋប្បវេណី មានរហស្សនាម 2-TCW-859។ សាក្សីរូបនេះបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីរូបនេះនឹងធ្វើសម្បថនៅពេលព្រឹកនេះ មុននឹង

ចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

[០៩:០៥:២០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះមិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅ អ.វ.ត.ក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈឈឺចុករោយចង្កេះ ពិសេសនៅពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកតាមមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៦:៣៩]

ហើយបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយតទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិ ដើម្បីតាំង មានឱកាសសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីនេះបន្តទៀត ហើយនៅមានពេល១៥ប៉ុណ្ណោះ។

**លោក ឡៅ ជុនធី៖**

បាទ អរគុណលោកប្រធាន។ ហើយសូមគោរពអង្គជំនុំជម្រះទាំងមូល។ នៅពេលនេះ ខ្ញុំបាទ ឡៅ ជុនធី ដែលនឹងធ្វើសំណួរបន្តពីម្សិលមិញ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរបន្តដោយលោក ឡៅ ជុនធី៖**

**ស៖** បាទ ជម្រាបសួរអ្នកស្រី ង៉ែត ចាត។ កាលពីម្សិលមិញ គឺខ្ញុំបានសួរសំណួរហ្នឹងទៅដល់ពេលដែលអ្នកស្រីបានរៀបការ។ ពេលដែលរៀបការហើយ បានគេឲ្យទៅស្នាក់នៅខ្ទមមួយ។ ថាតើអ្វីដែលអ្នកស្រីបានទៅស្នាក់នៅ នៅក្រោមខ្ទមហ្នឹង អស់រយៈពេលប៉ុន្មានដែរ?

**លោកស្រី ង៉ែត ចាត៖**

**ឆ៖** ខ្ញុំអត់ដឹងបានប្រហែលជាប៉ុន្មានថ្ងៃ។ ខ្ញុំអត់សួរ ខ្ញុំអត់បានចំណាំដែរ ប៉ុន្តែដេកហ្នឹង បានសម្រាកហ្នឹងបានប្រហែលពីរបីថ្ងៃចុះ ក៏គាត់ហ្នឹង ក៏គេប្រពន្ធគាត់ក៏គេយកវ៉ៃសម្លាប់ចោល ហើយគ្រួសារខ្ញុំក៏សម្លាប់ចោលដូចគ្នា។ អ៊ីចឹងក៏ចេះតែដេកស្លូកស្លឹងអ៊ីចឹង អត់ហ៊ាននិយាយអី គិតអីទេ ខ្លាចៗគេ ព្រោះអីឃើញឈ្លបដើរតាមផ្លូវកៀនៗជញ្ជាំងផ្ទះដែលខ្ញុំដេកហ្នឹង ហើយខ្លាចគេឮ ខ្លាចគេស្តាប់ដឹងអ៊ីចឹង ខ្លាចថាខ្ញុំហ្នឹងមិនគោរពបដិវត្តន៍អ៊ីចឹងទៅ។ ខ្ញុំខ្លាចគេយកទៅ បញ្ជូនខ្ញុំទៅលើ ខ្ញុំមិនដឹងទៅណា ខ្ញុំចេះតែខ្លាចអ៊ីចឹង ចេះអ៊ីចឹង ដេកស្ងៀមអ៊ីចឹងពីរនាក់គាត់អ៊ីចឹងទៅ។

[០៩:០៨:៥១]

**ស៖** បាទ អរគុណ។ ខ្ញុំសូមត្រឡប់ទៅផ្នែកខាងក្រោយបន្តិច ដោយសារម្សិលមិញខ្ញុំលើកឡើងហើយ ហើយសំណួរសួរថា តើនៅពេលដែលក្នុងពិធីការហ្នឹង មានចំនួនប៉ុន្មានគូ? ហើយមានអ្នកដែលចូលរួមនៅក្នុងពិធីការហ្នឹង នរណាខ្លះ? ជាមេកង ឬមួយជាមេក្រុម? ប្រសិនបើអ្នកស្រីចាំឈ្មោះ អាចជម្រាបឈ្មោះទៅអង្គជំនុំជម្រះផងដែរ។

**ឆ៖** ខ្ញុំដឹងតែពេលថ្ងៃខ្ញុំទៅ យកខ្ញុំទៅរៀបការហ្នឹង ដូចថាពេលថ្ងៃល្ងាចអ៊ីចឹង គេថា មិត្តចាតថ្ងៃល្ងាចនេះមិនបាច់ទៅធ្វើការទេ ចាំទៅខាងក្រោមនោះ ចាំទៅសមរភូមិក្រោយនោះជាមួយខ្ញុំ។ ដល់ពេលនេះក៏ ពូស៊ុន ហ្នឹងក៏គាត់នាំខ្ញុំដើរអ៊ីចឹងទៅ មកដល់កន្លែងបឹងខ្នារហ្នឹង ក៏ឃើញតែមីងៗពូៗអ៊ីចឹងគ្នាមួយសន្ធឹក ប្រហែលជា១០គូ ខ្ញុំអត់បានរាប់ទេ ព្រោះខ្ញុំទៅប្រហែលជាយប់ដែរហើយ។

**ស៖** បាទ អរគុណ។ តើរៀបការហ្នឹងនៅពេលថ្មើរម៉ានដែរ?

01376765



**ឆ៖** រៀបការហ្នឹងពេលយប់ហើយ លោកគ្រូ។

**ស៖** តើនៅក្នុងពិធីហ្នឹងមាននរណាខ្លះដែលចូលរួម?

**ឆ៖** ដើរមកហ្នឹង គេដើរមកមុនអ៊ីចឹងមក ខ្ញុំក៏អត់មានបានសួរនាំគេថា នរណាខ្លះ នរណាខ្លះ ខ្ញុំអត់ស្គាល់ ខ្ញុំស្គាល់តែពូម៉ី អ៉! ពូស៊ុន ហ្នឹងយកខ្ញុំមកអ៊ីចឹង ហើយបើគូណាៗ ខ្ញុំអត់បានស្គាល់គេផង ប៉ុន្តែខ្ញុំដឹងថា គេប្រជុំប្រាប់ថា ១០គូរៀបថ្ងៃហ្នឹង។

[០៩:១១:០៨]

**ស៖** អរគុណ។ តើ ពូស៊ុន ហ្នឹងជាអ្នកណា?

**ឆ៖** អាហ្នឹងដឹងគេអ្នកណា គេអ្នកគេ ដូចថា គេអ្នកដឹកនាំ គេប្រជុំ អ្វីខ្ញុំ ដូចគណៈសមរភូមិអ៊ីចឹង គេប្រជុំដូចថា ធំជាគេត្រូវទៅណាមកណាអ៊ីចឹង គេហៅទៅអ៊ីចឹងទៅ។ ឃើញតែពូ ស៊ុន ហ្នឹងគេអ្នកចុះឡើង ចុះឡើង ញឹកញាប់ជាងគេអ៊ីចឹង។

**ស៖** បាទ អរគុណ។ ថាតើនៅពេលនុ៎ង មាននរណាដែលគេឡើងថ្លែងអំពីពិធីរៀបការហ្នឹង ត្រូវឡើងប្តេជ្ញា? ហើយមានការប្តេជ្ញាចិត្តទេ នៅពេលនោះ?

**ឆ៖** មានអង្គការហ្នឹង មិនដឹងអង្គការ ដឹងឈ្មោះអី ខ្ញុំអត់បានស្គាល់ឈ្មោះ ប៉ុន្តែគាត់ប្រជុំ គាត់និយាយប្រកាសថា "បងៗយើង មីងៗយើងប្តេជ្ញាចិត្ត ថារៀបជាគ្រួសារនេះ អត់មានធាក់ជ្រែងទៅណាទេ ត្រូវតែអង្គការកំណត់គូណា មិត្តឯងត្រូវទទួលគូហ្នឹង"។ បើថាមិនយកទេ តថ្ងៃហ្នឹងក៏ខ្ញុំអត់ដឹងដែរ ប៉ុន្តែ បើថាអង្គការកំណត់ឲ្យយកគូណា ត្រូវតែយកគូហ្នឹងតែម្តង។ ឮគេនិយាយថាអ៊ីចឹង។

**ស៖** តើនៅពេលនោះ មានសង្កេតឃើញថា មានបងប្អូនញាតិសន្តានអីចូលរួមទេ?

**ឆ៖** អត់មានបងខ្ញុំទៅ អត់មាន -- បងខ្ញុំនៅខាងទទឹងនុ៎ងដែរ ប៉ុន្តែអត់ទៅផង ទៅតែខ្ញុំម្នាក់ឯងអត់មានដឹងថា ទៅរៀបគ្រួសារផង។ សមរភូមិរៀងខ្លួនៗ អត់មានបងណាស្គាល់ ម៉ែណាស្គាល់ថា កូនរៀបគ្រួសារអីអត់ទេ អត់ដឹងផង។ ខ្ញុំក៏អត់មានបានថា ម៉ែអើយ! ខ្ញុំរៀបគ្រួសារថ្ងៃនេះ អត់។ អត់មានបានទៅនិយាយជាមួយគាត់ ម៉ែឪខ្ញុំប្រាប់អីអត់ទេ អត់ដឹងទេ។ យកនេះ យកដោយចិត្តឯង អង្គការកំណត់ឲ្យយកអ៊ីចឹង ចេះតែយកអ៊ីចឹងទៅ។

[០៩:១៣:១៩]

**ស៖** តើមានពិធីផ្សេងៗតាមប្រពៃណីរបស់ខ្មែរយើងដែរអត់ទេ?

**ឆ៖** ខ្ញុំចូលទៅមើលទៅអត់ សម្លឹងទៅមើលមុខទៅអត់ឃើញមានអីផង។ ឃើញមានតែកៅអី

គេរៀបមួយគូ មួយគូអ៊ីចឹង មួយហែអ៊ីចឹងមក អ៊ីចឹងទៅ។ ដូចថាយកគូណា អង្គុយគូទន្ទឹមៗគ្នាអ៊ីចឹងទៅ។ ខ្ញុំមើលទៅមុខ អត់ឃើញមានអីផង។

**ស៖** បាទ អរគុណ។ ថាតើអ្នកស្រីបានចាំទេ តើពេលដែលរៀបការហ្នឹង ឆ្នាំណា ឬមួយអាចប្រៀបធៀបទៅរដូវអីបានទេ?

**ឆ៖** ខ្ញុំអត់ដឹងឆ្នាំណាទេ។ ខ្ញុំដឹងតែឆ្នាំ៧៨ ខែ៨ គេប្រកាសប្រាប់ថាអ៊ីចឹង។ គេដូចថា អង្គការអ្នកប្រជុំហ្នឹង និយាយប្រាប់ថា ឆ្នាំនេះឆ្នាំ៧៨ ខែ៨។ គេប្រាប់អ៊ីចឹង ចេះតែចាំទុកអ៊ីចឹងទៅ។ ហើយរឿងខ្ញុំនេះ អ្នក១៧នេះ មិនដឹងឆ្នាំ ដឹងខែថ្ងៃណាអីថ្ងៃណា ប៉ុន្តែពួកគាត់អ្នកប្រជុំប្រាប់កំណត់យើងជារៀបគ្រួសារហ្នឹង ប្រាប់ថាយើង ថាអ៊ីចឹង។

**ស៖** បាទ អរគុណ។ ដោយសារការរៀបអាពាហ៍ពិពាហ៍នេះ បន្ទាប់ពីគេបានបញ្ជូនប្ដីអ្នកស្រីទៅកាច់ពោត មិនទាន់នឹងបានប៉ុន្មានថ្ងៃផងក៏ត្រូវបានចាប់ឲ្យអ្នកស្រីហ្នឹងទៅរៀបអាពាហ៍ពិពាហ៍។ តើនៅក្នុងអារម្មណ៍របស់អ្នកស្រីមានស្ថានភាពយ៉ាងដូចម្ដេចដែរ?

[០៩:១៥:២៤]

**ឆ៖** អារម្មណ៍បេះដូងខ្ញុំចង់គាំងបន្តិច ញ័របន្តិច។ មើលទៅឃើញគេ ខ្ញុំយំអត់ហ៊ានឲ្យគេឃើញទេ ខ្ញុំបិទភ្នែកយំធ្វើហៀរទឹកភ្នែក ខ្ញុំអត់ហ៊ានយំ ខ្ញុំចេះតែក្លាហាន គេនិយាយប្រាប់ថា ប្ដេជ្ញាចិត្តចេះតែស្រែកនឹងគេ នឹងឯងអ៊ីចឹង។ ប៉ុន្តែអារម្មណ៍នោះ វាញ័រអស់ ចង់សន្លប់បន្តិចអីបន្តិច ព្រោះអីថា ខ្ញុំយំនឹកប្ដីខ្ញុំ ស្រណោះកន្លែងប្ដីខ្ញុំថា ចុះឯងអើយ មកពីរំលេច ចេះឯងម៉េចចេះមក ដល់ពេលគេឲ្យទៅកាច់ពោតសោះ ឯងម៉េចក៏អត់ទៅ ទាញដៃខ្ញុំ ទាញដៃខ្ញុំអត់ទៅ ក៏អួសកូនខ្ញុំ អួសកូនខ្ញុំទៅៗទៀត។ កូនខ្ញុំក៏វាយំ វាអត់ព្រមទៅ វាតាមម៉ែ។ ដល់ហើយក៏ឃើញគេប្រទាញប្រទង់អ៊ីចឹង ក៏មេកងហ្នឹងក៏គេហៅប្ដីខ្ញុំដើរមុខគេ។

**ស៖** បាទ អរគុណ។ ថាតើនៅពេលហ្នឹង វាមានទំនាក់ទំនងអីជាមួយនឹងអ្នកស្រី បានជាអ្នកស្រីមិនព្រមទៅ?

**ឆ៖** គេថ្ងៃត្រង់ប្រហែលថ្មើរហ្នឹងអ៊ីចឹង ខ្ញុំមកពីសមរភូមិប្រាប់កូនមក មកទាំងអស់គ្នា។ ដល់ពេលនេះ កូនខ្ញុំនៅសាលារៀន ប្ដីខ្ញុំទៅយកកូនក្រមកពេក ដល់ពេលហ្នឹង ខ្ញុំក៏នៅឈរម្នាក់ឯងហ្នឹង គេចេញទៅអស់។ គេសួរថា ចុះមិត្ត ចាត ម៉េចអត់ទៅនឹងគេ? ខ្ញុំថា ខ្ញុំចាំយកកូនមកពីសាលារៀនសិន។ ដល់គេឮខ្ញុំនិយាយអ៊ីចឹង ក៏គេហៅខ្ញុំទៅសួរហ្នឹង ហើយចម្ងាយប្រហែលជា១០ម៉ែត្រចុះ ថាចុះមិត្តឯង

មកហ្នឹងមកធ្វើអីចុះ? ខ្ញុំមកតាមគ្រួសារ។ ចុះម៉ែមិត្តឯងនៅណា? ម៉ែខ្ញុំនៅរំលេច។ ចុះបើគ្រួសារមិត្តឯងមកពីយកកូនវិញ មិត្តឯងកុំទៅ ទោះបីហៅមិត្តឯងម៉េច ក៏មិត្តឯងកុំទៅឲ្យសោះ ចាំលើកក្រោយ ចាំទៅ។ ខ្ញុំបានឮគេនិយាយអ៊ីចឹង ខ្ញុំអរ ព្រោះអីខ្ញុំទៅប៉ុន្មានថ្ងៃ ប៉ុន្មានខែនេះ ខ្ញុំសុំគេមកលេងម្ដាយខ្ញុំ ម៉ែខ្ញុំព្រោះអីគាត់ចាស់ៗហើយ សុំគេមកលេងម្ដងគេអត់ឲ្យមកសោះ តាំងពីខ្ញុំគេបបួលទៅខ្ទារទទឹងហ្នឹង។

[០៩:១៧:៣៨]

**សៈ** បាទ អរគុណ។ ចំណុចមួយទៀតថា មានថ្ងៃមួយនោះគឺមានឈ្លបបាននាំអ្នកស្រីទៅកន្លែងការដ្ឋានមួយ។ តើនៅពេលនោះមានព្រឹត្តិការណ៍អីកើតឡើងទេ ចំពោះអ្នកស្រី ឬមួយមិត្តភក្តិអ្នកស្រីហ្នឹង?

**ឆៈ** ដល់ពេលគេយកគ្រួសារខ្ញុំទៅអ៊ីចឹង ចេញទៅមុខអ៊ីចឹង ខ្ញុំក៏ចេញមកដើរ គេនាំខ្ញុំដើរមកអ៊ីចេះ។ គាត់ថា មិត្តឯងនេះចូលតាមប្រឡោះនេះទៅ។ ដល់ចូលតាមប្រឡោះនេះទៅមានកន្លែងយាយៗគាត់ចិញ្ចឹមជ្រូក ការដ្ឋានយាយៗចិញ្ចឹមជ្រូក ក៏ខ្ញុំចូលទៅដេកហ្នឹង។ ទៅដេកពីរនាក់កូនខ្ញុំពីរនាក់។ ដល់ពេលដេកទៅលក់ប្រហែល មិនទាន់លក់ប៉ុន្មាន ខ្ញុំអត់ទាន់បានលក់ផង ស្រាប់តែពេលប្រហែលព្រលប់បន្តិច ស្រាប់គេដើរមកព្រឹបៗ សុទ្ធតែឈ្លប ខ្ញុំក្រឡេកមើលឃើញសុទ្ធតែយោធា ឈ្លប បួនប្រាំនាក់ លីកាំបិត អាខ្លះលីដាវ--

**សៈ** ឲ្យខ្ញុំសុំទោស សំណួរខ្ញុំចង់សួរថា នៅពេលដែលគេយកប្ដីទៅហើយហ្នឹង ហើយនៅពេលមួយហ្នឹងគេមានឈ្លបមកនាំអ្នកស្រីទៅ តើពេលដែល អ្វីដែលទៅហ្នឹង ថាទៅណាដែរ?

**ឆៈ** នាំខ្ញុំទៅហ្នឹង គេប្រាប់ថា នេះមិត្តចាត មិត្តឯងចាំទៅកន្លែងការដ្ឋានយាយៗចិញ្ចឹមជ្រូកទៅព្រោះអីផ្លូវទៅនេះ ឃើញគេទៅតាមផ្លូវហ្នឹង គេដឹងគេយកទៅ ប្ដីខ្ញុំទៅតាមផ្លូវហ្នឹងគ្នាប្រហែលបួនដប់ម្ភៃនាក់ហើយ ច្រើនណាស់ ខ្ញុំឃើញដើរទៅឡើងមួយហែអ៊ីចឹង។ ខ្ញុំក៏ ខ្ញុំមើលប្ដីខ្ញុំអត់ឃើញ ព្រោះអី ខ្ញុំក៏អត់ហ៊ានមើល ខ្ញុំនឹកប្ដីខ្ញុំពេក។

[០៩:១៩:៣៨]

**សៈ** សំណួរចុងក្រោយរបស់ខ្ញុំថា តើក្រោយពីអ្វីដែលព្រឹត្តិការណ៍កើតឡើងនៅក្នុង ដែលអ្នកស្រីបានឆ្លងកាត់ ដូចជាការឲ្យអ្នកស្រីបែកពីប្ដី ហើយនិងការចាប់ឲ្យរៀបអាពាហ៍ពិពាហ៍ដែលមិនដឹងខ្លួនមុននេះ តើអ្នកស្រីមានការឈឺចាប់អ្វីខ្លះមកដល់បច្ចុប្បន្ននេះ?

**ឆៈ** ខ្ញុំឈឺចាប់ខ្លាំង យ៉ក៏ ខ្ញុំនិយាយប្រាប់កូនខ្ញុំថា កូនអើយ ខ្ញុំម៉ែវេទនាណាស់ កុំតែបានកូនឯង

ទៅនៅសាលារៀនយូរហ្នឹង កុំអីហ្នឹងម៉ែស្លាប់បាត់ហើយ កូនអើយ ដែលចេះតែឈឺចាប់ក្នុងខ្លួលខ្ទាញ់ក្នុងខ្លួនញ័រ ជួនកាលទៅ រាល់ៗថ្ងៃហ្នឹង មានរោគបេះដូង ឲ្យតែនឹកឃើញកន្លែងគេទាញដៃយកកូនខ្ញុំទៅប្ដីខ្ញុំទៅហ្នឹង ជួនកាលទៅ ចង់គាំងបេះដូងក៏មាន ព្រោះអីរាល់ថ្ងៃនេះ ខ្សោយបេះដូងតែម្ដង។ ដេកទៅញ័រ ហើយឈឺចង្កេះ។

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបញ្ចប់សំណួរប៉ុណ្ណេះ។ សូមអរគុណអ្នកស្រី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ ផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ហើយមានពេល ១៥នាទី ខាងតំណាងសហព្រះរាជអាជ្ញា។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។

[០៩:២១:១៥]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានពេលវេលាខ្លីណាស់ ហើយខ្ញុំ<មិន> មានសំណួរច្រើនដែរ ហើយខ្ញុំចង់សុំឲ្យលោកស្រីបំភ្លឺនូវបញ្ហាមួយចំនួន។ អ្វីដែលខ្ញុំមិនយល់នោះ គឺថាក្រោយពីប្ដីរបស់លោកស្រីស្លាប់ នៅពេលដែលគេឲ្យលោកស្រី<រៀប>ការនោះ តើដំបូងឡើយ លោកស្រីបានប្រកែក ឬក៏អត់?

**លោកស្រី ង៉ែត ចាត៖**

**ឆ៖** ខ្ញុំអត់ហ៊ានប្រកែកផង ខ្ញុំខ្លាច។

**ស៖** នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត <លោកស្រីបាននិយាយនៅក្នុង>ឯកសារ <E3/9790> <>នៅចម្លើយ<៨២>៖ “១០ថ្ងៃក្រោយពីគេសម្លាប់អ្នកស្វាយរៀង គេបង្ខំឲ្យខ្ញុំរៀបការប៉ុន្តែខ្ញុំប្រកែក។” ហើយនៅចម្លើយទី៨២ លោកស្រីបាននិយាយថា៖ “បើចង់និយាយអំពីការរំលោភ គឺខ្ញុំគេរំលោភម្ដងដែរ ដោយសារតែខ្ញុំប្រកែកមិនព្រមការ គេបញ្ជូនខ្ញុំ<ត្រឡប់មកវិញ> ហើយគេចង់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

រំលោភខ្ញុំ ហើយខ្ញុំក៏<បាន>រត់រួច។” ពេលនោះលោកស្រីនិយាយពី មិត្តរិន។ តើលោកស្រីនៅចាំទេ នូវចម្លើយដែលលោកស្រីបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតនោះ តើត្រឹមត្រូវដែរឬទេ? គឺថានៅពេលរៀបការហ្នឹង លោកស្រីមិនបានប្រកែកទេ ក៏ប៉ុន្តែលោកស្រីបានប្រកែកហ្នឹង គឺពីមុនៗមកនោះ គឺនៅពេលដែលគេបង្ខំឲ្យលោកស្រីរៀបការជាមួយនឹងប្ដីទី២ឯនោះ។

[០៩:២៣:០៣]

**ឆ៖** ខ្ញុំបាននែនិយាយថា ទៅអ៊ីចឹង ទៅសមរភូមិ គេជូនទៅរុកពែក ហើយដល់ពេលនេះ គាត់ថា ខ្ញុំមានដំបូកមួយអង្គុយអ៊ីចឹង គាត់ថាន៎ែ ហ្នឹងយកទៅតែពីរនាក់ជាមួយ មិត្តរីម ហើយនិងខ្ញុំហ្នឹង។ ដល់ហើយក៏ហៅ មិត្តរីម ទៅដេក ទៅៗពីខាងអ៊ីចេះដំបូងទៅ ខ្ញុំនៅអង្គុយខាងកើត ខាងលិចដំបូកអ៊ីចេះ គាត់ទៅអ៊ីចឹងបាន ដឹងបានសម្រេច មិនបានសម្រេច ខ្ញុំអត់ដឹងដែរ ព្រោះអីកំបាំងដំបូក។ ដល់ពេលនេះក៏គេមកចាប់ទាញខ្ញុំ ខ្ញុំក៏សំពះអង្វរគេថា ខ្ញុំអត់ស្រួលខ្លួនទេ កុំចាប់ខ្ញុំអី ព្រោះអីខ្ញុំ -- ដល់ហើយ ក៏គេប៉ះសាច់ខ្ញុំអ៊ីចេះ ខ្ញុំថា ខ្ញុំមករដូវ ខ្ញុំអត់ហ៊ានទេ កុំធ្វើបាបខ្ញុំអី ខ្ញុំលើកដៃសំពះគេ។ ហ្នឹងក៏គេល្បួបហ្នឹង ក៏គេអនុគ្រោះឲ្យខ្ញុំអ៊ីចឹងទៅ។

**ស៖** រឿងនេះ កើតឡើង គឺនៅមុនពេលលោកស្រីរៀបការជាមួយនឹងប្ដីទី២ មែនទេ?

**ឆ៖** រៀបការហើយៗហ្នឹង។

**ស៖** លោកស្រីបាននិយាយថា “ចាស” ក៏ប៉ុន្តែខ្ញុំសួរហ្នឹង ខ្ញុំថា កើតមុន ហើយលោកស្រីថាឆ្លើយថា “ចាស”។ អ៊ីចឹងឥឡូវខ្ញុំសួរបញ្ជាក់ឲ្យច្បាស់ថា រឿងហ្នឹងកើតឡើងមុន ឬក៏ក្រោយពេលលោកស្រីរៀបការជាមួយប្ដីទី២?

[០៩:២៤:៣៥]

**ឆ៖** កើតឡើង ខ្ញុំរៀបការហើយៗ បានៗទៅបែករំលែកគ្នាហ្នឹង បានទៅគេបញ្ជូនខ្ញុំទៅលើហ្នឹងតែម្ដង តែរុកពែកតែម្ដង។ បញ្ជូនខ្ញុំទៅម្នាក់ឯង ទៅៗកាន់មេពួកនៅឯរុកពែកហ្នឹង ទៅពីរនាក់ មិត្តរីម ហ្នឹង ក៏ទៅដល់ហ្នឹង ក៏គេឲ្យធ្វើមេពួក។ មេពួក វាកាន់ក្ដាប់ពួកស្វាយរៀងហ្នឹង សុទ្ធតែមិត្តនារីទាំងអស់។ មួយពួកខ្ញុំកាន់ហ្នឹង ប្រហែល២០នាក់ចុះ ខ្ញុំថាអ៊ីចឹងចុះ។ ដល់ពេលកាន់ក្ដាប់ទៅ ដល់ហើយ ក៏គ្នាហ្នឹង អ្នកដូចថាស្គាល់ៗគ្នាថា អ្ហ៎អ្ហែងបានមកកាន់ក្ដាប់ខ្ញុំអ៊ីចឹង គាត់ថា អូនអើយ ខ្ញុំនិយាយតាមប្រវត្តិខ្ញុំបែបបទថា គេសម្លាប់ប្ដី សម្លាប់អីអ៊ីចឹងថា អត់ទេ ម៉ែឯងដឹងតែរស់ ហៅខ្ញុំម៉ែ ប៉ុន្តែខ្ញុំ១៧ទេ ប៉ុន្តែគេយកទៅធ្វើដូចថា នេះបើថាទៅ ទៅទាំងអស់គ្នាតែម្ដង។ ដល់តែពេលនោះ ក៏គេចាត់កម្លាំងថា ទៅម្ដង

01376770



ប្រាំនាក់ ម្ដងបួននាក់ ដល់ពេលនេះ ទៅអស់រលីង។

**ស៖** ខ្ញុំនឹងផ្ដោតទៅលើការរៀបការរបស់លោកស្រី។ លោក<ស្រី>ដឹងទេថា<តើអ្នកណាជាអ្នកសម្រេច តើមេរបស់លោកស្រីជាអ្នកសម្រេច ឬក៏អាជ្ញាធរនៅការដ្ឋាន គឺ>នៅក្នុងស្រុកបាកាន <> ជាអ្នកសម្រេចរៀបការឲ្យលោកស្រីលើកទី២ <ភ្លាមៗ>ក្រោយពីគេសម្លាប់ប្ដីទី១ជាខ្មែរក្រោមនោះ? ហេតុ<អ្វី>បានជាគេគិតថា ជាការសំខាន់ក្នុងការរៀបការម្ដងទៀតឲ្យលោកស្រី កុំឲ្យលោកស្រីនៅមេម៉ាយយូរនោះ? តើលោកស្រីដឹងទេ ថាមូលហេតុ<អ្វី>បានជាគេឲ្យលោកស្រីរៀបការម្ដងទៀតភ្លាមៗក្រោយពីប្ដីលោកស្រីស្លាប់ភ្លាមនោះ?

**ឆ៖** ខ្ញុំឃើញតែ ពូស៊ុន ហ្នឹងគាត់អ្នកហៅទៅ ឲ្យទៅរៀបការហ្នឹងតែម្ដង គាត់ថាទៅរៀបការបឹងខ្នារហ្នឹង។

**ស៖** សូមអរគុណ។ ពេលរៀបការ លោកស្រីនិយាយថា មានតំណាងមកពីអង្គការចូលរួម។ តើអ្នកតំណាងទាំងអស់ហ្នឹងមានបានពន្យល់ថា លោកស្រីត្រូវតែរួម<ដំណេក>ទេ គឺគេឲ្យចុះសម្រុងគ្នាជាមួយប្ដីហ្នឹង គេមានបាននិយាយអ៊ីចឹងទេ ពេលរៀបការនោះ?

[០៩:២៧:០៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងរបៀបដែលសហព្រះរាជអាជ្ញាសួរសំណួរនេះ។ នេះជាការបកស្រាយរបស់គាត់ ដែលប្រើពាក្យថា “ចុះសម្រុងជាមួយប្ដី” ដែលមានន័យថា “រួមដំណេក” នោះ។ ខ្ញុំសូមជំទាស់នឹងសំណួរបែបនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ នេះជាពាក្យដែលយើងបានស្ដាប់ឮជាញឹកញាប់នៅក្នុងសវនាការនេះហើយ។ អ៊ីចឹងខ្ញុំសូមរៀបចំសំណួរឡើងវិញ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** តើអាជ្ញាធរដែលតំណាងឲ្យអង្គការនោះ គេមានបានពន្យល់ថា លោកស្រីត្រូវតែរួម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដំណេកជាមួយនឹងប្ដីថ្មី<ឬ>ទេ?

**លោកស្រី ង៉ែត ចាត៖**

**ឆ៖** គេបានឲ្យរួមដំណេកថា ខំប្ដេជ្ញាចិត្តយកគ្នាទៅ ខំបង្កកើតកូនឲ្យបានច្រើន ឲ្យបានមានកូនមានអីទៅ។ ខ្ញុំមានកូនទៅ បើមនុស្សស្គមហូបតែបបរ បានអីមានកូន បើអត់មានកម្លាំងកំហែងអីផង ប៉ុន្តែមិនហ៊ានថាទេ ប៉ុន្តែប្ដេជ្ញាចេះតែស្រែកថាប្ដេជ្ញា ទះដៃអ៊ីចឹង ចេះតែទះនឹងគេអ៊ីចឹងទៅ។

[០៩:២៨:២៧]

**ស៖** តើតំណាងអង្គការ គេមានបានប្រាប់ថា ហេតុ<អ្វី>បានជាប្ដីប្រពន្ធហ្នឹង ត្រូវបង្កើតកូនឲ្យបានច្រើននោះ? <តើដើម្បីគោលបំណងអ្វី?>

**ឆ៖** គាត់ថាឲ្យយកទៅបម្រើអង្គការ ឲ្យបានច្រើន កុំឲ្យខ្វះខាត។ ដូចជាយើងហូបបបរថ្ងៃនេះ ខំបង្កបង្កើនផលឲ្យបានច្រើន ជីវភាពឲ្យបានបរិបូរ ហើយធ្វើម៉េចឲ្យបានបរិបូរ បើខំដកសំណាប១ថ្ងៃ ៥ផ្លូនកំណត់ឲ្យហើយ នៅតែឃើញហូបតែបបរ ហើយពោត ហើយដំឡូងអ៊ីចឹង អត់ដឹងដែរ ខ្ញុំអត់ដឹងដែរ។ អត់ដែលបានបាយហូបផង ជីវភាព។

**ស៖** ក្រៅពីការរៀបការរបស់លោកស្រីនោះ តើមានការរៀបការណាផ្សេងទៀតទេ នៅក្នុងឃុំរំលេច ស្រុកបាកាននោះ?

**ឆ៖** ខ្ញុំអត់ដឹងដែរ ដឹងរៀបការប៉ុន្មានគូ ខ្ញុំអត់ដឹង ខ្ញុំដឹងតែថ្ងៃខ្ញុំរៀបការហ្នឹង១០គូ។

**ស៖** ខ្ញុំសួរសំណួរនេះ ពីព្រោះថាក្នុងឯកសារ D22/2152/1 នៅទំព័រជាភាសាអង់គ្លេស 0054 6329 គឺជាសេចក្ដីសង្ខេបនៃចម្លើយរបស់លោកស្រី។ ជាភាសាអង់គ្លេស ខ្ញុំសូមដកស្រង់ ៖ “ក៏មានការបង្ខំឲ្យយុវជន នារីៗក្មេងរៀបការផងដែរ។ ហើយក្រោយមក២០ថ្ងៃក្រោយការរៀបការ ពួកគេទាំងអស់ ក៏ត្រូវបានយកទៅសម្លាប់ចោល។” បញ្ចប់ការដកស្រង់។ តើលោក<ស្រី>នឹកឃើញរឿងហ្នឹងទេ? លោកស្រីមានចាំថា លោកស្រីបាននិយាយហេតុការណ៍ហ្នឹងទេ?

[០៩:៣០:៤៦]

**ឆ៖** ហ្នឹងខ្ញុំដឹងតែប្អូនថ្លៃខ្ញុំ វានៅកងយុវ័ន ប៉ុន្តែវាឲ្យគេរៀបការមុនគេយកទៅសម្លាប់ចោលហ្នឹង គេរៀបការគ្រួសារវា ដឹងប៉ុន្មានគូ ប៉ុន្តែប្អូនថ្លៃខ្ញុំ វាទៅរៀបការ។ គេយកទៅរៀបការ ដល់ពេលវាមក វាអត់ចុះដំណេកទៅ វាប្រទូស្តប្រទាំង វាមិនដឹងជាម៉េចអីម៉េច ខ្ញុំក៏អត់បានតាមដានវា ព្រោះអីវានៅអង្គភាពជាមួយគ្នាដែរ ដេកជិតដែរ ប៉ុន្តែដូចខ្ញុំហ៊ានតាមដានវា។ ថា ខ្ញុំចេះថាអូនអើយ! អូនឯងខំកសាង

ខ្លួនទៅ។ ស្អីៗ ខ្ញុំចេះតែនិយាយវាច្រើនអ៊ីចឹងទៅ ដល់ហើយក៏បន្តទៅមុខទៀត ក៏មិនវាយ៉ាងម៉េច គេយកទៅបាត់អស់អ៊ីចឹងទៅ ប្អូនខ្ញុំ។ ប្អូនថ្លៃខ្ញុំ គេយកទៅបាត់អស់ហើយ សម្លាប់ ទៅវ៉ៃស្អីចោលអស់។

**ស៖** ឥឡូវនេះ ខ្ញុំសូមនិយាយអំពីប្ដីទី១របស់លោកស្រី និងក្រុមគ្រួសាររបស់គាត់។ លោកស្រីអាយុប៉ុន្មាន នៅពេលដែលលោកស្រីរៀបការជាមួយនឹង សៀន <យ៉េន>? ហើយគឺ<រយៈពេល>ប៉ុន្មាន<>ដែរ មុនពេលខ្មែរក្រហមចូលកាន់អំណាចនៅឆ្នាំ១៩៧៥នោះ ដែលលោកស្រីរៀបការ?

**ឆ៖** ខ្ញុំរៀបការកាលឆ្នាំ៧១។ បានកូនពីរ ត្រឹម៧៤ បានកូនពីរ។

**ស៖** លោកស្រីបានឆ្លើយថា ប្ដីរបស់លោកស្រីជាខ្មែរក្រោម ក្រុមគ្រួសារគាត់ក៏ខ្មែរក្រោមដែរ ហើយមករស់នៅតំបន់របស់លោកស្រីហ្នឹង គឺតាំងពីយូរមកហើយ។ អ៊ីចឹងខ្ញុំចង់ដឹងថា <តើ>ប្ដីរបស់លោកស្រី និងក្រុមគ្រួសារគាត់ហ្នឹង <ឬក៏>ខ្មែរក្រោម<ផ្សេងទៀតនៅក្នុងស្រុកបាកាន ចាត់ទុកខ្លួនគេថាជាខ្មែរ> ឬក៏ជាវៀតណាម?

**ឆ៖** ខ្មែរក្រោម ព្រោះអី គាត់មកកើត ខ្ញុំអត់ដឹងប្រវត្តិឪក្មេកខ្ញុំយ៉ាងម៉េច ប៉ុន្តែប្ដីខ្ញុំ គាត់កើតនៅភូមិរូងតាកុកហ្នឹងហ្មង។

**ស៖** តើគាត់មានឯកសារ ដូចជាអត្តសញ្ញាណប័ណ្ណខ្មែរទេ?

**ឆ៖** អត់មានទេ គេវ៉ៃចោល។ គេ ដឹងបាត់ទៅណាអស់ ខ្ញុំម៉េចមានអត្តសញ្ញាណប័ណ្ណ តែសូម្បីតែក្រដាសស្អីបន្តិច ក៏គ្មានជាប់នឹងខ្លួន។ ប៉ុន្តែដឹងថា គ្រួសារខ្ញុំហ្នឹងខ្មែរក្រោម។

**ស៖** លោកស្រីបានឆ្លើយថា ខ្មែរក្រោមគេប្រមូលផ្ដុំទៅដាក់នៅសហករណ៍ខ្នារទទឹង។--

[០៩:៣៤:០៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអន្តរាគមន៍ជាថ្មីម្ដងទៀត ពីព្រោះខ្ញុំឃើញថាសហព្រះរាជអាជ្ញាកំពុងតែសួរពាក់ព័ន្ធនឹងបញ្ហាខ្មែរក្រោម។ ខ្ញុំសូមបញ្ជាក់ថា ខ្មែរក្រោមនេះមិនពាក់ព័ន្ធនឹងសំណុំរឿងនៃសំណុំរឿង០២/០២ទេ។ ដូច្នេះខ្ញុំសូមជំទាស់។ សូមអង្គជំនុំជម្រះបង្គាប់កុំឲ្យគាត់បន្តទៅទៀត។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំសូមឆ្លើយតប។ វាជាការសំខាន់សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីដែលគាត់បានបាត់បង់ប្ដីរបស់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01376773



គាត់ និងក្រុមគ្រួសាររបស់ប្ដីគាត់។ អ៊ីចឹងហើយបានខ្ញុំចង់សួរដឹង ថាតើខ្មែរក្រហមយល់យ៉ាងម៉េច ចំពោះក្រុមជនជាតិខ្មែរក្រោមនេះ។ តើគេចោទប្រកាន់ថា ខ្មែរក្រោមហ្នឹងគឺជាជនជាតិវៀតណាម ឬក៏ជាប់និន្នាការវៀតណាម ឬក៏យ៉ាងម៉េចនោះ។ ខ្ញុំគិតថា សំណួរហ្នឹង វាមានសារៈសំខាន់ ហើយមានភាពពាក់ព័ន្ធ លោកប្រធាន។

[០៩:៣៥:០៧]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ ខ្ញុំសូមបញ្ជាក់មួយ ខ្ញុំបានអានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងខ្មែរក្រោមមុននឹងសក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ ខ្ញុំគិតថា អង្គជំនុំជម្រះបានបញ្ជាក់ច្បាស់រួចមកហើយ ។ខ្ញុំគិតថា មេធាវីការពារក្ដីយល់ខុសនូវសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។ ខ្ញុំសូមយោងលើឯកសារ E1/262 និងឯកសារ E1/304 នៅក្នុងឯកសារទាំងពីរនេះ អង្គជំនុំជម្រះបានប្រកាសសេចក្ដីសម្រេចផ្ទាល់មាត់ ដោយបានបញ្ជាក់ដូចតទៅ។ <វាបានធ្វើនៅ>ថ្ងៃទី១២ ខែ<កុម្ភៈ> ឆ្នាំ២០១៥ អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងសម្រេចទៅលើអ្វីដែលត្រូវបានចាត់ទុកថា ជាផ្នែកនៃក្រុមជនជាតិវៀតណាម គឺថាតើជាវៀតណាមដែលមានសញ្ជាតិវៀតណាម ឬក៏អ្នកដែលត្រូវបានគេចាត់ទុកថាជាជនជាតិវៀតណាម។ ដូច្នេះអង្គជំនុំជម្រះបានបញ្ជាក់ថា បញ្ហាខ្មែរក្រោមនេះ គឺវាមានភាពពាក់ព័ន្ធនៅក្នុងក្របខ័ណ្ឌនេះ។

ហើយនៅពេលអង្គជំនុំជម្រះចេញសេចក្ដីសម្រេចនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ លើបញ្ហាខ្មែរក្រោមនេះគឺ E1/304 អង្គជំនុំជម្រះបានបញ្ជាក់ដូចតទៅ ខ្ញុំសូមដកស្រង់៖ "ភស្តុតាងពាក់ព័ន្ធនឹងខ្មែរក្រោម អាចមានភាពពាក់ព័ន្ធ ដោយសារតែមានបញ្ហាមួយចំនួនហ្នឹង វាស្ថិតនៅក្នុងសំណុំរឿងនៃសំណុំរឿង០០២/០២ ឧទាហរណ៍ដូចជាបរិបទប្រវត្តិសាស្ត្រ គោលនយោបាយ ឬក៏ឧក្រិដ្ឋកម្មផ្សេងទៀតដែលត្រូវបានចោទប្រកាន់ដែលស្ថិតនៅក្នុងសំណុំរឿង ហើយដែលមានជនរងគ្រោះមួយចំនួននោះ ជាខ្មែរក្រោម។" បញ្ហាដែលអង្គជំនុំជម្រះដកចេញពីវិសាលភាពនោះ គឺការធ្វើទុក្ខបុកម្នេញ ហើយនិងការប្រល័យពូជសាសន៍ទៅលើខ្មែរក្រោមដែលជាក្រុមដាច់ដោយឡែកមួយ ក៏ប៉ុន្តែចំណុចផ្សេងទៀតហ្នឹង គេអាចទទួលយកបាន។

[០៩:៣៧:២២]

ដូច្នេះការធ្វើទុក្ខបុកម្នេញទៅលើខ្មែរក្រោម ចាត់ដូចក្រុមមួយហ្នឹង គឺត្រូវបានដកចេញពីវិសាល

ភាព។ ការប្រល័យពូជសាសន៍ខ្មែរក្រោម គឺត្រូវបានដកចេញពីវិសាលភាព ក៏ប៉ុន្តែអង្គជំនុំជម្រះអាចស្តាប់នូវសក្ខីកម្មពាក់ព័ន្ធនឹងខ្មែរក្រោមបាន។ ដូច្នេះមិនមានសេចក្តីសម្រេចណាមួយដែលរារាំងដើមបណ្តឹងរដ្ឋប្បវេណី អ្នកជំនាញ ឬសាក្សីមិនឱ្យនិយាយពីបញ្ហាទាំងអស់នេះបានទេ។ នេះជាអ្វីដែលខ្ញុំយល់ច្បាស់ចេញពីសេចក្តីផ្ទាល់មាត់ទាំងពីរដែលអង្គជំនុំជម្រះបានចេញពាក់ព័ន្ធនឹង<ប្រធានបទ>នេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន បើសិនជាខ្ញុំអាច ខ្ញុំសូមឆ្លើយតប។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងការកំណត់គោលដៅលើខ្មែរក្រោម វាមានលក្ខណៈច្បាស់លាស់ហើយ។ ដូច្នេះមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំនៅពេលនេះឱ្យពិចារណាសេចក្តីសម្រេចនេះឡើងវិញ។ ចំពោះខ្ញុំ វាគ្មានកាលៈទេសៈណាថ្មីមួយត្រូវសម្រេចឡើងវិញនោះទេ។ សេចក្តីសម្រេចមានលក្ខណៈច្បាស់លាស់ ហើយនៅតែច្បាស់លាស់ដដែល។ កូនក្តីរបស់ខ្ញុំគឺគាត់គួរតែដឹងថា គាត់គួរតែការពារខ្លួនឯងដោយរបៀបណាពាក់ព័ន្ធនឹងការកំណត់គោលដៅលើខ្មែរក្រោម។ ខ្ញុំមិនយល់អំពីទឡ្ហីករណ៍ដែលបានលើកឡើង ឧទាហរណ៍ថា អៀង សារី<>គឺជាខ្មែរក្រោម។ តើសញ្ជាតិ ឬក៏អ្នកដែលមកពីកន្លែងណាមួយនោះ វាមានចំណងពាក់ព័ន្ធជាមួយនឹង<ចោទប្រកាន់ជាគោលដៅ>វៀតណាមនោះយ៉ាងណា? <ព្រោះថានេះជាអ្វីដែលនៅក្នុង>វិសាលភាព។ <ការព្យាយាមប្រើទ្វារក្រោយ ដើម្បី>យកបញ្ហា<កំណត់គោលដៅលើខ្មែរក្រោមចូលក្នុងការធ្វើទុកបុកម្នេញលើជនជាតិវៀតណាមគឺ<គ្មានភស្តុតាងទេ> ហើយវាជាដំណាក់កាលមួយដែលលើកឡើង វាយឺតពេលហើយនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់យើង។

[០៩:៣៩:៣០]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

មុនពេលមេធាវី អង់តា ហ្គីសសេ<អន្តរាគមន៍ ខ្ញុំមិនដឹងថាតើខ្ញុំត្រូវបានគេបកប្រែឱ្យបានត្រឹមត្រូវដែរឬអត់ទេ>--

**ប្រធានអង្គជំនុំ៖**

មេធាវី អង់តា ហ្គីសសេ មុន!

អង់តា ហ្គីសសេ អញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ដើម្បីបំពេញបន្ថែមទៅនឹងការជំទាស់របស់ខ្ញុំ ហើយខ្ញុំចង់លើកឡើងពីអង្គច្បាប់។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01376775



ក្នុងពេលពិភាក្សាគ្នា យើងតែងតែលើកអំពីបញ្ហាដដែលៗ ភាពពាក់ព័ន្ធ ឬក៏អត់នៅពេលដែលចំណុចណាមួយមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២។ យើងតែងតែពិភាក្សាគ្នារបៀបនេះដដែលៗថា យើងតែងតែស្ថិតនៅក្នុងអង្គជំនុំជម្រះដែលគោរពច្បាប់ស៊ីវិល<> ហើយដែលយើងមានដីកាបំបែកនីតិវិធីដែលមានអង្គហេតុច្បាស់លាស់ មានអង្គហេតុជាក់លាក់ដែលត្រូវបានបញ្ជូនមកអង្គជំនុំជម្រះហើយដីកាបំបែកកិច្ចដំណើរការនីតិវិធីហ្នឹងបញ្ជាក់ច្បាស់អំពីអង្គហេតុដែលត្រូវជំនុំជម្រះ។ ខ្ញុំគិតថាបញ្ហាច្បាប់នោះ <យើងត្រូវតែយល់ដឹងពីបុព្វហេតុរបស់វាពី ព្រោះ>វាមានផលប៉ះពាល់ទៅលើអ្វីដែលយើងការពារក្ដី នៅពេលដែលយើងសរសេរសេចក្ដីសន្និដ្ឋានបញ្ចប់នោះ គឺវាបញ្ហា<ធាតុផ្សំដែលមិនមាននៅក្នុងវិសាលភាពនៃសំណុំរឿង ឬក៏ធាតុផ្សំដែលមិនមែនជាលទ្ធផលនៃបទ>ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយទេ។ <នេះជាបញ្ហាមួយ ដែលត្រូវបានលើកឡើងចំពោះ> បញ្ហារឿងខ្មែរក្រោម <ហើយវាក៏មានសុពលភាពផងដែរពាក់ព័ន្ធនឹងបញ្ហាផ្សេងៗទៀត>។ វាមានបញ្ហាប្រទាំងប្រទើសគ្នាត្រង់អង្គច្បាប់ នៅពេលដែលយើងធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនោះ។

[០៩:៤១:១៩]

**លោក វាំងសង់ វ៉ាយដ៍ ដេស្ពាងលេះ**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ខ្ញុំមិនទាន់បានសួរ<សំណួរ>ផងអម្បាញ់មិញនោះ។ អ៊ីចឹងមេធាវីការពារក្ដី គឺជំទាស់ទាំងខ្ញុំមិនបានសួរផង អ៊ីចឹងគួរតែច្រានចោល។ អ៊ីចឹងទី២ យើងចង់ដឹងថាតើទស្សនៈរបស់ខ្មែរក្រហមនោះ តើខ្មែរក្រោមនៅស្រុកនោះត្រូវបានគេចាត់ទុកថាជាជនជាតិវៀតណាមដែរឬក៏អត់? អ៊ីចឹងខ្ញុំគិតថាវាជាអង្គហេតុពាក់ព័ន្ធ ហើយវាជាអង្គហេតុដែលអាចស្ថិតនៅក្នុងធាតុផ្សំនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទៅលើជនជាតិវៀតណាម។ នេះគ្រាន់តែជាទស្សនៈរបស់កម្ពុជាប្រជាធិបតេយ្យ មិនមែនជាទស្សនៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទេ។ ចំណុចនេះមាននៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះហើយ។ អ៊ីចឹងខ្ញុំគ្រាន់តែចង់ដឹងពីដើមបណ្ដឹងរដ្ឋប្បវេណីផ្ទាល់ ថាតើគាត់ដឹងដែរឬទេថាតើបើតាមទស្សនៈរបស់ខ្មែរក្រហមនោះ គេចាត់ទុកខ្មែរក្រោមយ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចបដិសេធសេចក្ដីជំទាស់របស់មេធាវីការពារក្ដី ហើយសាក្សីឆ្លើយតបនឹងសំណួរនេះ ហើយសំណួរចុងក្រោយហើយ ប្រើពេលវេលាវំលោភពេលវេលាទៀតហើយសហព្រះរាជ

អាជ្ញារងអន្តរជាតិ។

[០៩:៤២:៤០]

**លោកស្រី ង៉ែត ចាត៖**

**ឆ៖** គេថាម៉េចអំមិញ?

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** <សំណួររបស់ខ្ញុំ គឺដូចតទៅ។>

**ឆ៖** ខ្ញុំស្ដាប់អត់ទាន់។

**ស៖** ដែលខ្ញុំអំមិញ អម្បាញ់មិញមិនទាន់បានសួរសំណួរផង។ ខ្ញុំនឹងសួរសំណួរ ខ្មែរ<ក្រោម> ដែលគេបានប្រមូលទៅដាក់នៅសហករណ៍ខ្នារទទឹងនោះ ដែលក្នុងនុំងមានប្ដីលោកស្រី និងក្រុមគ្រួសារគាត់ដែរនោះ តើលោកស្រីដឹងទេថា តើខ្មែរក្រហមហ្នឹងចាត់ទុកខ្មែរក្រោមហ្នឹងជាខ្មែរ ឬក៏ជាជនជាតិវៀតណាម? ហើយបន្ថែមពីលើនេះទៀតនោះ តើគេ<បាន>ចោទ ឬក៏គេសង្ស័យខ្មែរក្រោមទាំងអស់ហ្នឹងពីបទអ្វីដែរ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមជំទាស់សំណួរនេះ។ សំណួរនេះ គឺថាសួរខុសទៅលើថ្នាក់ផ្សេងៗ។ ហើយចំណុចទី១ គឺថាសួរឲ្យស្មាន។ ទី២ នរណាគេជាខ្មែរក្រហម? យើងនិយាយបញ្ហាខ្មែរក្រហមនេះតាំងពី៩ឆ្នាំមុន ចាប់ផ្ដើមដំបូងមកនៃរឿងក្ដីនេះ។ សំណួរនេះគួរតែរាំងដាច់ខាតលោកប្រធាន។

[០៩:៤៤:០៧]

**ប្រធានអង្គជំនុំ៖**

ដែលបដិសេធសមស្រប។ ហើយសហព្រះរាជអាជ្ញារងអន្តរជាតិចប់ហើយ អញ្ជើញប្រគល់វេទិកាជូនទៅមេធាវីការពារក្ដី នួន ជា។

**លោក លីវ សុវណ្ណា៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** សូមជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំឈ្មោះ លីវ សុវណ្ណា ជាមេធាវីនៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក្នុងក្រុមការពារក្ដីលោក នួន ជា ខ្ញុំមានសំណួរមួយចំនួនសួរលោកស្រីព្រឹកនេះ។ ទី១ ខ្ញុំចង់ដឹងពីការរៀបអាពាហ៍ពិពាហ៍ទី១ របស់លោកស្រី។ លោកស្រីបានឆ្លើយថា លោកស្រីរៀបការឆ្នាំ១៩៧១ អ៊ីចឹងពេលនោះតើលោកស្រីមានអាយុប៉ុន្មានដែរ?

**លោកស្រី ង៉ែត ចាត៖**

**ឆ៖** ខ្ញុំអាយុ១៥ឆ្នាំ ព្រោះអីម្ដាយខ្ញុំគេជិតថា ដូចថាគេជិតចាប់មិត្តនារីហើយ ម៉ែខ្ញុំក៏គាត់ខ្លាចដល់ពេលគេចូលសួរទៅ ក៏រៀបចំឲ្យខ្ញុំយកគ្រួសារអ៊ីចឹងទៅ។

**ស៖** បាទ តើការរៀបការរបស់លោកស្រីហ្នឹង វាកើតចេញពីការរៀបចំរបស់ឪពុកម្ដាយ ឬមួយក៏ជាការសម្រេចចិត្តរបស់លោកស្រីផ្ទាល់?

[០៩:៤៥:៣៩]

**ឆ៖** ឪខ្ញុំផង ម៉ែខ្ញុំផង ក៏សម្រេចចិត្តទាំងអស់គ្នា សួរខ្ញុំអីវិញ ស្ម័គ្រចិត្តទាំងអស់គ្នាក៏ព្រមព្រៀងការឲ្យខ្ញុំទៅ។

**ស៖** តើលោកស្រីស្គាល់ប្ដីលោកស្រីទេ មុនពេលដែលលោកស្រីរៀបការនោះ? ហើយបើស្គាល់ៗប៉ុន្មានឆ្នាំមុន ប៉ុន្មានខែមុនពេលរៀបការដែរទៅ?

**ឆ៖** ខ្ញុំស្គាល់គាត់យូរដែរហើយ ព្រោះអីគាត់នៅដូចថា បងយកបង ប៉ុន្តែម្ដាយខាងប្រុសហ្នឹងខុសគ្នា។ ខ្ញុំ បងខ្ញុំក៏យក បងខ្ញុំក៏មកយក បង១ យ៉ែន ហ្នឹង ប្រុសមកយកបងខ្ញុំស្រី។ ហើយដល់ខ្ញុំស្រីទៅយកប្អូនថ្លៃបង យ៉ែន ហ្នឹងប្រុស បងរឿន ហ្នឹងប្រុស។

**ស៖** បាទ ខ្ញុំចង់បញ្ជាក់ចំណុចមួយដែលលោកស្រី សហព្រះរាជអាជ្ញាបានសួរ ប៉ុន្តែលោកស្រីមិនបានឆ្លើយច្បាស់។ លោកស្រីបានឆ្លើយថា លោកស្រីមិនបានប្រកែកទេ គឺថ្ងៃនុ៎ងគឺគេឲ្យលោកស្រីទៅរៀបការ គឺលោកស្រីរៀបការ។ ប៉ុន្តែយោងទៅលើចម្លើយរបស់លោកស្រី នៅក្នុងកំណត់ហេតុជាមួយសហចៅក្រមស៊ើបអង្កេតគឺឯកសារ E3/9790 ត្រង់សំណួរទី៩៣។ គេសួរថា -- ពេលនោះលោកស្រីឆ្លើយថា៖ “នៅពេលនោះខ្ញុំទៅជាមួយនឹង មិត្តរិន ដោយសារខ្ញុំបដិសេធថា ខ្ញុំមិនរៀបការ។ បន្ទាប់មកគេនិយាយថា មិត្តឯងមិនរៀបការអ៊ីចឹង គេនឹងបញ្ជូនទៅខាងលើ។” អ៊ីចឹងសំណួរខ្ញុំសួរថា តើលោកស្រីមានបានប្រកែកទេ ពេលដែលគេឲ្យលោកស្រីរៀបការ ព្រោះចម្លើយនេះឃើញថាវាផ្ទុយពីចម្លើយរបស់លោកស្រី?

[០៩:៤៧:៤៥]

01376778



**ឆ៖** ខ្ញុំប្រកែកដែរ ប៉ុន្តែខ្ញុំអត់ហ៊ាននិយាយខ្លាំង ខ្ញុំខ្លាច ប៉ុន្តែខ្ញុំនៅតែសារភាពថា ខ្ញុំប្រកែក ប៉ុន្តែខ្ញុំនៅតែព្រមយកអ៊ីចឹង ប៉ុន្តែខ្ញុំប្រកែកនៅមុខ មិត្តរិន ខ្ញុំប្រកែក។ ប៉ុន្តែថា ដល់ហើយ មិត្តរិន ហ្នឹងគាត់ថា មិត្តឯងប្រកែកអត់បានទេ។ ប៉ុន្តែដល់ហើយ ខ្ញុំថាអ៊ីចឹង ខ្ញុំក៏ព្រម ក៏ព្រម ក៏ទៅៗអ៊ីចឹង។

**ស៖** តើ មិត្តរិន ហ្នឹងគាត់មានតួនាទីអីដែរ មិត្តរិន ហ្នឹង?

**ឆ៖** មិត្តរិន ហ្នឹងគណៈសមរភូមិ។ ខ្ញុំដឹងតែគណៈសមរភូមិ ប៉ុន្តែមិនដឹងគាត់ធ្វើខាងអីៗ ខ្ញុំអត់ដឹងទេ ប៉ុន្តែឮតែអង្គភាពខ្ញុំហ្នឹង គេហៅថា មិត្តរិន ហ្នឹងគណៈសមរភូមិ។

**ស៖** តើលោកស្រីស្គាល់ មិត្តរិន ហ្នឹងមានប៉ុន្មាននាក់ដែរនៅក្នុងអង្គភាពលោកស្រី ឬក៏ក្នុងសហករណ៍លោកស្រីហ្នឹងមាន មិត្តរិន ហ្នឹងប៉ុន្មានាក់ដែរ លោកស្រីស្គាល់ប៉ុន្មាននាក់ដែរ?

**ឆ៖** ខ្ញុំស្គាល់តែ មិត្តរិន ហ្នឹងមួយហ្នឹង ព្រោះអីខ្ញុំ គេជម្លៀសទៅនៅខ្នារទទឹង ខ្ញុំអត់សូវស្គាល់គេផង ព្រោះអីខ្ញុំទើបតែទៅនៅ។

**ស៖** ចុះលោកស្រីឆ្លើយថាមុនហ្នឹងថា មិត្តរិន ដែលត្រូវឈ្លបម្នាក់ដែលគាត់នាំទៅ ថាទៅលោកស្រីគិតថាទៅរំលោភហ្នឹងណ៎ា មិត្តរិន ហ្នឹងហើយ មិត្តរិន ដែលលោកស្រីកំពុងតែនិយាយហ្នឹងជាមនុស្សតែមួយ ឬមួយយ៉ាងម៉េច?

**ឆ៖** មិនមែនមនុស្សតែមួយទេ។ ឈ្លបហ្នឹងឈ្លបផ្សេង នេះមិត្តរិន ផ្សេង ឈ្លបផ្សេង។ ឈ្លបបាននាំខ្ញុំទៅថា ដូចថាទៅ ដឹងគេថាយកទៅណាទេ ប៉ុន្តែបណ្ដើរខ្ញុំទៅជាមួយ មិត្តរឹម។ មួយមិត្តរិន ហ្នឹងគណៈសមរភូមិ, មិត្តរឹម ហ្នឹងគ្នាខ្ញុំ។

[០៩:៤៩:៥៣]

**ស៖** ពីម្សិលមិញ លោកស្រីបានឆ្លើយថា គេថាបើសិនជាយើងមិនព្រមរៀបការ គេនឹងបញ្ជូនទៅធ្វើការនៅខាងលើ។ អ៊ីចឹងពាក្យ "បញ្ជូនទៅធ្វើការនៅខាងលើ" ហ្នឹង គឺលោកស្រីពន្យល់មើលធ្វើការអីនៅខាងលើហ្នឹង?

**ឆ៖** អត់ទាន់បានបញ្ជូនទៅផង ប៉ុន្តែគេថា បើមិត្តឯងអត់ព្រមព្រៀង គេបញ្ជូនទៅលើ គេប្រាប់ថាអ៊ីចឹង។ ខ្ញុំអត់ដឹងគេថាទៅណាមកណា ខ្ញុំអត់ដឹងទេ ប៉ុន្តែខ្ញុំយល់ថា មើលទៅគ្រួសារខ្ញុំមុនគេថា ឲ្យទៅកាច់ពោត មិនទៅកាច់ពោត លេងយកគ្រួសារខ្ញុំទៅចល័តចោល។ ដល់ពេលខ្ញុំអត់យកគ្រួសារ គេថាបញ្ជូនទៅលើ ខ្ញុំអត់ដឹងទៅណា គេថាទៅលើ ខ្ញុំថាតាមគេអ៊ីចឹងទៅ។

**ស៖** ដើម្បីរំឭកការចងចាំរបស់លោកស្រី ខ្ញុំសូមដកស្រង់ឯកសារលេខ E3/9790 ដដែលត្រង់

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

សំណួរទី៩៥ គេបានសួរលោកស្រីថា៖ “ក្រោយគេ -- ពេលដែលគេបង្ខំលោកស្រីឲ្យរៀបការ ហើយលោកស្រីបដិសេធ តើគេបានធ្វើអ្វីចំពោះលោកស្រី? លោកស្រីបានឆ្លើយថា៖ គេបានបញ្ជូនខ្ញុំទៅធ្វើការនៅខាងលើជាមួយនឹង រិន។ សំណួរទី៩៦ គេសួរថា៖ តើបញ្ជូនលោកស្រីទៅធ្វើការខាងលើកន្លែងណា? ចម្លើយ៩៦របស់លោកស្រីឆ្លើយថា៖ គេបញ្ជូនខ្ញុំទៅធ្វើការនៅព្រែកជីក។” អ៊ីចឹង តើលោកស្រីចាំបានចម្លើយរបស់លោកស្រីទេ?

**ឆ៖** ខ្ញុំបានភ្លេចខ្លះហើយ ព្រោះអីខ្ញុំចាស់ហើយ ខ្ញុំវាមានរោគបេះដូងផង វាភ័យផង ខ្ញុំអត់សូវបាននឹកនាទេ ព្រោះអីខ្ញុំវារវល់រកស៊ី បានគ្រួសារក្រោយនេះ ក៏គាត់ចាស់ ណាមួយខ្ញុំក៏ខំតែរកស៊ីអ៊ីចឹងអត់បាននឹកនា ដូចថា គ្មានអារម្មណ៍។ ដល់ពេលថា នេះទៅបាន អត់នឹកឃើញ ភ្លេចអ៊ីចឹងតែម្តង។

[០៩:៥១:៥០]

**ស៖** តើពេលនេះលោកស្រីមានរំឭកថា លោកស្រីធ្លាប់បានប្រកែក ហើយគេក៏ឲ្យលោកស្រីទៅធ្វើការនៅព្រែកជីក តើលោកស្រីនឹកឃើញចំណុចនេះទេ?

**ឆ៖** ទៅធ្វើការប្រឡាយព្រែកជីក មានជាន់រហាត់ទឹក ធ្វើស្រែប្រាំង កណ្តាលយប់ឡើងហៅទៅទប់កណ្តាប់។ កណ្តាប់មកពីវាលត្រពាំងអណ្តែងអ៊ីចឹងទៅ នាំគ្នាចុះក្នុងប្រឡាយប្រជីកហ្នឹង ចុះទឹកៗត្រឹមកអ៊ីចឹង ទប់កណ្តាប់ ស្រង់ដាក់ទៅលើភ្លឺប្រឡាយ។ ទុកសម្រាប់យកទៅស្ទូង ក្នុងប្រឡាយព្រែកជីកហ្នឹង។

**ស៖** លោកស្រី ខ្ញុំសូមបញ្ជាក់មួយ។ អំមិញសំណួរខ្ញុំសួរថា លោកស្រីធ្លាប់បានប្រកែកមិនព្រមរៀបការម្តង។ តើរឿងនេះ ពិតប្រាកដដែរឬទេ?

**ឆ៖** ខ្ញុំប្រកែក ៗបានតែលាក់កំបាំងដែរ ខ្ញុំអត់ហ៊ានពេញមុខ ខ្ញុំខ្លាចដែរ ព្រោះអីខ្ញុំតែប្រកែកអ៊ីចឹងក៏ចេះតែថាប្រកែកអ៊ីចឹងទៅ ប៉ុន្តែទៅចេះតែនៅតែទៅអ៊ីចឹង។ បើថា ឲ្យប្រកែកពេញធឹង ខ្ញុំអត់ហ៊ានប្រកែកទេ ព្រោះអីមួយជំនាន់ហ្នឹង ដឹងស្រាប់ហើយ តែប្រកែកអត់បានអ៊ីចឹងតែម្តង។

**ស៖** តែនៅក្នុងកំណត់ហេតុយកចម្លើយរបស់លោកស្រីហ្នឹង លោកស្រីបានឆ្លើយថា លោកស្រីប្រកែក ហើយក្រោយពីលោកស្រីប្រកែក គេក៏បញ្ជូនលោកស្រីទៅធ្វើការនៅខាងលើ គឺគេបញ្ជូនទៅធ្វើការនៅព្រែកជីក។ អ៊ីចឹងតើ រំឭកការចងចាំរបស់លោកស្រីទេថា លោកស្រីធ្លាប់បានប្រកែក ហើយគេបានបញ្ជូនលោកស្រីទៅធ្វើការនៅព្រែកជីក?

[០៩:៥៣:៣៤]

**ឆ៖** ដូចខ្ញុំនិយាយអំមិញអ៊ីចឹង ខ្ញុំថា ព្រោះអីខ្ញុំវាមានរោគផង ខ្ញុំបានភ្លេចខ្លះអីខ្លះ ក៏ខ្ញុំអត់បានចងចាំ។ ខ្ញុំចងចាំតែកន្លែងណាដែលថា ខ្លួនខ្ញុំកំសត់ខ្លាំង អួសប្ដីខ្ញុំទៅវៃចូល ដូចថាអ៊ីចឹង អួសទាញអ៊ីចឹង ខ្ញុំនឹកឃើញតែប៉ុណ្ណឹង។ ដល់ថា វែងពេកអ៊ីចឹង ខ្ញុំអត់បានចាំផង ព្រោះអីខ្ញុំវា១៧ ឈឺឡើងកោរត្រងោល អត់មានបាយហូបទេ មានតែបបរទេ។

**ស៖** បាទ ដើម្បីរំឭកការចងចាំលោកស្រី ខ្ញុំសូមដកស្រង់ឯកសារដដែលគឺ E3/9790 សំណួរចម្លើយទី៩៧ របស់លោកស្រី។ លោកស្រីបានឆ្លើយថា៖ "ចាស គេបានបង្ខំខ្ញុំ ដំបូងខ្ញុំប្រកែក ប៉ុន្តែក្រោយមកយូរៗទៅ មិត្តភក្តិរបស់ខ្ញុំចេះតែអង្វរឲ្យខ្ញុំរៀបការ ហើយខ្ញុំចេះតែភ័យខ្លាចអំពីសុវត្ថិភាពខ្ញុំនិងកូនខ្ញុំ។ ដូច្នេះហើយទើបខ្ញុំយល់ព្រមរៀបការ។" អ៊ីចឹង តើលោកស្រីចងចាំទេថា ការយល់ព្រមរៀបការរបស់លោកស្រីហ្នឹង តាមការអង្វររបស់មិត្តភក្តិលោកស្រី?

**ឆ៖** បានអង្វរខ្ញុំអ៊ីចឹងមែនថា "មិត្តចាត អើយ មិត្តឯង អ្អែងយកទៅអើយ កុំឲ្យតថ្លៃអី វរៗខ្លាចណាស់ យើងមិនដឹងទៅមុខទៀត ដឹងយ៉ាងម៉េចទេ។ ណាមួយអ្អែងមានកូនផង ចេះតែយកទៅ កុំឲ្យធាក់ជ្រែងអ៊ីចឹង តថ្លៃអ៊ីចឹង មិនបានទេ មិត្តចាត អ្អែងយកទៅ។" មិត្តភក្តិខ្ញុំក៏លួងលោម និយាយអង្វរខ្ញុំថា អ៊ីចឹងអញមិនដឹងធ្វើម៉េចទេ អ្នា យកតាមអ្អែង ក៏តែយកទៅ។

**ស៖** អ៊ីចឹងលោកស្រីសម្រេចចិត្តរៀបការប្ដីទី២ ដោយមានការអង្វររបស់មិត្តភក្តិលោកស្រី តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ត្រឹមត្រូវ។

[០៩:៥៥:៣៤]

**ស៖** តើមិត្តភក្តិរបស់លោកស្រីហ្នឹងគាត់ឈ្មោះអីដែរ?

**ឆ៖** មិត្តភក្តិខ្ញុំវាច្រើន ឈ្មោះ បងរ៉ម ក៏មាន, ឈ្មោះ បងម៉ាក់ ក៏មាន, ឈ្មោះ មិត្តរីម នោះក៏មាន, ឈ្មោះ មិត្តប៉ាត ក៏មាន។

**ស៖** មិត្តភក្តិដែលអង្វរកលោកស្រីហ្នឹង អ្នកណាមួយដែរ?

**ឆ៖** ខ្ញុំស្ដាប់អត់បាននិយាយអំមិញ។

**ស៖** បាទ ខ្ញុំចង់សួរថា មិត្តភក្តិដែលលោកស្រីថា ដែលជាអ្នកអង្វរកលោកស្រីឲ្យរៀបការទៅហ្នឹង តើគាត់ឈ្មោះអីដែរ?

**ឆ៖** ឈ្មោះ មិត្តរីម។

**លោក លីវ សុវណ្ណា៖**

បាទ សូមអរគុណលោកស្រី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយចុងក្រោយប្រគល់វេទិកាជូនទៅមេធាវីការពារក្ដីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** មានសំណួរខ្លីមួយ ទាក់ទងទៅនឹងពេលវេលាដែលលោកស្រីរៀបការលើកទី២។ នៅពេលសវនាការម្សិលមិញនេះ អ្នកស្រីថា ក្រោយពីគេយកប្ដីអ្នកស្រីបានបួនប្រាំថ្ងៃ អ្នកស្រីក៏ត្រូវគេឲ្យរៀបការជាលើកទី២ទៀត។ អ៊ីចឹងខ្ញុំចង់សួរថា តើរយៈពេលនេះ បួនប្រាំថ្ងៃ ឬមួយក៏មានរយៈពេលខុសពីនេះ?

[០៩:៥៧:២៥]

**លោកស្រី ង៉ែត ចាត៖**

**ឆ៖** បួនប្រាំថ្ងៃ យកទៅសម្លាប់ ពួកខ្មែរក្រោមហ្នឹងប្រមូលយកទៅអស់អ៊ីចឹងទៅ បានបួនប្រាំថ្ងៃ មិនទាន់នឹងបាត់យំស្រួលបួលផង ក៏យកយើងទៅរៀបគ្រួសារអ៊ីចឹងទៅ។

**ស៖** បាទ ប៉ុន្តែនៅក្នុងឯកសារ E3/6451 អ្នកស្រីត្រង់ទំព័រខ្មែរ 00546324 ខ្ញុំអត់បានរកជាភាសាអង់គ្លេសទេ។ ខ្ញុំ--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ចំពោះ ERN យើងអត់បានទទួលទេ សូមលោកបញ្ជាក់ឡើងវិញ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមបញ្ជាក់ឡើងវិញ 00546324 ជាភាសាខ្មែរ ហើយចាំរកភាសាអង់គ្លេស និងបារាំងតាមក្រោយ។ ខ្ញុំសូមដកស្រង់៖ "ក្រោយពេលវាសម្លាប់ប្ដីរបស់ខ្ញុំបាន២០ថ្ងៃគត់ សហករណ៍បានបង្ខំខ្ញុំឲ្យការប្ដីថ្មីមួយទៀត។" សូមចប់ការដកស្រង់។ លោកស្រីចាំបានទេ នេះជាសម្ដីអ្នកស្រីទេ ដែលនៅក្នុងឯកសាររបស់អ្នកស្រី អ្នកស្រីថា២០ថ្ងៃ ប៉ុន្តែនៅពេលដែលអ្នកស្រីឆ្លើយពីម្សិលមិញ ហើយនិងអម្បាញ់មិញនេះ ថាបួនប្រាំថ្ងៃ។ អ៊ីចឹងហេតុអ្វីបានជាមានភាពខុសគ្នាបែបនេះ?

01376782



[០៩:៥៩:១៣]

**លោកស្រី ង៉ែត ចាត៖**

**ឆ៖** ព្រោះអីកាលនោះ ខ្ញុំក៏វាមិនបានកត់ដែរ ខ្ញុំដូចថា បើនាប់ពេក ខ្ញុំស្មាន។ ខ្ញុំស្មានៗក្នុងចិត្ត ថា ប្រហែលជាបួន ប្រាំ ប្រាំមួយថ្ងៃអ៊ីចឹង ព្រោះអីវាទើបតែយកទៅស្លាប់ យកទៅសម្លាប់ហ្នឹង អត់ទាន់បាន និយាយទៅអត់ទាន់បាន អត់ទាន់ភ្លេចត្រចៀកផង រៀបគ្រួសារឲ្យខ្ញុំហើយ។ ខ្ញុំក៏អត់បានកត់ថ្ងៃខែ អ៊ីចឹងខ្ញុំស្មានក្នុងចិត្តខ្ញុំ។

**ស៖** បាទ អរគុណ។ អ៊ីចឹងមានន័យថា អ្នកស្រីមិនបានចាំច្បាស់អំពីពេលវេលាពិតប្រាកដទេ តើអ៊ីចឹងទេ?

**ឆ៖** ព្រោះអីខ្ញុំអត់បានចាំច្បាស់ទេ ព្រោះអីខ្ញុំវារវល់តែខំធ្វើការងារផង ណាមួយឈឺផង អីផង អត់សូវមានកម្លាំង ខ្ញុំអត់មានអារម្មណ៍ថា ព្រោះអីខ្ញុំចេះតែថា បានប្រហែលបីបួនប្រាំថ្ងៃអ៊ីចឹងចុះ ខ្ញុំថា អ៊ីចឹង។ ពិតប្រាកដតែម្ដង ព្រោះអីវាយចោល--

**ស៖** បាទ--

**ឆ៖** យកប្ដីខ្ញុំទៅដើមខែ៨ មិនទាន់ដឹង ៗបានប៉ុន្មានថ្ងៃផង យកខ្ញុំទៅរៀបគ្រួសារទៀតហើយ។

**ស៖** បាទ ប៉ុន្តែមុននេះបន្តិច អ្នកស្រីបានឆ្លើយជាមួយនឹងលោកមេធាវីរបស់លោក នួន ជា ថា លោកស្រីបានប្រកែក ហើយមានរយៈពេលមួយនោះ គឺមិត្តភក្តិរបស់អ្នកស្រីបាននិយាយលួងលោមអ្នកស្រីទៀត ថាឲ្យរៀបការទៅ។ អ៊ីចឹងបានន័យថា វាមានរយៈពេលដែលអ្នកស្រីដកឃ្លា បន្ទាប់ពីការជូនដំណឹងថា ឲ្យរៀបការ និងរយៈពេលដែលអ្នកស្រីសម្រេចព្រមរៀបការ។ តើអ៊ីចឹងទេ?

[១០:០១:០៦]

**ឆ៖** ខ្ញុំក៏មិនបានចាំច្បាស់ដែរ ខ្ញុំបានភ្លេចខ្លះហើយ ព្រោះអីវាវីវក់ខួរក្បាលខ្ញុំ វាអារម្មណ៍ខ្ញុំខ្ចួលខ្ចាញ់ ដិតដើមទ្រូងខ្ញុំហ្នឹង វាបុកអស់ហើយ ញ័រអស់ហើយ ខ្ញុំគ្មានបានថា គិតខែគិតថ្ងៃទេ ប៉ុន្តែខ្ញុំបានតែម្ដងៗអ៊ីចឹង។

**លោក គង់ សំអុន៖**

សូមអរគុណ។ លោកប្រធាន អម្បាញ់ខ្ញុំថា ខ្ញុំនឹងជម្រាបជូនពីលេខ ERN ជាភាសាបរទេស ប៉ុន្តែអត់មានឯកសារជាភាសាបរទេសទេ ដូច្នេះអត់មានលេខ ERN ហ្នឹងទេ មានតែភាសាខ្មែរ។ បាទ សូមអរគុណ។ ខ្ញុំអស់សំណួរហើយ លោកប្រធាន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរខ្លី<ពីរបីប៉ុណ្ណោះ>។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំសូមសួរលោកស្រីបំភ្លឺបន្តិច។ អម្បាញ់មិញលោកស្រីបាននិយាយថានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកស្រីជាប្រធាន ជាមេកង។ អ៊ីចឹងខ្ញុំសួរលោកស្រីថា តើអ្នកណាជាអ្នកផ្ដល់មុខតំណែងនេះឲ្យលោកស្រី? ហើយអ្នកណាជាមេផ្ទាល់របស់លោកស្រី នៅពេលដែលលោកស្រីធ្វើជាមេកងនេះ?

[១០:០២:២៣]

**លោកស្រី ង៉ែត ចាត៖**

**ឆ៖** ខ្ញុំអត់បានធ្វើមេកងទេ គេឲ្យខ្ញុំយកធ្វើមេពួក។ មេពួកហ្នឹង វាតូចជាងមេកងឆ្ងាយណាស់។ គេសម្រាប់ថា ដូចថាទៅ មួយពួក មួយពួកអ៊ីចឹង យកទៅទាំងអស់គ្នាអ៊ីចឹងតែម្ដង។ គេឲ្យខ្ញុំធ្វើមេពួកព្រោះអីខ្ញុំលក្ខណៈ១៧ គឺអត់បានធ្វើមេកងទេ ដូចខ្ញុំជម្រាបអ៊ីចឹង។

**ស៖** ខ្ញុំសូមអភ័យទោស ដែលខ្ញុំយល់ខុសអម្បាញ់មិញ។ អ៊ីចឹងអ្នកណាជាអ្នកឲ្យលោកស្រីធ្វើជាមេពួកនោះ? ហើយអ្នកណាមេផ្ទាល់របស់លោកស្រីនៅពេលនោះ?

**ឆ៖** ទៅនៅឯហ្នឹង ខ្ញុំអត់បានចាំឈ្មោះគេ ខ្ញុំភ្លេចអស់ហើយ ខ្ញុំអត់ដូចថា ខ្ញុំអត់នឹកឃើញអ៊ីចឹងតែម្ដង។ បើថាធ្វើមេពួក ខ្ញុំដឹងធ្វើមេពួកតែម្ដង។ កាលហ្នឹងដឹងអ្នកណា មិត្តណាទេចាត់ខ្ញុំ ខ្ញុំអត់បានចាំ។

**ស៖** សំណួរខ្ញុំ សំណួរមួយទៀត ខ្ញុំសួរលោកស្រីថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងក្រៅពីមេផ្ទាល់របស់លោកស្រី ឬក៏មេឃុំអីនោះ តើលោកស្រីមានដឹងដែរឬទេថាអ្នកណាជាអ្នកដឹកនាំនៅស្រុកលោកស្រី តំបន់លោកស្រីដែរឬទេ? <>តើលោកស្រីមានទំនាក់ទំនងផ្ទាល់ជាមួយនឹងថ្នាក់ដឹកនាំមូលដ្ឋានរបស់លោកស្រីដែរឬទេ?

[១០:០៤:២១]

**ឆ៖** ខ្ញុំស្គាល់តែ ពូម៉ី ហើយ តាស៊ុន ហ្នឹង ឃើញគណៈសមរភូមិ គាត់សម្រាប់តែឡើងប្រជុំអ៊ីចឹងតែម្ដង។ គាត់ប្រជុំ ដូចថា ឲ្យទៅធ្វើការងារអីប្ដេជ្ញាចិត្តអី ឲ្យសម្រេចផែនការ ដាក់ការងារអីឲ្យសម្រេច

ផែនការអ៊ីចឹងតែម្តង។ ចំណាំតែឃើញ ពូម៉ី ហ្នឹងគាត់អ្នកឡើងប្រជុំ ញឹកញាប់ជាងគេ។

**សៈ** ដើម្បីឲ្យច្បាស់ ក្រៅពីបុគ្គលទាំងពីរនាក់ហ្នឹង លោកស្រីមិនស្គាល់អ្នកថ្នាក់ដឹកនាំដែលស្ថិតនៅថ្នាក់លើហ្នឹងទៀតទេ តើអ៊ីចឹងមែនទេ?

**ឆៈ** ខ្ញុំអត់សូវបានស្គាល់ផង។

**សៈ** ពេលដែលលោកស្រីប្រើពាក្យ "ខ្មែរក្រហម" តើលោកស្រីសំដៅទៅលើអ្នកណាដែរ? តើលោកស្រីសំដៅទៅលើពីរនាក់ហ្នឹង ឬក៏លោកស្រីសំដៅទៅលើបុគ្គលផ្សេងទៀតដែរ?

**ឆៈ** ខ្ញុំឃើញតែ ពូស៊ុន ហ្នឹង ហើយនិង ពូម៉ី ហ្នឹងគណៈសមរភូមិហ្នឹង ហើយបើមេកងតូចនោះ បងញឹង ហ្នឹងខ្ញុំ ហ្នឹងមេកងក្តាប់ខ្ញុំហ្នឹងតែម្តង។ បើធំៗហ្នឹង ឃើញពីរនាក់ហ្នឹង ពូស៊ុន, ពូម៉ី ហ្នឹងគេធំជាងគេតែម្តង។ ឃើញដើរតាមសមរភូមិរហូតអ៊ីចឹង ក្នុងខ្ទារទទឹងហ្នឹង។

**សៈ** សំណួរចុងក្រោយរបស់ខ្ញុំ។ តើប្រធានកងនោះ លោកស្រីចាត់ទុកថាប្រធានកងហ្នឹងជាខ្មែរក្រហមដែរឬទេ?

**ឆៈ** ខ្ញុំអត់ដឹងខ្មែរអីទេ ព្រោះគាត់ធ្វើមេកងខ្ញុំអ៊ីចឹង ខ្ញុំដឹងគាត់ថាខ្មែរអី ខ្មែរអី ខ្ញុំអត់ដឹងទេ ដូចតែខ្ញុំអ៊ីចឹងដែរ បើគាត់ធ្វើការដូចតែខ្ញុំអ៊ីចឹងដែរ ដូចថាត្រង់ណាអ៊ីចឹង គាត់បញ្ជាយើងទៅៗ ប៉ុន្តែដល់ថាត្រង់គាត់ខ្មែរអី ខ្មែរអី ខ្ញុំអត់ដឹងទេ។

**កញ្ញា អង់តា ហ្គីសសេៈ**

<> ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

[១០:០៦:៥៩]

**ប្រធានអង្គជំនុំៈ**

បាទ អរគុណ។ ហើយ ង៉ែត ចាត ហើយចុងក្រោយនេះមានអីថ្លែងរៀបរាប់សង្ខេបចុងក្រោយដែរទេ?

**លោកស្រី ង៉ែត ចាតៈ**

ខ្ញុំគ្រាន់រៀបរាប់ថា ដូចប្តីខ្ញុំដែលខ្មែរក្រោមអ៊ីចឹង ដូចអត់មានទោសមានអី យកគ្នាទៅលត់ដំ រែកកណ្តាប់តាំងពីប្រឡាយព្រែកជីកមកដល់កំប្រាក់កូនអ៊ីចឹង។ ខំសម្រេចផែនការហើយ ហេតុអីបានយកប្តីខ្ញុំ អូសដៃអូសជើង យកគ្នាទៅសម្លាប់អ៊ីចឹង ខ្ញុំគួរឲ្យឈឺចាប់ណាស់ ខ្ញុំអាណិតប្តីខ្ញុំណាស់ លោកអើយលោក។ រកអីប្រៀបពុំបានទេ ញាប់ញ័រអស់ហើយ។ ខ្ញុំឃើញ ដេកទៅពីយប់មិញ ក៏នឹកឃើញទៅប្តីខ្ញុំ

នៅពីមុខ ដូចនៅពីមុខខ្ញុំអ៊ីចឹង។ ដល់ខ្ញុំមកឡើងសាលាក្តីអ៊ីចឹង ខ្ញុំនឹកឃើញដូចស្រស់ៗនៅនឹងភ្នែក ឃើញដូចគាត់នៅរស់។ បាន ខ្ញុំអស់យោបល់ហើយ ខ្ញុំមានតែប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី។ ឥឡូវនេះសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្មរបស់លោកស្រីបានដល់ទីបញ្ចប់ហើយ។ ហើយអង្គជំនុំជម្រះអរគុណលោកស្រី ហើយជូនពរលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន។

ឥឡូវនេះលោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណា ដែលលោកស្រីមានបំណងចង់ទៅបានហើយ។ ហើយអង្គជំនុំជម្រះអរគុណលោក ប៊ុន លឹមហួរ ហើយសវនាការស្តាប់សក្ខីកម្ម -- សេចក្តីថ្លែងរៀបរាប់ទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានចប់ហើយ អ៊ីចឹងលោកអាចសម្រាកបានហើយ។

ហើយឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ និងម្ភៃប្រាំនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:០៨ នាទី ដល់ម៉ោង ១០:២៧ នាទី)*

[១០:២៧:៥១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីចុងក្រោយ ហើយរួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រី ដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអី?

**លោកស្រី សយ ណារឿន៖**

**ឆ៖** ចាស នាងខ្ញុំឈ្មោះ សយ ណារឿន។

**ស៖** សយ ណារឿន ឬក៏ សយ សារឿន?

**ឆ៖** សយ ណារឿន។ សយ ណារឿន។

**ស៖** បាទ អរគុណលោកស្រី សយ ណារឿន។ ហើយលោកស្រីកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ខ្ញុំកើតនៅថ្ងៃទី០៧ ខែ៨ ឆ្នាំ១៩៥៥។

**ស៖** បាទ អរគុណ។ ហើយទីកន្លែងកំណើតរបស់លោកស្រីកើតនៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំកើតនៅភូមិស្វាយទាប ឃុំស្វាយទាប ស្រុកចំការលើ។ ពីមុន កាលពីសង្គមកំណើតរបស់ខ្ញុំ គេហៅ ស្រុកបុសចេកព្រៃ។

[១០:៣០:២១]

**ស៖** ចុះទីលំនៅសព្វថ្ងៃ តើលោកស្រីរស់នៅទីកន្លែងណា?

**ឆ៖** ទីលំនៅបច្ចុប្បន្ន សព្វថ្ងៃខ្ញុំនៅភូមិប្រម៉ាត់ដី ឃុំស្វាយទាប ស្រុកចំការលើ។

**ស៖** អរគុណ។ ហើយតើលោកស្រីប្រកបមុខរបរអ្វីដែរ សព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំធ្វើស្រែចម្ការបន្តិចបន្តួច និងបច្ចុប្បន្នកាលនេះ ខ្ញុំមើលចៅ។

**ស៖** ឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកស្រីឈ្មោះអី?

**ឆ៖** ឪពុកបង្កើតនាងខ្ញុំឈ្មោះ សយ ឆាង។ ម្ដាយឈ្មោះ ស្នួង រ៉េន។

**ស៖** ចុះប្ដីរបស់លោកស្រីឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ប្ដីនាងខ្ញុំឈ្មោះ ស្នួង ភីន។ នាងខ្ញុំមានកូនប្រាំបួននាក់ ប៉ុន្តែស្លាប់អស់ពីរ នៅប្រាំពីរនាក់។

**ប្រធានអង្គជំនុំ៖**

នៅពេលនេះ គឺលោកស្រីអញ្ជើញមកថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម បានន័យថា ផលអន្តរាយទាំងឡាយដែលប៉ះពាល់លោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយនាំឱ្យលោកស្រីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប៉ុន្តែដោយនីតិវិធីសំណើសុំរបស់ខាងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំតាំងសំណួរពាក់ព័ន្ធនឹងបញ្ហានេះ។ ហើយទោះបីយ៉ាងនេះក្ដី ក៏អង្គជំនុំជម្រះនៅផ្ដល់លទ្ធភាពជូនលោកស្រីចុងក្រោយថ្លែងរៀបរាប់ដោយខ្លួនឯងផ្ទាល់ ជាការបិទបញ្ចប់នូវសេចក្ដីរៀបរាប់ទុក្ខវេទនារបស់លោកស្រីជាចុងក្រោយដែរ បើសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។

ហើយតទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិការជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ពាក់ព័ន្ធជាមួយនឹងបញ្ហាដែលបានកំណត់

01376787



ធ្វើសវនាការនាពេលនេះ។ សូមអញ្ជើញ!

[១០:៣២:២៧]

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស អរគុណលោកប្រធាន។ សូមគោរពអង្គសវនាការទាំងមូល។ ចាស នាងខ្ញុំឈ្មោះ ស៊ីន សុវ៉ន ជាមេធាវីតំណាងឱ្យដើមបណ្ដឹង។ ចាស នាងខ្ញុំសូមសួរសំណួរមួយចំនួនទៅដើមបណ្ដឹង។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** សូមជម្រាបសួរអ្នកស្រីដើមបណ្ដឹង។ ចាស ខ្ញុំសូមសួរសំណួរមួយចំនួនពាក់ព័ន្ធនឹងការឃឺចាប់ ដែលលោកស្រីបានទទួលរងនៅសម័យកម្ពុជាប្រជាធិបតេយ្យ។ ចាស សំណួរទី១ ខ្ញុំចង់ជម្រាបសួរអ្នកស្រីថា នៅថ្ងៃ១៧ មេសា ១៩៧៥ តើគេជម្លៀសអ្នកស្រី និងក្រុមគ្រួសារអ្នកស្រី ទៅភូមិឃុំស្រុកខេត្តណា? ហើយគេឱ្យអ្នកស្រីធ្វើអ្វីខ្លះ?

**លោកស្រី សយ ណារឿន៖**

**ឆ៖** ចាស នៅថ្ងៃទី១៧ មេសា ១៩៧៥ គេបានជម្លៀសនាងខ្ញុំចេញពីភូមិស្វាយទាប ទៅនៅភូមិអូរទឹកត្រជាក់ ឃុំអូរឆ្នូង ស្រុកស-៦២ ខេត្តកំពង់ចាម។

**ស៖** គេឱ្យអ្នកស្រី ហើយក្រុមគ្រួសារអ្នកស្រីរស់នៅជុំគ្នា ហើយគេឱ្យអ្នកស្រីធ្វើអ្វីខ្លះដែរ?

[១០:៣៣:៥០]

**ឆ៖** ក្រោយពីគេជម្លៀសខ្ញុំទៅដល់ព្រៃអូរឆ្នូងនុ៎ងហើយ ភូមិអូរទឹកត្រជាក់ហ្នឹងហើយ គេឱ្យខ្ញុំចាកចេញពីក្រុមគ្រួសារ ដើម្បីទៅកាប់ព្រៃធំៗ រុករាន រើធ្វើជាភូមិ ដើម្បីបង្កើតភូមិថ្មីៗទៀត នៅក្នុងឃុំអូរឆ្នូង។ ឱ្យខ្ញុំចាកចេញពីក្រុមគ្រួសារទៅនៅតាមការដ្ឋាន គេបើកជាការដ្ឋាន នៅក្នុងព្រៃអូរឆ្នូង ហើយនាំគ្នាធ្វើជាកងចល័តទៅប្អូនដប់ម្ភៃនាក់ សាមសិបនាក់ សុទ្ធតែស្រ្តី។ ទៅដល់ព្រៃអូរឆ្នូង ខ្ញុំមានការលំបាកណាស់។ ទៅដល់ក្នុងព្រៃ ហើយខ្ញុំជាស្ត្រីឱ្យកាប់ព្រៃកាប់ឈើ រានឆ្ការដើម្បីជារាន ជាភូមិ ហើយមិនមានជាឧបករណ៍អ្វីដែលឱ្យខ្ញុំកាប់ព្រៃនោះ ដោយស្រួលទេ គឺកាប់នឹងកាំបិតផ្គាក់ និងពូថៅ ហើយដើមឈើនៅព្រៃកុង ព្រៃស្រោង គឺធំៗណាស់។ នាងខ្ញុំមានការលំបាក រកអ្វីប្រៀបពុំបានទេ។ តែកន្លែងហូបចុកក៏អ៊ីចឹង កន្លែងស្នាក់នៅក៏អ៊ីចឹងដែរ គឺលំបាក។ កន្លែងស្នាក់នៅគឺពិបាកនឹងរស់នៅ ហើយខ្ញុំជាស្ត្រី មានការដូចជាពេលមករដូវ ពេលខ្លះអ៊ីចឹងទៅ គឺលំបាកអត់មានអ្វីរៀបចំខ្លួនឯងជាស្ត្រីទេ។ ហើយ

បញ្ហាហូបចុកទៀត ក្នុងមួយថ្ងៃបើកអង្ករឲ្យ១០កំប៉ុងចំនួនគ្នាម្ភៃសាមសិបនាក់សម្រាប់មួយថ្ងៃ គឺមួយថ្ងៃមិត្តនារីហ្នឹងយកទៅឲ្យអង្ករ១០កំប៉ុងក្នុងការដ្ឋាន។ ជីវិតរបស់នាងខ្ញុំលំបាក ហៅមហាលំបាករកនិយាយមិនកើតទេ ថ្លែងមិនកើតត្រង់ថា ហេតុអ្វីក៏បានជាប្រើនាងខ្ញុំឲ្យកាប់ឈើធំៗ ហើយមិនឲ្យនាងខ្ញុំហូបឆ្អែត មានតែមួយថ្ងៃអង្ករ១០កំប៉ុងមនុស្សរាប់នាក់មិនអស់ ទីជម្រកក៏ជ្រកមិនបានត្រឹមត្រូវ។ ចាស សូមអស់។

**ស៖** ចាស សូមអរគុណ។ ចាស អ្នកស្រីបានជួបស្ថានការណ៍ដ៏វេទនាហ្នឹង តើអ្នកស្រីមានអារម្មណ៍បែបម៉េចដែរ?

[១០:៣៦:២៤]

**ផ៖** នាងខ្ញុំមានអារម្មណ៍ក្តុកក្តួលនៅក្នុងចិត្តណាស់ ណាមួយបែកពីម៉ែពីឪ គ្រាន់តែជម្លៀសទៅដល់ភ្លាម ឲ្យខ្ញុំចូលកងចល័ត ឲ្យចេញពីម៉ែពីឪ។ មួយទៀតទៅនៅក្នុងព្រៃ ណាខ្លាចសត្វសាហាវនៅក្នុងព្រៃធំ ហើយមនុស្សក៏តិច គ្នាម្ភៃសាមសិបនាក់ព្រៃធំពេក។ ពេលដេកម្តងៗកន្លែងដេកហ្នឹងក៏វាពិបាកណាខ្លាច ណាភ័យបារម្ភក្នុងអារម្មណ៍ខ្ញុំ ក្តុកក្តួល រំជួលរកចង់គាំងដុំៗក៏មានដែរ លោកប្រធាន។

**ស៖** ចាស អរគុណ ចាស អរគុណ។ លោកស្រីរៀបការនៅឆ្នាំណាដែរអ្នកស្រី?

**ផ៖** នាងខ្ញុំរៀបការនៅឆ្នាំ១៩៧៥។

**ស៖** ចាស អរគុណ។ សូមអ្នកស្រីរៀបរាប់ពីការរៀបការនៅសម័យកម្ពុជាប្រជាធិបតេយ្យដែលអ្នកស្រីថា អ្នកស្រីរៀបការឆ្នាំ៧៥ តើមានហេតុការណ៍អ្វីកើតឡើងចំពោះអ្នកស្រី?

**ផ៖** នាងខ្ញុំរៀបការនៅឆ្នាំ៧៥ នាងខ្ញុំនៅតាមការដ្ឋាន នាងខ្ញុំជានារីកងចល័ត។ ថ្ងៃមួយគេបានហៅនាងខ្ញុំឲ្យទៅធ្វើមីទិ្ទង ធ្វើមីទិ្ទងនៅភូមិអូរថ្ម នាងខ្ញុំកំពុងតែលើកទំនប់ គេហៅថា "ទំនប់កុមារ" នៅភូមិវាលទូក។ ហើយនាងខ្ញុំក៏ដើរតាមមេកងហ្នឹងហៅ មកដល់កន្លែងសម្រាក មេកងក៏គាត់ប្រាប់ខ្ញុំថា "មិត្តឯងកុំស្លៀកខោទៅប្រជុំ មិត្តឯងស្លៀកសំពត់ទៅ"។ នាងខ្ញុំក៏បានឡើងទៅកន្លែងសម្រាក ផ្លាស់ខោចេញក៏ស្លៀកសំពត់ បង់កក្រមាពាក់អាវខ្មៅ ស្លៀកសំពត់ខ្មៅ បង់កក្រមាហ្នឹងមកកន្លែងប្រជុំ គេឲ្យប្រជុំ ថាអង្គមីទិ្ទងហ្នឹងលើមកបើកអង្គមីទិ្ទង។ ខ្ញុំក៏ដើរតាមមេកងហ្នឹងមករហូតមកដល់ភូមិអូរថ្ម។

[១០:៣៨:៥១]

មកដល់ភូមិអូរថ្ម នាងខ្ញុំក្រឡេកមើលទៅឃើញមនុស្សច្រើន ខ្ញុំក៏សួរថា សួរមិត្តកងថា គេធ្វើអីច្រើនម្ល៉េះមិត្ត? ថាបន្តិចទៀតមិត្តឯងដឹងហើយ ថ្នាក់លើចុះមកធ្វើអង្គមីទិ្ទង។ នាងខ្ញុំក៏ទៅ ចូលទៅ

ឃើញមិត្តបុរសហ្នឹងអង្គុយមួយជួរ នារីអង្គុយមួយជួរ។ នាងខ្ញុំឆ្ងល់ដែរ តែមិនៗហ៊ានសួរគេទៀតទេ ចេះតែអង្គុយមើលគេឆ្វេងស្តាំ ឆ្វេងស្តាំ បន្ទាប់មកខ្ញុំក្រឡេកឃើញមិត្តនារីម្នាក់នៅភូមិនាងខ្ញុំ ភូមិអូរទឹកត្រជាក់ហ្នឹង។ តែនាងខ្ញុំគ្មានបានទៅទំនាក់ទំនងសួរស្និទ្ធស្នាល សួរនាំអីទេ ព្រោះគេមិនឲ្យយើងនិយាយរកគ្នាទេ គេឲ្យយើងនៅអង្គុយឲ្យស្ងៀម។ ដល់អីចឹងឃើញដែរ ឃើញគ្នាឯងដែរ តែក៏មិនហ៊ានសួរនាំពីលិចពីកើតអីដែរ សុខចិត្តនៅស្ងៀម។ ក្រោយមកទៀត ក៏ថ្នាក់លើគាត់បើកអង្គមីទិ្ទង។ បើអង្គមីទិ្ទងទៅឲ្យពួកខ្ញុំហ្នឹងឡើងប្តេជ្ញាចិត្ត។ ឡើងប្តេជ្ញាចិត្តមួយគូៗ ឡើងមួយគូៗហ្នឹង បានខ្ញុំអង្គុយទៅ ខ្ញុំដឹងថា គេហៅខ្ញុំមករៀបគ្រួសារ ឬម៉េច បានជាគេហៅម្តងមួយគូ ឲ្យចាប់ដៃគ្នាប្តេជ្ញាចិត្តនៅមុខថ្នាក់លើ។ ខ្ញុំមានអារម្មណ៍ភ័យ មានអារម្មណ៍ខ្លាច ក្នុងខ្លួនម្នាក់ឯង ដូចជាចង់គ្រុនញាក់បន្តិច គ្រុនញ័របន្តិចហើយ ញ័រសាច់ត្រជាក់ស្រឹបអស់ហើយ។ ខ្ញុំភ័យពេក មិនដឹងធ្វើម៉េច ចេះតែនៅអង្គុយតែស្ងៀម តែក្នុងខ្លួនហ្នឹងដូចចង់ទៅជាគ្រុនចាញ់ហើយ។ វាពិបាក មើលទៅដូចជាភ័យពេក អត់មានរឿងអីសោះស្រាប់តែគេហៅមកឡើងប្តេជ្ញាចិត្ត ម្តងមួយគូ ម្តងមួយគូ។ ខ្ញុំជាវាមានអារម្មណ៍ថា ភ័យខ្លាចណាស់លោកប្រធាន។

**ស៖** ពេលអ្នកស្រី--

**ប្រធានអង្គជំនុំ៖**

បើកៗក្បាល់មីក្រូហ្វូន!

[១០:៤១:១១]

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** គេហៅអ្នកស្រីមកធ្វើមីទិ្ទង ប៉ុន្តែក្រោយមកអ្នកស្រីដឹងថា អ្នកស្រីត្រូវបានគេឲ្យមករៀបការ។ ពេលអ្នកស្រីរៀបការហ្នឹង តើមានប៉ុន្មានគូដែរ ដែលរៀបការជាមួយអ្នកស្រី? ហើយក្នុងពេលនុ៎ងតើមានឪពុកម្តាយ សាច់ញាតិអ្នកស្រីបានចូលរួមក្នុងពិធីរៀបមង្គលការអ្នកស្រីហ្នឹងដែរឬអត់?

**លោកស្រី សយ ណាវឿន៖**

**ឆ៖** ថ្ងៃ ពេលដែលគេហៅខ្ញុំឡើងប្តេជ្ញាចិត្តនុ៎ង គឺគ្មានឪពុកម្តាយក្រុមគ្រួសារ ញាតិមិត្ត បងប្អូនទេ។ គេហៅតែខ្ញុំនៅតាមការដ្ឋាន ធ្វើម្តេចគាត់ដឹង នៅតែអី គាត់នៅតែក្នុងសហករណ៍។ ដូច្នេះហើយដែលនាងខ្ញុំថា មានការឈឺចាប់ មូលហេតុមកពីនាងខ្ញុំនៅធ្វើការនៅការដ្ឋាន ហៅនាងខ្ញុំមកប្តេជ្ញាចិត្តដើម្បីមានគ្រួសារ។ សួរថា ជីវិតនាងខ្ញុំ ឪពុកម្តាយនាងខ្ញុំ ដែលគាត់ខំចិញ្ចឹមខ្ញុំតាំងពីតូចរហូតមកហើយដល់ពេលខ្ញុំមានគ្រួសារ ហេតុអីក៏ឪពុកម្តាយមិនដឹង? គាត់មិនបានដឹងទេ មិនបានដឹងថា ខ្ញុំហ្នឹង

ទៅរៀបការទេ ព្រោះខ្ញុំទៅធ្វើការទៅតាមការដ្ឋាន។ ដល់ពេល--

**ស៖** ចាស អរគុណ។ ប៉ុន្មានគូដែរអ្នកស្រី?

**ឆ៖** ចាស ៦០គូ។ ភូមិនាងខ្ញុំគឺពីរគូ រួមទាំងស្រុកគឺ៦០គូ។

**ស៖** ចាស អរគុណ។ តើអ្នកស្រីមានអារម្មណ៍បែបណាដែរ ដោយការរៀបការរបស់អ្នកស្រីមិនមានឪពុកម្ដាយ ឬសាច់ញាតិបងប្អូនអ្នកស្រីបានចូលរួមក្នុងពិធីនុ៎ង?

[១០:៤៣:០៤]

**ឆ៖** នាងខ្ញុំមានអារម្មណ៍ឈឺចាប់ណាស់ ឈឺចាប់ត្រង់ថា ហេតុអីក៏ចាប់មនុស្សបញ្ជូកដូចជាសត្វគោ ចាប់យកទៅទឹម ដោយមិនបានស្គាល់មុខ មិនបានស្គាល់គ្នាថា បុរសជាប្ដីនោះ មានចរិតបែបណា មានវង្សត្រកូលយ៉ាងម៉េច តើមនុស្សនុ៎ងល្អ ឬអាក្រក់? ដោយមិនបានដឹងជាមុន ហើយក៏មិនបានស្គាល់គ្នាតាំងពីណាណីមក មិនដែលបានស្គាល់គ្នាសោះ មកដល់ពេលហ្នឹង មកចាប់ខ្ញុំទឹមដូចគោ ដូចក្របី ថាខ្ញុំមានអារម្មណ៍ឈឺចាប់ខ្លាំងណាស់ លោកប្រធាន។

**ស៖** ចាស អរគុណ។ ចាស អ្នកស្រីពេញចិត្តនឹងគូរបស់អ្នកស្រីដែលអង្គការគេតម្រូវឲ្យអ្នកស្រីប្ដេជ្ញាចិត្តហ្នឹងទេ?

**ឆ៖** ឲ្យខ្ញុំពេញចិត្តអាម៉េច បើមនុស្សមិនទាំងដែលស្គាល់គ្នាផង។ មនុស្សយើងពេញចិត្តនឹងគ្នារៀបការនឹងគ្នា អាស្រ័យតែយើងបានទាក់ទងគ្នា និយាយរកគ្នា ហ្នឹងបានមានចិត្តស្រលាញ់គ្នា។ តែនេះចាប់ខ្ញុំបញ្ជូកទឹមអ៊ីចឹង តើមានចិត្តឯណានឹងពេញទៅលើបុរសនោះជាប្ដី ខ្ញុំអត់មានពេញទេ។

**ស៖** ចាស អរគុណ។ អ្នកស្រី សូមអ្នកស្រីរៀបរាប់អំពីយប់ដំបូងនៃថ្ងៃរៀបការរបស់អ្នកស្រីក្រោយពេលដែលអ្នកស្រីប្ដេជ្ញាចិត្តហើយ តើអ្នកស្រីយល់ព្រមក្នុងការរួមដំណេកជាមួយប្ដីអ្នកស្រីដែលអង្គការគេតម្រូវឲ្យអ្នកស្រីប្ដេជ្ញាចិត្តហ្នឹងទេ?

[១០:៤៤:៥៧]

**ឆ៖** នាងខ្ញុំសូមរៀបរាប់ពីពេលខ្ញុំ នាងខ្ញុំប្ដេជ្ញាចិត្តរួចហើយ គេបានឲ្យនាងខ្ញុំទៅដេកតាមរោងបន្ទប់ មួយបន្ទប់ៗហ្នឹង គឺមានច្រើនបន្ទប់ គេឲ្យពួកខ្ញុំអ្នកប្ដេជ្ញាចិត្តហ្នឹងទៅសម្រាកនៅក្នុងបន្ទប់រោងតូចៗមួយហ្នឹង។ រោងហ្នឹងបាំងជញ្ជាំងដោយស្បូវ ប្រក់ដោយស្បូវ។ ហើយនាងខ្ញុំ និងប្ដីនាងខ្ញុំហ្នឹង ក៏បានគេឲ្យចូល ឈ្លបគេនាំនាងខ្ញុំទៅ ចូលទៅបន្ទប់តូចៗនៅតាមរោងហ្នឹង។ ក្រោយមកទៀត នាងខ្ញុំអង្គុយត្បោញក្បាលជង្គង់ គាត់ក៏សម្រាកទៅ តែនាងខ្ញុំអង្គុយត្បោញក្បាលជង្គង់។ ស្រាប់តែឮស្បូវសម្រើបជើង

ដើរព្រឹបៗចុះឡើងៗ នាងខ្ញុំភ័យខ្លាច ហែកជញ្ជាំងស្លឹរលបមើល ឃើញកងឈ្លបដើរចុះដើរឡើង ប្រហែលជាប្រាំមួយ ប្រាំពីរនាក់ ដោយយប់ងងឹតនាងខ្ញុំមិនបានរាប់អស់ទេ តែយ៉ាងច្រើន ប្រហែលជាប្រាំមួយនាក់ប៉ុណ្ណោះឯង។ នាងខ្ញុំឃើញកងឈ្លបដើរមកដល់ជិតរោងនាងខ្ញុំ នាងខ្ញុំក៏បិទជញ្ជាំងហ្នឹងទៅ ហើយនាងខ្ញុំក៏ប្រះដេក ខ្លាចលោឈ្លបមកអើតមើលទៅឃើញនាងខ្ញុំអង្គុយ ខ្លាចមានបញ្ហា។ ក្រោយមកទៀត នាងខ្ញុំឮសូរសម្រឹប ដូចជារត់បន្តិច ដូចជាដើរលឿនបន្តិច នាងខ្ញុំក៏ហែកស្លឹរ ជញ្ជាំងស្លឹរមើលទៀត ស្រាប់តែក្រឡេកទៅឃើញបន្ទប់ ប្រហែលជា ចម្ងាយប្រហែលជា៥០ម៉ែត្រពីបន្ទប់របស់នាងខ្ញុំ ក្រឡេកទៅឃើញកងឈ្លបខាងមុខពីរ ខាងក្រោយមិនដឹងជាប៉ុន្មានទេ ច្រើន នាំមួយគូដើរចេញពីរោងសម្រាកហ្នឹងចេញទៅ។ ទៅយូរណាស់ ដល់ពេលកងឈ្លបហ្នឹងជូនមួយគូហ្នឹងចេញពីរោងទៅបាត់ នាងខ្ញុំអង្គុយចាំមើលគឺយូរ ប្រហែលជាកន្លះម៉ោងក្រោយមក បានឃើញពួកឈ្លបត្រឡប់មកវិញ តែអត់ឃើញអ្នកដែលគូប្ដេជ្ញាពីក្បាលព្រលប់ហ្នឹងទេ។ នាងខ្ញុំគិតសន្និដ្ឋានថា អ្នកគូនោះប្រហែលជាមិនចុះសម្រុងគ្នា ឬយ៉ាងម៉េចបានជា គេនាំចេញពីខ្ទមហ្នឹង។ ក្រោយមកទៀត ឈ្លប ពួកឈ្លបនៅតែដើរឈ្លបដដែល។ មិនបានប៉ុន្មាននាទីផង ក៏នាំមួយគូទៅទៀត។ ដល់ត្រង់នេះខ្ញុំមានអារម្មណ៍ថា ជីវិតខ្ញុំថ្ងៃទៅមុខទៀត ខ្ញុំក៏សុខចិត្ត នឹកគិតថា ខ្លួនញ័រទទ្រាក់ដូចកូនសត្វយ៉ាងម៉េចក៏ដោយចុះ ខ្ញុំក៏សុខចិត្តព្រមប្រគល់ខ្លួនឲ្យប្ដីនាងខ្ញុំនៅយប់ទី១ ដោយសារនាងខ្ញុំឃើញឈ្លបបណ្ដើរចេញពីរោង ដល់ទៅពីរគូ នាងខ្ញុំភ័យណាស់ នាងខ្ញុំមានអារម្មណ៍ខ្លាច ដោយនាងខ្ញុំបាត់--។

**ស៖** ចាស អរគុណ។ ចាស អរគុណអ្នកស្រី។ ចាស តើអ្នកស្រីមានអារម្មណ៍ក្ដុកក្ដួលដូចម្ដេចដែរ នៅពេលអ្នកស្រីរួមដំណេកដំបូងជាមួយប្ដីអ្នកស្រីដែលអ្នកស្រីមិនពេញចិត្តនោះ?

[១០:៤៨:២៥]

**ឆ៖** នាងខ្ញុំមានអារម្មណ៍ញ័រ មានអារម្មណ៍ចុកណែនក្នុងខ្លួនដើមទ្រូងរបស់ខ្ញុំ ចង់គាំងបេះដូងដុំៗ ដោយមួយជីវិតខ្ញុំ តាំងពីខ្ញុំដឹងក្ដីមក ខ្ញុំពុំដែលជួបប្រទះ ខ្លួនខ្ញុំជាស្ត្រីខ្មែរមួយរូប អ្វីៗក៏វាមិនសំខាន់ដល់ស្មើនឹងខ្លួនរបស់នាងខ្ញុំដែរ។ តែនាងខ្ញុំសុខចិត្តញ័ររញាក់ ដូចកូនសត្វយ៉ាងណាក៏ដោយ ក៏នាងខ្ញុំសុខចិត្តថានៅស្ងៀម ដើម្បីឲ្យប្ដីបម្រើទៅតាមចំណង់ចំណូលចិត្តរបស់គាត់រួមភេទ ព្រោះគាត់បានប្ដេជ្ញាចិត្តនៅមុខអង្គការ។ នាងខ្ញុំមានអារម្មណ៍ឈឺចាប់ណាស់ សូមឲ្យលោកប្រធានពិចារណា។

**ស៖** ចាស អរគុណ។ អ្នកស្រីក្នុងពេលដែលប្ដេជ្ញាចិត្តនោះ តើមានថ្នាក់ដឹកនាំណាចូលរួមក្នុងពិធីហ្នឹង? ហើយតើថ្នាក់ដឹកនាំនោះ គាត់មានធ្វើសេចក្ដីណែនាំអីខ្លះដល់គូមួយៗ ដែលត្រូវឡើងប្ដេជ្ញាចិត្ត

ហ្នឹង?

**ឆ៖** ចាស មាន។ គណៈតំបន់ និងគណៈស្រុក និងមេឃុំ ប្រធានកងធំ ប្រធានកងតូចច្រើន ក៏ប៉ុន្តែនាងខ្ញុំស្គាល់តែគណៈស្រុក និងប្រធានស-៦២ និងប្រធានកងធំតែប៉ុណ្ណោះ។ គណៈតំបន់ គឺនាងខ្ញុំអត់ដែលស្គាល់ទេ នាងខ្ញុំអត់បានស្គាល់ទេ។ ហើយអង្គការទាំងនោះបានហៅមួយគូៗឡើងប្តេជ្ញាចិត្ត មុននឹងប្តេជ្ញាចិត្ត គេបានថា បើត្រូវធ្វើតាមអង្គការកំណត់ ត្រូវនិយាយតាមអង្គការដាក់ឲ្យ ឲ្យអ្នកទាំងពីរនាក់ប្តេជ្ញាចិត្ត ឲ្យស្រលាញ់គ្នាចាប់ពីពេលនេះតទៅ បង្កបង្កើនផលឲ្យបានច្រើនពីមួយហិកតាប៉ុន្មានតោនទៅប៉ុន្មានតោនតាមកំណត់របស់អង្គការ ឲ្យបង្កបង្កើតជាមនុស្សឲ្យបានច្រើនដោយតម្រូវទៅតាមអង្គការត្រូវការ មនុស្សច្រើនដើម្បីការពារទឹកដី។ មុននឹងខ្ញុំប្តេជ្ញាគឺថ្នាក់លើបានណែនាំឲ្យខ្ញុំនិយាយអ៊ីចឹងនិយាយឲ្យដូចគេថាអ៊ីចឹង។

[១០:៥១:០៦]

**ស៖** ចាស អរគុណអ្នកស្រី។ ចាសដោយសារពេលវេលាខ្លីអ្នកស្រីនិយាយឆ្លើយនូវអ្វីដែលខ្ញុំសួរបានហើយ។ ក្រោយពេលរៀបការហើយ តើអ្នកស្រីនិងប្តីអ្នកស្រីបានរស់នៅជាមួយគ្នាប៉ុន្មានថ្ងៃដែរ?

**ឆ៖** ចាស ៣ថ្ងៃ។

**ស៖** ៣ថ្ងៃៗក្រោយមកទៀត តើប្តីអ្នកស្រី និងអ្នកស្រីបែកគ្នាទៅតាមសហករណ៍ ឬតាមកងរៀងៗខ្លួន ឬក៏ម៉េចដែរ? ហើយប៉ុន្មានថ្ងៃក្រោយមក បានគេឲ្យអ្នកស្រីជួបគ្នាម្តងហ្នឹង?

**ឆ៖** ក្រោយពីជួប -- ឲ្យនៅជួបគ្នា៣ថ្ងៃហើយ គេឲ្យបែកទៅតាមការដ្ឋានរៀងខ្លួន ក្រោយមកមួយអាទិត្យគេឲ្យជួបគ្នាម្តងនៅផ្ទះ នៅផ្ទះម្តាយខ្ញុំ។

**ស៖** ចាស អរគុណ។ ចាស ក្រោយពេលដែលអ្នកស្រីជួបគ្នាហើយ ៣ថ្ងៃនុ៎ង ក្រោយមកទៀតមួយអាទិត្យក្រោយគេឲ្យ អង្គការគេតម្រូវឲ្យប្តីអ្នកស្រីមកជួបអ្នកស្រីនៅផ្ទះម្តាយអ្នកស្រី។ តើក្នុងពេលហ្នឹងអារម្មណ៍ម្តាយអ្នកស្រី ឬក៏បងប្អូនអ្នកស្រី ក្រោយពេលដែលដឹងថាអ្នកស្រីរៀបការហើយ តើគាត់មានអារម្មណ៍ដូចម្តេចដែរអ្នកស្រី?

**ឆ៖** គាត់មានអារម្មណ៍ចុកចាប់នៅក្នុងខ្លួនគាត់ គាត់មានអារម្មណ៍សោកស្តាយ ដោយសារកូនដែលគាត់ខំចិញ្ចឹមហើយ ពេលរៀបការសូម្បីតែខ្លួនគាត់ជាម្តាយឪពុកមិនបានទៅមើលមុខ មើលកូនដែលកូនរៀបការមានគូស្រករ ក៏គាត់នឹកឡើងគាត់ឈឺចាប់ណាស់។ គាត់ទៅជាឈឺអត់បាយក្រហាយទឹក។ គាត់ទទួលយកអត់បានទេ លោកប្រធាន។

[១០:៥៣:០៦]

**ស៖** ចាស អរគុណ។ ចាសក្នុងពេលដែលអ្នកស្រីរួមដំណេកជាមួយប្ដីអ្នកស្រី តើពេលនុំងអ្នកស្រីមានកូនទេ?

**ឆ៖** ចាស មាន។ ខ្ញុំមានកូន ហើយខ្ញុំចាញ់កូន។ ទោះបីខ្ញុំចាញ់កូនធ្វើការទាំងចាញ់កូន ទាំងគ្មានអាហារហូបគ្រប់គ្រាន់ ពេលធម្មតាស្ត្រីយើងដែលមានផ្ទៃពោះគឺនឹកឃ្លាន របស់អ្វីក៏មិនបានហូបចុកដែរ។ ហើយប្រើខ្ញុំឱ្យធ្វើទាំងចាញ់ ឈឺស្គមស្គាំង មើលមិនយល់ ដោយសារខ្ញុំមានកូនចាញ់កូនខ្លាំងពេកក៏ចេះតែធ្វើការរាល់ថ្ងៃ តែប្ដីនៅតាមការដ្ឋានដោយឡែកពីគ្នា។

**ស៖** ចាស អរគុណ។ ចាស ការដែលអ្នកស្រីមានកូន អ្នកស្រីចង់បានខ្លួនឯង ឬក៏មានកូនដោយចៃដន្យ? ហើយអ្នកស្រីយល់ថាក្នុងសម័យនុំង អ្នកស្រីមានកូនវាជាការល្អ ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំមានកូន គឺមិនមែនតាមចិត្តខ្ញុំចង់ចាឱ្យមានទេ តែនេះជាទិសដៅរបស់គេ គេថាត្រូវតែមានកូន ត្រូវតែបង្កើតកូនឱ្យអង្គការ។ ពេលណា នេះខ្ញុំនឹកគិតថាជីវិតកូនខ្ញុំដល់កើតមក មិនដឹងទៅជាយ៉ាងម៉េចទេ។ ខ្ញុំមិនចង់ឱ្យមានទេលោកប្រធាន តែមិនដឹងធ្វើម៉េចទៅតាមធម្មជាតិ។

**ស៖** ចាស អរគុណ។ ចាស អ៊ីចឹងកូនអ្នកស្រី កូនទី១របស់អ្នកស្រី ដែលអ្នកស្រីថាអ្នកស្រីមានទម្ងន់ចាញ់កូននោះ តើកូននុំងរស់រានមានជីវិតរហូតដល់បច្ចុប្បន្ន ឬក៏យ៉ាងម៉េចដែរអ្នកស្រី?

[១០:៥៥:១៤]

**ឆ៖** កូនខ្ញុំមិនបានរស់រានមានជីវិតទេ លោកប្រធាន។ ខ្ញុំពពោះកូនបាន៦ខែ នៅក្នុងពោះ៦ខែ ខ្ញុំកើតជំងឺគ្រុនចាញ់ គ្មានថ្នាំសង្កូវ គ្មានអ្វីព្យាបាល គ្មានអ្វីពិនិត្យសុខភាពកូនទេ។ កូន ដល់ពេលខ្ញុំពពោះ៩ខែ ១០ថ្ងៃ កូនខ្ញុំកើតមក កូនខ្ញុំកើតបានស្លាប់។ កូនខ្ញុំទី១ស្លាប់ ដោយសារជំនាន់ដ៏ខ្មៅងងឹត កូនខ្ញុំស្លាប់ ខ្ញុំមិនបានឃើញមុខកូនខ្ញុំសូម្បីតែបន្តិច ដោយសារអ្វី ដោយសារខ្ញុំគ្រុនចាញ់ គ្មានថ្នាំសង្កូវ ដើម្បីព្យាបាលជីវិតកូនខ្ញុំ ទារកដែលនៅក្នុងផ្ទៃទេ មានតែសុំថ្នាំគេ គេឱ្យតែថ្នាំអាចម៍ទន្សាយយកមកលេប។ ជីវិតកូនខ្ញុំកើតមក ខ្ញុំមិនបានឃើញមុខកូនសូម្បីតែបន្តិច មិនដឹងជាកូនខ្ញុំស្លាប់ពីថ្មើរណា ទៅថ្មើរណាទេ។ ខ្ញុំឈឺចាប់ណាស់ លោកប្រធាន ដោយមូលហេតុថា ថ្វីត្បិតតែខ្ញុំមិនចង់បានមែន តែទឹកចិត្តជាម្ដាយចង់កាលណាកូនមានហើយ អាណិតស្រឡាញ់កូន ទីបញ្ចប់គឺខ្ញុំមិនបានឃើញមុខកូនខ្ញុំសូម្បីតែបន្តិច។ នេះហើយ ដែលជាភាពខ្ញុំឈឺចាប់ណាស់ នៅក្នុងចិត្តខ្ញុំ ដែលខ្ញុំមិនអាចបំភ្លេចបានទេ លោកប្រធាន។

*(ដើមបណ្ដឹងរដ្ឋប្បវេណីយំ)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ចាស អរគុណ។ ចាស ដោយភាពឈឺចាប់ដែលអ្នកស្រីបាត់បង់កូន ចុះបន្ទាប់ពីអ្នកស្រីបាត់បង់កូននុំងហើយ តើពេលដែលអ្នកស្រីឆ្លងទន្លេរួចហើយ អ្នកស្រីបាត់បង់កូនហ្នឹងហើយ តើអ្នកស្រីបាននៅសម្រាកប៉ុន្មានខែដែរ បានគេ អង្គការគេឲ្យអ្នកស្រីទៅធ្វើការនៅតាមការដ្ឋាននុំង?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់! កុំអាលទាន់!

ឲ្យគាត់ផ្អាកបន្តិចសិនទៅ ឬគាត់ធូរអារម្មណ៍បន្តិចណ៎ា។

*(សម្រាករយៈពេលខ្លី)*

សួរៗសំណួរចុងក្រោយសាជាថ្មី ទំនងមិនចាំសំណួរទេ។

[១០:៥៨:០៥]

**សួរដោយលោកស្រី ស៊ីន សុវ៉ាន៖**

**ស៖** អរគុណលោកប្រធាន។ ចាស ក្រោយពេលដែលអ្នកស្រីសម្រាលកូនហើយ កូនអ្នកស្រីបានស្លាប់ តើពេលនុំង អ្នកស្រីបានសម្រាក ដោយអ្នកស្រីសរសៃខ្ចី អង្គការគេឲ្យអ្នកស្រីសម្រាកបានប៉ុន្មានខែដែរ បានគេឲ្យអ្នកស្រីទៅធ្វើការនៅតាមការដ្ឋានវិញហ្នឹង?

**លោកស្រី សយ ណារឿន៖**

**ឆ៖** ចាស គេឲ្យខ្ញុំសម្រាក តែមិនមែនបានសម្រាកនៅផ្ទះទេ គេឲ្យសម្រាកបាន១អាទិត្យ តែគេឲ្យខ្ញុំសម្រាកនៅរោងសិប្បកម្ម យាយៗធ្វើសិប្បកម្មនៅក្នុងរោងបាយ អ្នកគ្រូ។

**ស៖** អរគុណ។ ចាស ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង អ្នកស្រីមានតែកូនមួយដែលកើតមកនុំងស្លាប់ ឬក៏អ្នកស្រីមានទម្ងន់កូនទៀត?

**ឆ៖** ក្រោយមកកូនច្បងបានស្លាប់ទៅ នាងខ្ញុំមានទម្ងន់កូនមួយទៀត កើតនៅឆ្នាំ៧៧ រស់នៅទល់សព្វថ្ងៃ។

**ស៖** ចាស អរគុណ។ តើសុខភាពកូននុំងតាំងពីកើតមក រហូតដល់បច្ចុប្បន្នហ្នឹង មានសុខភាពល្អធម្មតាដូចគេ ដូចឯង ឬក៏យ៉ាងម៉េចដែរ អ្នកស្រី?

[១០:៥៩:២៩]

**ឆ៖** កូនខ្ញុំទី២ កើតនៅឆ្នាំ៧៧ គ្មាន -- សុខភាពគ្នាសព្វថ្ងៃមិនបរិបូរទេ ស្គមស្គាំង មូលហេតុដែលគ្នាកើតមកបានប៉ុន្មានខែ ខ្ញុំទៅដើរចោលធ្វើការតាមការដ្ឋាន អត់បានបៅ អត់បានអីទេ។ កូននៅនឹង

យាយៗសិប្បកម្ម។ ពេលយប់ម៉ោងដប់មួយកន្លះយប់ ឬម៉ោងដប់ពីរ ទើបមកដល់ផ្ទះ បានឲ្យកូនបៅ។ ដូច្នោះហើយ កូនខ្ញុំទី២ កំសត់ណាស់នៅក្នុងរបបនោះ។ ត្រង់ហ្នឹងហើយដែលខ្ញុំគិតថា មិនចង់ឲ្យមានកូនទេ របបនេះ សាហាវណាស់ តែធ្វើម៉េចជំនាន់នោះគ្មានអ្វីការពារសម្រាប់រូបខ្ញុំទេ។

**សៈ** ចាស។

**ឆៈ** ដូច្នេះហើយបានជាកូនខ្ញុំស្គមស្គាំងគ្មានអ្វីស៊ីចុកទេ។

**សៈ** ចាស អរគុណ។ អ្នកស្រីបានបាត់បង់កូនជាទីស្រឡាញ់ ដែលអ្នកស្រីខំពពោះ៩ខែ១០ថ្ងៃ ពេលកើតមកស្លាប់។ ក្រៅពីការបាត់បង់កូន ដែលស្លាប់ហ្នឹង តើអ្នកស្រីមានបាត់បង់សាច់ញាតិបងប្អូនជាទីស្រឡាញ់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹងដែរឬទេ អ្នកស្រី?

**ឆៈ** ចាស មាន។ មានបងប្អូន ឪពុកមាមួយគ្រួសារ ឪពុកធំមួយគ្រួសារចំនួន១១នាក់ នៅនឹងចម្ការស្វាយចន្ទី។

**សៈ** ចាស អរគុណ។ តើអ្នកស្រីមានអារម្មណ៍ឈឺចាប់បន្ថែម ក្រោយពេលអ្នកស្រីបាត់បង់កូន ហើយអ្នកស្រីបានទទួលព័ត៌មានថា អ្នកស្រីបាត់បង់សាច់ញាតិដែលជាទីស្រឡាញ់ដល់ទៅ១១នាក់ទៀត តើអ្នកស្រីមានអារម្មណ៍ឈឺចាប់ប៉ុនណាដែរអ្នកស្រី?

**ឆៈ** នាងខ្ញុំមានអារម្មណ៍ឈឺចាប់ គ្មានថ្ងៃបំភ្លេចបានរហូតដល់ថ្ងៃស្លាប់។ មិនត្រឹមតែបាត់បង់កូនជាទីស្រឡាញ់ បាត់បង់ទាំងសាច់ញាតិដល់ទៅ១១នាក់ សួរថាអារម្មណ៍នាងខ្ញុំចុកចាប់ប៉ុនណា អារម្មណ៍នាងខ្ញុំឈឺចាប់ណាស់ ដោយសាររបបខ្មៅងងឹត៣ឆ្នាំ៨ខែ២០ថ្ងៃ ធ្វើឲ្យនាងខ្ញុំមានអារម្មណ៍ចងចាំរហូតដល់ថ្ងៃស្លាប់នៃជីវិតនាងខ្ញុំចាស។

[១១:០១:៥៩]

**សៈ** ចាស អរគុណ។ ចាស របបដ៏ខ្មៅងងឹតនេះបានកន្លងផុតជាង៣០ឆ្នាំហើយ រហូតដល់បច្ចុប្បន្នហ្នឹង តើអ្នកស្រីនៅតែនឹកឃើញកូនជាទីស្រឡាញ់របស់អ្នកស្រី និងសាច់ញាតិ១១នាក់ដែលបានបាត់បង់ជីវិតដោយអយុត្តិធម៌នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង ឬក៏ភ្លេចហើយអ្នកស្រី?

**ឆៈ** នាងខ្ញុំមិនអាចបំភ្លេចបានទេ ដោយសារអ្វី? ពេលណានាងខ្ញុំឃើញកូននាងខ្ញុំ កូនទី២ ឲ្យតែឃើញកូននាងខ្ញុំ នាងខ្ញុំអាចរំឭកនូវសេចក្ដីឈឺចាប់កាលពីមុនមក គឺនៅចងចាំនៅជានិច្ច ខ្ញុំមិនភ្លេចទេលោកស្រី។

**ប្រធានអង្គជំនុំៈ**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អស់ៗពេលហើយណ៎ា មេធាវី។

**លោកស្រី ស៊ីន សុវ៉ន៖**

លោកប្រធាន ចាស។ ចាស អរគុណអ្នកស្រីដើមបណ្ដឹង។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

[១១:០៣:១៥]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានពេល១៥នាទី ដើម្បីសួរលោកស្រី ហើយសូមលោកស្រីស្ដាប់សំណួរខ្ញុំ<ដោយប្រុងប្រយ័ត្ន> និងឆ្លើយ<ឲ្យច្បាស់>។ លោកស្រីបាននិយាយថា លោកស្រីមិនស្គាល់ប្ដីលោកស្រីទេ មុនពេលរៀបការ។ អ៊ីចឹងលោកស្រីធ្លាប់ឃើញទេ<?> ហើយ<តើ>គាត់មកពីតំបន់ជាមួយលោកស្រី ឬក៏មកពីតំបន់ណាផ្សេង?

**លោកស្រី សយ ណារឿន៖**

**ឆ៖** ចាស គេទៅពីតំបន់ផ្សេង។

**ស៖** គាត់ជាទាហាន ឬក៏ជាជនស៊ីវិល?

**ឆ៖** គាត់កាលពីមុន ខ្ញុំអត់ដឹងទេ តែដល់ក្រោយមក រៀបការហើយ គាត់បាននិយាយប្រវត្តិប្រាប់ខ្ញុំថា គាត់ពីជំនាន់ខ្មែររំដោះ គឺគាត់ធ្វើយោធា។

**ស៖** <តើ>លោកស្រីដឹងទេថា គាត់ដឹងមុនថាគាត់ត្រូវរៀបការទេ ឬក៏គាត់<ភ្ញាក់ផ្អើលដូចលោកស្រីដែរ>នៅពេលដែលគេរៀបចំពិធីការហ្នឹង<>?

[១១:០៤:៤៤]

**ឆ៖** ចាស គាត់បាននិយាយប្រាប់ខ្ញុំក្រោយមកទៀតហ្នឹង គាត់ថាពេលដែលគេហៅគាត់ទៅប្ដេជ្ញាចិត្ត គឺគាត់អត់បានដឹងដែរ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ក្នុងពេលរៀបការ ពេលដែលលោកស្រីរួមជាមួយនឹង៥៩គូ<ផ្សេង>ទៀត ហើយលោកស្រីដឹងថា ពេលហ្នឹងលោកស្រីត្រូវរៀបការ លោកស្រីមានគិតថា ចង់ប្រកែកមិនព្រមទេ?

**ឆ៖** ចាស ខ្ញុំបានប្រកែកដែរ។ ប្រកែកលើកទី១ មុនគេហៅខ្ញុំទៅប្ដេជ្ញាហ្នឹង គេបានហៅតែខ្ញុំម្នាក់គត់។ គេឲ្យខ្ញុំទៅនៅក្នុងក្រសួងស-៦២។ ទៅដល់ គេឲ្យខ្ញុំ ឈ្មោះ មិត្តយន ប្រធាន ស-៦២ហ្នឹង គាត់ជាប្រធាននៅក្នុងក្រសួងហ្នឹង គាត់ហៅខ្ញុំតែម្នាក់ឯងទៅគត់។ ទៅដល់ គាត់ប្រាប់ខ្ញុំថា សមមិត្តសយ ណារឿន ខ្ញុំហៅមិត្តឯងឲ្យមកទទួលគ្រួសារ គឺជនពិការនៅសមរភូមិមុខ។ ក្រោយមកទៀត បានរុញអ្នកពិការ គឺកំបុតជើងលើៗក្បាលជង្គង់ទាំងពីរនៅលើរទេះរុញ។ ខ្ញុំក្រឡេកឃើញ ខ្ញុំភ័យពេក ខ្ញុំស្រែកនៅក្នុងក្រសួង ក្នុងមន្ទីរហ្នឹង ខ្ញុំស្រែក ដោយមិនបានជាចាប់អារម្មណ៍ថា ខ្លាចគេយកទៅវៃចោលខ្លាចអីទេ ដោយឃើញ វាស្លុតពេក ខ្ញុំក៏ស្រែកថា “មិត្តបង! ខ្ញុំអត់យកទេ ខ្ញុំអត់យកទេ ដាច់ខាត ខ្ញុំអត់យកទេ”។ ដល់ក្រោយមកទៀតមក បានមិត្តមួយទៀត គាត់ដើរមក គាត់ប្រាប់ថា “មិនបាច់ទេទៅ ឲ្យទៅកន្លែងវិញទៅ ទៅការដ្ឋានវិញទៅ”។ ខ្ញុំបានប្រកែករួចនៅលើទី១។ តែមកដល់វិញ ខ្ញុំមានអារម្មណ៍ថាភ័យខ្លាចដែរ ដោយប្រកែក ប្រកែកនោះ ទៅទាំង ដូចថាមិនដឹងខ្លួនទេ។ ដល់ឃើញទៅ ស្លុតនឹងជនពិការ នាងខ្ញុំក៏បានប្រកែកស្រែកយក ស្រែកយកអ៊ីចឹងទៅ ក៏បានមិត្តមួយទៀត ឲ្យខ្ញុំមកការដ្ឋានវិញ។ ហើយក្រោយមកទៀត បាន១គេហៅខ្ញុំប្ដេជ្ញាចិត្តហ្នឹង។ ខ្ញុំប្រកែកដែរ តែដល់ពេលថ្នាក់លើ គេថា “កង់ប្រវត្តិសាស្ត្រកំពុងតែវិល អ្នកណាលូកដៃដាច់ដៃ អ្នកណាលូកជើងដាច់ជើង។ អង្គការជាភ្នែកម្នាស់ អ្នកឯងធ្វើអី ក៏មិនជិតដែរ”។ ចាស អស់ ចាស សូមអស់សំណួរ អស់ចម្លើយ។

[១១:០៧:២៦]

**ស៖** <តើចន្លោះ>ពេលដែលលោកស្រីប្រកែកមិនព្រមរៀបការជាមួយជនពិការ<លើកទី១> រហូតទៅដល់ពេលដែលលោកស្រីរៀបការ<លើកទី២>ហ្នឹង វាមានរយៈប្រហែលជាប៉ុន្មានដែរ?

**ឆ៖** ខ្ញុំប្រកែកលើកទី១រួចហើយ ទៅតាមការដ្ឋានវិញ ប្រហែលជារយៈ ប្រហែលជា២ខែក្រោយមក បានគេហៅខ្ញុំប្ដេជ្ញាចិត្ត។

**ស៖** ក្នុងពេលរៀបការ តើគេមានបាននិយាយដោយត្រង់ ឬបញ្ជិតបញ្ចៀងឲ្យលោកស្រីត្រូវរួមដំណេកជាមួយប្ដីទេ?

**ឆ៖** ចាស គឺមិនបានបញ្ជិតបញ្ចៀងអីទេ ព្រោះបានថាអ៊ីចឹង បានគាត់ឡើងប្រកាសឲ្យថា ឲ្យខ្ញុំប្ដេជ្ញាចិត្តថាតាមគាត់ “គឺបង្កបង្កើតមនុស្សឲ្យបានច្រើន បង្កបង្កើនកូនឲ្យបានច្រើន ដើម្បីអង្គការត្រូវ

ការមនុស្ស ដើម្បីការពារទឹកដី"។ ចាស គឺនិយាយអ៊ីចឹងតែម្តង។

**ស៖** ពេលដែលលោកស្រីឮគេប្រាប់ថា ត្រូវបង្កបង្កើតកូនឲ្យបានច្រើនហ្នឹង <តើ>លោកស្រីគិតថា ពេលហ្នឹង គឺថាលោកស្រីត្រូវតែរួមដំណេកជាមួយប្តី មែនទេ ដើម្បីឲ្យបានបង្កបង្កើនកូនឲ្យបានច្រើននោះ?

**ឆ៖** នាងខ្ញុំគិតថា បើសិនខ្ញុំមិនរួមរស់ជាមួយប្តី គឺនាងខ្ញុំមិនដឹងជាទៅដល់ដំណាក់កាលណាទេ គេយកនាងខ្ញុំទៅសម្លាប់ចោលក៏មិនដឹងទេ ព្រោះនាងខ្ញុំប្រកែកម្តង ជាពីរដងហើយអ៊ីចឹង។ ដល់ពេលអ៊ីចឹង ហើយណាមួយ ខ្ញុំឃើញឈ្លបនាំទាំងគូៗទៅ នឹងភ្នែកៗខ្ញុំ មានអារម្មណ៍ថា ត្រង់ហ្នឹងហើយ ដែលខ្ញុំសុខចិត្តថា ខ្ញុំសុខចិត្តរួមដំណេកជាមួយប្តីរបស់ខ្ញុំ។

[១១:០៩:៤៨]

**ស៖** ៣ថ្ងៃក្រោយមកនោះ នៅពេលដែលប្តីលោកស្រីមកជួបលោកស្រីម្តងៗហ្នឹង តើលោកស្រីសប្បាយចិត្តទេ? ហើយលោកស្រីព្រមព្រៀងក្នុងការរួមដំណេកជាមួយគាត់រហូត ឬក៏<ផ្ទុយមកវិញ> លោកស្រីមានអារម្មណ៍មិនសប្បាយចិត្ត <ឬ លោកស្រីមានអារម្មណ៍ផ្សេងទៅវិញ>?

**ឆ៖** ពេលមកជួបក្នុងមួយអាទិត្យគេឲ្យមកជួបគ្នាម្តងនៅពេលយប់ហ្នឹង ព្រលឹមឡើងក៏បែកចេញទៅវិញ។ តែនៅពេលយប់ដែលគាត់មកជួបខ្ញុំហ្នឹង ខ្ញុំមិនមានអារម្មណ៍រីករាយ មិនមានអារម្មណ៍រំភើបអីនឹងចំពោះខ្លួនគាត់ទេ។ ខ្ញុំនឹកឃើញថា មានអារម្មណ៍មិនចង់រួមរស់នឹងគាត់ទេ ក៏ប៉ុន្តែធ្វើម៉េចបើបានជាជ្រុលទៅបាត់ទៅហើយ មិនដឹងទៅប្រកែកថាម៉េច មិនដឹងធ្វើម៉េច ក៏ចេះតែតាមដំណើរធម្មជាតិរបស់ស្ត្រី និងបុរសទៅ លោកគ្រូ។

**ស៖** លោកស្រីថា លោកស្រីមិនចង់មានផ្ទៃពោះទេ អ៊ីចឹងនៅពេលដែលលោកស្រីមានផ្ទៃពោះនោះ តើលោកស្រីមានជីវភាពប្រសើរជាង<ស្ត្រីផ្សេងទៀត>ទេ? ឧទាហរណ៍ថា លោកស្រីត្រូវបានគេឲ្យធ្វើការតិចជាងមុន ឲ្យហូបចុកបានច្រើនជាងមុន ហើយឲ្យមានពេលសម្រាកអីច្រើនជាងមុន <តើ> មានអ៊ីចឹងទេ?

**ឆ៖** មិនមានទេ។ កាលណាខ្ញុំមានផ្ទៃពោះ ខ្ញុំលំបាក ហូបបរមិនបាន បបរលាយមកហើយហុតតែទឹកបន្តិចៗទៅ ក្អួតចង្អោរអស់។ មិនបានឲ្យបានស្រួលទេ ពេលខ្ញុំមានផ្ទៃពោះ វេទនាណាស់ ខ្ញុំស្តូមសល់តែក្បាល ធ្វើការទាំងស្គមស្គាំងហ្នឹង ដោយគេមិនឲ្យយើងឈប់សម្រាកទេ។ សម័យនោះ គេមិនឲ្យយើងសម្រាកទេ តែនរណាឈឺ គឺឈឺសតិអារម្មណ៍ហើយ គេមិនឲ្យយើងឈប់ទេ។

[១១:១២:០៩]

**ស៖** ដោយសារតែ<កាលៈទេសៈបែបនោះ និងការស្លាប់កូនទី១ របស់លោកស្រី> អ៊ីចឹងនៅពេលដែលលោកស្រីមានគភ៌លើកទី២ទៀតនុំង មានផ្ទៃពោះលើកទី២ លោកស្រីភ័យខ្លាចថាអាចនឹងកូនហ្នឹងស្លាប់ទៀតទេ?

**ឆ៖** ចាស ភ័យ។ ភ័យហើយមានកូនលើកទី២ហ្នឹង នាងខ្ញុំធ្វើការធ្ងន់ជាងលើកទី១ទៀត។ ធ្វើការធ្ងន់ ហើយនឹកបារម្ភ ព្រួយបារម្ភរាល់ថ្ងៃ នឹកគិតថា ខ្លាចលោកូនហ្នឹងកើតមកស្លាប់ដូចជាកូនទី១។ តែដល់មកចុងឆ្នាំ៧៧ ខ្ញុំកើតកូនហ្នឹងមក កូនហ្នឹងស្គមមានតែឆ្អឹង អត់មានអី ដូចថាវាខ្វះជីវជាតិបំប៉នទារក ប៉ុន្តែចេះតែរស់ទាំងត្រដរមករហូតសព្វថ្ងៃទៅ លោកគ្រូ។

**ស៖** ខ្ញុំសួរជិតចប់ហើយលោកស្រី។ ក្នុងចំណោមមិត្តភក្តិដែលមានអាយុដូចៗគ្នានៅភូមិលោកស្រី ឬក៏ក្នុងចំណោមក្រុមគ្រួសារលោកស្រី តើមានអ្នកណាដែលត្រូវបានគេឲ្យរៀបការនៅសម័យកម្ពុជាប្រជាធិបតេយ្យទេ? ហើយបើមាន តើពួកគាត់រៀបការយ៉ាងម៉េចដែរ?

**ឆ៖** នៅឆ្នាំ៧៨ ចុងឆ្នាំ៧៨ គេឲ្យប្អូនខ្ញុំបង្កើតទៅរៀបការ ៦០គូដែរ។ គេឲ្យរៀបការដូចគ្នាអ៊ីចឹងដែរ ហ្នឹងជាប្អូនរបស់នាងខ្ញុំបង្កើត មិនមានអ្នកសាច់ញាតិអ្នកចូលរួមដូចគ្នាអ៊ីចឹងដែរ។

**ស៖** ប្អូនលោកស្រីហ្នឹង មានបានរៀបរាប់ប្រាប់ថាគាត់រៀបការយ៉ាងម៉េចទេ? ហើយ<តើ> គាត់មានបានប្រាប់ថា ពិធីការហ្នឹងគឺវាមានលក្ខណៈដូចជាពេលដែលលោកស្រីការដែរទេ?

[១១:១៤:៣៤]

**ឆ៖** ចាស ដូចតែគ្នា មិនខុសគ្នាទេ អត់មានខុសទេ មានតែពីខ្លាំងជាងពីជំនាន់ខ្ញុំទៀត។ ពីជំនាន់ខ្ញុំ ពី៧៥ ទើបនឹងរំដោះទីក្រុងភ្នំពេញបាន មិនសូវជាប៉ុន្មានទេ ប៉ុណ្ណឹង ក៏ខ្ញុំឈឺចាប់ណាស់ទៅហើយ តែមកប្អូនខ្ញុំ៧០ ចុង៧៨ វារៀបរួចជិតដាច់ សម្លាប់មនុស្សឡើងរង្គាល សម្លាប់នឹងភ្នែក នឹងភ្នែក។ នាងខ្ញុំឈឺចាប់ណាស់។

**ស៖** លោកស្រីអាចបញ្ជាក់បានទេ ប្អូនលោកស្រីហ្នឹង តើប្អូនប្រុស ឬក៏ប្អូនស្រី? ហើយគាត់ត្រូវបានគេបង្ខំឲ្យរៀបការហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** ប្អូនខ្ញុំ ប្អូនស្រី រៀបការគឺនៅភូមិអូរថ្មហ្នឹងដដែល មួយកន្លែងដែលខ្ញុំរៀបការហ្នឹង។

**ស៖** បើតាមលោកស្រីប្រាប់លោកប្រធានថា លោកស្រីនៅតែយកគ្នាជាប្តីប្រពន្ធដដែលជាមួយប្តីដែលលោកស្រីត្រូវបានគេបង្ខំឲ្យរៀបការនៅសម័យកម្ពុជាប្រជាធិបតេយ្យនោះ។អ៊ីចឹងខ្ញុំសួរថា ហេតុ

អ្វីបានជាក្រោយឆ្នាំ១៩៧៩ លោកស្រីសម្រេចចិត្តនៅតែបន្តរួមរស់ជាមួយប្ដីដដែល?

**ឆ៖** ខ្ញុំក្រោយពីឆ្នាំដាច់មកហ្នឹង ខ្ញុំបានជាខ្ញុំរួមរស់ជាមួយគ្រួសារជាប្ដីប្រពន្ធរហូតមកដល់សព្វថ្ងៃ ដោយខ្ញុំគិតថាខ្ញុំអាណិតកូន កើតក្នុងសម័យសង្គ្រាម កូនមិនបានពេញលេញទេ។ ហើយណាមួយខ្លួនខ្ញុំជាស្ត្រីខ្មែរ ខ្ញុំមិនចង់ឲ្យកូនមានឪមួយ ឪពីរ ប្ដីមួយ ប្ដីពីរទេ ខ្ញុំសុខចិត្តតែទ្រាំនៅរួមរស់ជាមួយគាត់រហូតមកដល់បច្ចុប្បន្នកាលនេះ ក៏ខ្ញុំនៅតែមានភាពឈឺចាប់ដែរចំពោះគ្រួសាររបស់ខ្ញុំ តែខ្ញុំសុខចិត្តទ្រាំដោយសារកូន បានជាកូនហើយ ខ្ញុំមិនចង់ឲ្យកូនបែកបាក់ទៅខាងណាមកខាងណាទេ។ ខ្ញុំក៏ទ្រាំរស់ទាំងការឈឺចាប់រហូតមកដល់សព្វថ្ងៃ លោកប្រធាន។

[១១:១៧:១២]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងលេ៖**

លោកអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ លោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាតទៅនេះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា។

**លោក លីវ សុវណ្ណា៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការជាថ្មី។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំឈ្មោះ លីវ សុវណ្ណា ជាមេធាវីជាតិនៅក្នុងក្រុមការពារក្ដីលោក នួន ជា។ ខ្ញុំមានសំណួរមួយចំនួនសាកសួរលោកស្រី ជាដំបូងនេះខ្ញុំចង់ដឹងថានៅក្នុងតំបន់ដែលលោកស្រីរស់នៅហ្នឹង គេរំដោះនៅក្នុងឆ្នាំណា? ខែណាដែរ? ដែលគេហៅថាកម្ពុជាប្រជាធិបតេយ្យបានរំដោះនៅក្នុងតំបន់លោកស្រីហ្នឹងនៅក្នុងខែណា ឆ្នាំណាដែរ?

**លោកស្រី សយ ណាវឿន៖**

**ឆ៖** ខ្ញុំមិនបានចាំទេ តែក្នុង ដឹងថាឆ្នាំនៅក្នុងអំឡុងឆ្នាំ៧៥ – ១៩៧៥ តែថ្ងៃ១៧ មេសា ហ្នឹងគេបានជម្លៀសខ្ញុំចេញពីភូមិកំណើតខ្ញុំ ទៅនៅក្នុងភូមិក្នុងឃុំអូរទន្ទងតែម្ដង។

[១១:១៨:២៧]

**ស៖** បាទ ដើម្បីរំឭកការចងចាំរបស់លោកស្រី ឯកសារលេខ E3/5009 ក្នុងទម្រង់បែបបទនៃការបំពេញរបស់ជនរងគ្រោះនេះ ដែល ERN ជាភាសាខ្មែរមានលេខ 00559307, ជាភាសាអង់គ្លេសផ្នែកនេះពុំមានទេ។ ក្នុងហ្នឹងលោកស្រីបានឆ្លើយថា៖ "ឆ្នាំ១៩៧៤ ក្រុមគ្រួសាររបស់នាងខ្ញុំធ្វើការនៅភូមិអូរទឹកត្រជាក់ ឃុំអូរដូង ដល់នៅទីនោះគេបានបង្ខំឲ្យពួកយើងធ្វើការដោយមិនមានពេលសម្រាក និងគ្មានអាហារគ្រប់គ្រាន់សម្រាប់ហូបនោះទេ។" ដូច្នេះក្នុងឯកសារនេះ លោកស្រីបានឃើញថាឆ្នាំ១៩៧៤ គឺលោកស្រីត្រូវបានគេបង្ខំឲ្យធ្វើការនៅក្នុងភូមិអូរទឹកត្រជាក់ទៅហើយ មិនមែននៅក្នុងភូមិកំណើតរបស់លោកស្រីទេ។ អ៊ីចឹងសូមលោកស្រីរំឭកការចងចាំមើល តើលោកស្រី តំបន់លោកស្រីហ្នឹងរំដោះពេលណា?

**ឆ៖** ខ្ញុំមិនបានចាំត្រង់ថា ពេលដែលខ្ញុំទៅនៅដល់អូរទឹកត្រជាក់ហ្នឹង ខ្ញុំ -- ព្រោះបានអ៊ីចឹងខ្ញុំនឹកឃើញថា ខ្ញុំទៅដល់ គេជម្លៀសខ្ញុំហ្នឹងនៅពេលរំដោះហើយទេ។ មិនបាននៅក្នុងចុង៧៤ហ្នឹងខ្ញុំ បើចុង៧៤ហ្នឹង គឺខ្ញុំនៅជាសហករណ៍ -- នៅជាកងចល័តតាមភូមិ លើកទំនប់ ជីកប្រឡាយ លើកភ្លឺស្រែនៅតាមភូមិទេ ចុងឆ្នាំ៧៤ណោះ។

**ស៖** អ៊ីចឹងនៅពេលដែលលោកស្រីលើកទំនប់ជីកប្រឡាយ នៅចុងឆ្នាំ៧៤ហ្នឹង តើលើកទំនប់ជីកប្រឡាយនៅក្នុងតំបន់រំដោះ ឬមួយក៏នៅក្នុងតំបន់ដែលកាន់កាប់ដោយរដ្ឋាភិបាលលន់ នល់?

**ឆ៖** ខ្ញុំលើកទំនប់ជីកប្រឡាយហ្នឹង កាលពីខ្ញុំនៅចុងឆ្នាំ៧៤ គឺមិនមែននេះទេ គឺនៅសម័យ លន់ នល់ នៅឡើយទេ មិនទាន់រំដោះទីក្រុងភ្នំពេញបានទេ។ តែក្រោយមក ខ្ញុំមកនៅភូមិអូរទឹកត្រជាក់ហ្នឹង ឃុំអូរទ្លួង ក៏ខ្ញុំលើកទំនប់ជីកប្រឡាយដូចគ្នា។

[១១:២០:៥៤]

**ស៖** បាទ សំណួរខ្ញុំ ខ្ញុំអត់ចង់ដឹងពីការរំដោះនៅភ្នំពេញទេ ខ្ញុំសួរតំបន់ដែលលោកស្រីរស់នៅហ្នឹង ភូមិលោកស្រីរស់នៅហ្នឹង តើគេ -- ជាការកាន់ -- ស្ថិតក្រោមការកាន់កាប់របស់ លន់ នល់ ឬក៏ជាការកាន់កាប់របស់ពួកអ្នករំដោះ?

**ឆ៖** ខ្ញុំចង់បញ្ជាក់ថា ពេលខ្ញុំទៅដល់នៅភូមិអូរទឹកត្រជាក់ហ្នឹង គឺគេរំដោះហើយ។ ទៅដល់បានតែពីរថ្ងៃ បីថ្ងៃ គេរំដោះតែម្តង រំដោះទីក្រុងភ្នំពេញហ្នឹង។

**ស៖** លោកស្រីថ្លែងអំមិញថា លោកស្រីការឆ្នាំ១៩៧៥ តើការនៅថ្ងៃខែណាដែរ លោកស្រីចាំបានទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ផ៖** ខ្ញុំមិនបានចាំទេ ពេលគេហៅខ្ញុំរៀបការ ខ្ញុំមិនបានចាំទេ ព្រោះខ្ញុំគ្មាន សម័យនោះខ្ញុំអត់បានមានប្រតិទិនសម្រាប់មើលថ្ងៃខែចាំទេ ខ្ញុំអត់បានចាំទេចាស។

**ស៖** តើលោកស្រីអាចគិតថា ជារដូវវស្សា រដូវប្រាំង ឬក៏ជារដូវរំហើយ រដូវរងារចុងឆ្នាំ លោកស្រីអាចចាំបានទេ?

**ផ៖** ចាស បើអស់លោកសួរពីរដូវខ្ញុំចាំ បើសួរពីខែ ៗខ្ញុំមិនចាំទេ ខែថ្ងៃខ្ញុំអត់ចាំទេ។ បើសួរពីរដូវកាលខ្ញុំចាំ នៅរដូវរំហើយ។

**ស៖** បាទ មុននេះលោកស្រីឆ្លើយនឹងសំណួររបស់សហព្រះរាជអាជ្ញាថា គេបានឱ្យលោកស្រីទៅជួបគេ ហើយគេឱ្យលោកស្រីរៀបការជាមួយនឹងអ្នកពិការជើង។ លោកស្រីបានប្រកែក ហើយគេបានបញ្ជូនឱ្យមកធ្វើការនៅការដ្ឋានវិញ។ តើការដ្ឋានដែលបញ្ជូនមកវិញ ការដ្ឋានដែលលោកស្រីធ្វើការដដែល ឬមួយការដ្ឋានផ្សេងទៀត?

[១១:២៣:២៥]

**ផ៖** ការដ្ឋាន មិនមែនការដ្ឋានដដែលទេ នាងខ្ញុំដើរធ្វើការដ្ឋាន មួយក្រសួងស-៦២ គឺខ្ញុំ នាងខ្ញុំដើរការដ្ឋានច្រើនណាស់។

**ស៖** បាទ សំណួរខ្ញុំ ១ចង់សួរពេលដែលលោកស្រី ក្រោយពីលោកស្រីប្រកែកហើយនោះ អ៊ីចឹងគេឱ្យលោកស្រីមករស់នៅ ឬក៏មកធ្វើការនៅកន្លែងដដែលវិញ ឬក៏អត់ទេ?

**ផ៖** ខ្ញុំប្រកែកហើយ ខ្ញុំត្រឡប់មកចូលនៅការដ្ឋានមួយទៀត ចំបក់មាស គេហៅថា ភូមិចំបក់មាស។ ក្រោយមកបានការដ្ឋាននុ៎ង បានចំនួនប្រហែលជា២អាទិត្យ ៣អាទិត្យ បានគេបញ្ជូននាងខ្ញុំមកការដ្ឋានលើកទំនប់ ទំនប់កុមារនៅភូមិវាលទូក។

**ស៖** នៅពេលដែលគេបង្ខំឱ្យលោកស្រីរៀបការលើកទី១ ហ្នឹងលោកស្រីបានប្រកែក ហើយពុំមានរឿងអ្វីកើតឡើងជាមួយលោកស្រីទេ ចុះហេតុអីបានជាលើកទី២លោកស្រីមិនព្រមប្រកែកដែរទៅ?

**ផ៖** នាងខ្ញុំបានប្រកែកដែរ លើកទី២ ក៏នាងខ្ញុំប្រកែកដែរ តែប្រធានកងគាត់ប្រាប់ថា កុំឱ្យនិយាយអ្វីក៏ដោយ ក៏កុំឱ្យនិយាយដែរ។ នាងខ្ញុំបានប្រកែកថា ហេតុអីក៏បានជាយកមករៀបការអ៊ីចឹងអត់មានបានដឹងមុនអ៊ីចឹង អត់មានស្គាល់គ្នា។ នាងខ្ញុំថា រួចចេះតែការៗទៅអ៊ីចឹង។ ទៅក៏ប្រធានកងហ្នឹងដែលធ្លាប់ក្តោបក្តាប់នាងខ្ញុំគ្រប់ការដ្ឋានហ្នឹង គាត់និយាយថា គេឱ្យ អង្គការឱ្យធ្វើអីធ្វើទៅ មិត្តឯងកុំប្រកែក។ ដល់ត្រង់ហ្នឹងហើយ ខ្ញុំអាចយល់ត្រង់ថា ខ្ញុំប្រកែកជាលើកទី១ គឺខ្ញុំប្រកែកដោយមិនដឹងខ្លួន។

ដល់មកលើកទី២នេះ ក៏បានប្រកែកហ្នឹងគេអ៊ីចឹងទៀត តែដល់គេនិយាយប្រាប់អ៊ីចឹងខ្ញុំនឹកឃើញថា បើសិនជាខ្ញុំនៅតែរឹងរូសស្រែកដូចជាលើកទី១ គឺខ្ញុំមានផលវិបាកហើយ។

[១១:២៥:៣៦]

**ស៖** តើលើកទី២ហ្នឹង លោកស្រីប្រកែកហ្នឹងនៅពេលណា ប៉ុន្មានថ្ងៃមុនដែលលោកស្រីគេហៅទៅប្ដេជ្ញាចិត្តហ្នឹង?

**ឆ៖** ប្រកែកពេលនាងខ្ញុំដើរទៅដល់ភូមិអូរថ្ម កន្លែងគេរៀបការហ្នឹង ប្រកែកមុនម៉េច បើអត់ដឹងផង។

**ស៖** លោកស្រីអំមិញមុននេះឆ្លើយថា អធិបតីក្នុងការរៀបអាពាហ៍ពិពាហ៍របស់លោកស្រី គឺមាន លោកស្រីស្គាល់គណៈស្រុកចូលរួម។ អ៊ីចឹងតើគណៈស្រុកហ្នឹង លោកស្រីស្គាល់គាត់ឈ្មោះអី? ហើយគាត់ស្រី ឬប្រុស?

**ឆ៖** ចាស ថ្នាក់ស្រុកឈ្មោះ មិត្តមឿន។ ប្រធានក្រសួងស-៦២ ឈ្មោះ មិត្តឃន។ ប្រធានឃុំឈ្មោះ មិត្តចេន។ ប្រធានកងខ្ញុំឈ្មោះ មិត្តរី។ សុទ្ធតែបុរស ស្ត្រីតែ មិត្តរី ម្នាក់។

**ស៖** តើ មិត្តមឿន ហ្នឹងគាត់នៅក្នុងស្រុកហ្នឹងគាត់ជាលេខាស្រុក អនុលេខាស្រុក ឬក៏សមាជិកស្រុកដែលលោកស្រីថាស្គាល់គាត់ហ្នឹង?

**ឆ៖** ខ្ញុំមិនដឹងជាលេខា ឬស្អីអាម៉េចអាម៉ាខ្ញុំអត់ដឹងទេ តែដឹងថា មិត្តមឿន ហ្នឹងគឺជាប្រធាននៅស្រុក។ ធំជាងគេនៅស្រុកនុ៎ង ដឹងគេធ្វើខាងអី ក៏ខ្ញុំមិនដឹងដែរ។

**ស៖** ស្រុកហ្នឹងស្រុកអីដែរ សូមលោកស្រីបញ្ជាក់ឲ្យច្បាស់មើល?

[១១:២៧:៣៤]

**ឆ៖** ស្រុកស-៦២។

**ស៖** មានឈ្មោះដែរទេ ក៏មានតែលេខសម្គាល់ស-៦២ហ្នឹង?

**ឆ៖** ខ្ញុំអត់បានដឹងទេ តែគេជម្លៀសខ្ញុំទៅហ្នឹង គេហៅថា យើងមកនៅនេះកន្លែងក្រសួងស-៦២ នៅស្រុកស-៦២ ឃុំអូរឡូង។

**ស៖** បាទ នៅក្នុង មុននេះគឺលោកស្រីថា លោកស្រីបានឃើញឈ្លបនាំគេពីរគូទៅ។ អ៊ីចឹងសំណួរខ្ញុំចង់សួរថា តើពេលលោកស្រីឃើញហ្នឹង យប់ហ្នឹងគឺលោកស្រីមានបានឃើញមុខអ្នកដែលត្រូវគេនាំទៅហ្នឹងទេ ទាំងឈ្លប ទាំងអ្នកដែលត្រូវគេនាំទៅ?

**ឆ៖** ខ្ញុំមិនបានឃើញមុខទេ ព្រោះអីយប់ តែឃើញគ្រាន់តែឃើញគេដុតភ្លើងឬស្សីជ័រដាក់នេះហ្នឹង ភ្លើងភ្លុងៗហ្នឹងខ្ញុំឆ្ងាយ ហើយខ្ញុំមិនបានឃើញមុខអ្នកដែលគេនាំទៅទេ ខ្ញុំអត់បានឃើញទេ។

**សះ** ចុះមិនបានឃើញ ហេតុអីបានជាលោកស្រីសន្និដ្ឋានថា អ្នកដែលនាំទៅហ្នឹង គឺជាគូដែលរៀបការពីថ្ងៃ?

**ឆ៖** ចុះបើសិនជា ខ្ញុំឃើញ ហែកជញ្ជាំងទៅ ឃើញចេញពីច្រកដែលគេឱ្យអ្នកប្ដេជ្ញាចិត្តចូលមួយជួរហ្នឹង រោង មានរោងបន្ទប់ជាប់ៗគ្នារហូតហ្នឹង ខ្ញុំមិនឃើញ។

[១១:២៩:២៧]

**សះ** បាទ ហើយហេតុអ្វីបានជាចម្លើយនេះ វាទើបតែមានពេលថ្ងៃនេះ ហើយនៅក្នុងទម្រង់បែបបទដែលលោកស្រីបានបំពេញពីមុនមក គឺឯកសារលេខ E3/5009 ត្រង់ ERN លេខជាភាសាខ្មែរលេខ 00559307 លោកស្រីគ្រាន់តែបានឆ្លើយថា៖ "នៅពេលយប់ឡើង ពួកឈ្លបបានដើរស៊ើបមើលតាមផ្ទះ ព្រោះពួកគេចង់ដឹងថាតើពួកយើងគោរពទៅតាមការរៀបចំរបស់អង្គការឬក៏អត់។ ប្រសិនបើគេដឹងថា ពួកយើងមិនបានធ្វើតាមការគោរពបញ្ជារបស់អង្គការនោះ គេនឹងមានវិធានការ ដើម្បីចាត់ការចំពោះយើងជាមិនខាន។" ហេតុអីបានជានៅក្នុងការបំពេញបែបបទរបស់លោកស្រី លោកស្រីមិនបានបញ្ជាក់ថា ពេលយប់នុ៎ង ឈ្លប ឃើញឈ្លបមាននាំអ្នកផ្សេងទៅ ចេញទៅនេះៗ? សូមលោកស្រីបញ្ជាក់ឱ្យបានច្បាស់មើល។

**ឆ៖** ចាស ខ្ញុំសូមបញ្ជាក់ប្រាប់ឱ្យច្បាស់ថា កាលពីខ្ញុំដាក់ពាក្យបណ្ដឹងលើកទី១ លើកទីក្រោយមកទៀត ខ្ញុំមិនអាចចាំនូវភាពទាំងអស់នោះគ្រប់២៤ម៉ោងទេ។ ខ្ញុំអាចមានការភ្លេចភ្លាំង ដល់ក្រោយមកទៀត ខ្ញុំនឹកឃើញ ដល់ពេលខ្ញុំចេះតែរំឭកទៅ ខ្ញុំអាចនឹកឃើញពីគេដើរយាមល្បាត ពីគេនាំមនុស្សទៅ។ កាលដែលខ្ញុំធ្វើឯកសារនុ៎ង ខ្ញុំមិនបានរៀបរាប់អស់ ដោយសារខ្ញុំវាមានការភ្លេចភ្លាំង ព្រោះខ្ញុំចាស់ហើយចាស។

**សះ** បាទ ខ្ញុំឃើញក្នុងហ្នឹង លោកស្រីបាននិយាយរឿងថា មានឈ្លប មានអីចឹង។ ចុះហេតុអីបានជាព្រឹត្តិការណ៍សំខាន់នៅក្នុងយប់ហ្នឹង ដែលទាក់ទងនឹងរឿងឈ្លប រឿងអីហ្នឹងដែរ ហេតុអីបានជាលោកស្រីទៅជាភ្លេចទៅវិញ?

[១១:៣១:២៥]

**ឆ៖** បានជាខ្ញុំភ្លេច ខ្ញុំគ្រាន់តែថា នឹកឃើញតែឈ្លប ដល់ពេលក្រោយមកទៀតទៅ បានខ្ញុំនឹក

ឃើញថា អំពេលគេ ពេលឈ្លបទៅយាមហ្នឹង ឃើញគេនាំពីរគូចេញ អ៊ីចឹងបានខ្ញុំសុំធ្វើឯកសារបន្ថែមដោយខ្ញុំមានការភ្លាំងភ្លេចពីមុនមក។

**ស៖** បាទ ដោយសារពេលវេលាខ្លី ខ្ញុំសូមសួរសំណួរមួយចុងក្រោយ។ នៅក្នុង មុននេះលោកស្រីបានឆ្លើយថា លោកស្រីបានបាត់បង់សាច់ញាតិអស់១១នាក់។ ប៉ុន្តែហេតុអ្វីបានជានៅក្នុងការបំពេញទម្រង់បែបបទរបស់លោកស្រីនេះ ឯកសារលេខ E3/5009 ដដែលហ្នឹង ផ្នែក "គ" ហ្នឹង កន្លែងគេសួរចំណុចទី២ គេសួរថា "សូមបញ្ជាក់អំពីព្យសនកម្ម ការបាត់បង់ ឬផលវិបាកដែលកើតដែលបានទទួល" ក្នុងហ្នឹងលោកស្រីអត់បានបញ្ជាក់ថា លោកស្រីបានត្រូវបាត់បង់សាច់ញាតិ១១នាក់ អីៗអត់មានទេ។ តែឥឡូវនេះបែរលេចថា លោកស្រីបានបាត់បង់សាច់ញាតិ១១នាក់។ ចុះហេតុអីបានជាពីមុនមក លោកស្រីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីអត់បានបញ្ជាក់ពីការបាត់បង់សាច់ញាតិបែបនេះ?

**ឆ៖** ចាស ខ្ញុំសូមបញ្ជាក់។ ការដែលខ្ញុំដាក់ពាក្យបណ្តឹងជាដើម តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺទី១ នាងខ្ញុំបានដាក់តែពីបញ្ហាការឈឺចាប់ និងរៀបការដោយបង្ខំ។ ដល់ក្រោយមកទៀតមកទើបខ្ញុំបានដឹងថា ការដាក់ពាក្យជាជនរងគ្រោះដោយសាច់ញាតិបានស្លាប់នៅក្នុងសម័យរបបនោះ ទើបនាងខ្ញុំធ្វើពាក្យដាក់មកតាមក្រោយ។ កាលលើកទី១ នាងខ្ញុំដាក់តែពាក្យថា ខ្ញុំឈឺចាប់ដោយគេរៀបការខ្ញុំដោយបង្ខំ។ ដល់មកវគ្គក្រោយទៀត បានខ្ញុំទៅពិភាក្សាទៅតាមគ្រប់អង្គការនានា តើជនរងគ្រោះដែលត្រូវសាច់ញាតិគេសម្លាប់ចោលហ្នឹង គេដាក់ធ្វើម៉េច ទៅសរុបជាមួយដើមបណ្តឹងដែលយើងដាក់ពាក្យសាមុនបានឬអត់? នាងខ្ញុំបានពិភាក្សាគ្រប់អង្គការនានាផ្សេងៗទៀត ដោយសារនាងខ្ញុំមិនយល់ដល់សភាពការណ៍ថា ឥឡូវយើងដាក់អ៊ីចឹងហើយ ក៏ដាក់អ៊ីចឹងទាំងអស់ នាងខ្ញុំអត់បានយល់អ៊ីចឹងទេ។ បានជានាងខ្ញុំធ្វើបន្ថែមតាមក្រោយ។ ចាស សូមអស់យោបល់។

[១១:៣៣:៥៦]

**លោក លីវ សុវណ្ណា៖**

បាទ ដោយសារពេលវេលា ខ្ញុំបាទសូមដើម្បីប្រតិចារឹក គឺនៅក្នុងឯកសារ E3/5009 ក៏គាត់ពុំបានដាក់ថា ព្យសនកម្មគាត់ហ្នឹង គឺកើតចេញពីការរៀបការដោយបង្ខំដែរ។ បាទ សូមអរគុណលោកប្រធាន។ សូមអស់សំណួរ។

**ប្រធានអង្គជំនុំ៖**

ម៉េចហើយ ខាងក្រុមសហមេធាវីការពារក្តី ខៀវ សំផន មានសំណួរសួរចំពោះដើមបណ្តឹងរដ្ឋ

ប្បវេណីរូបនេះដែរឬទេ?

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ក្រុមយើងខ្ញុំអត់មានសំណួរថែមទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះ អរគុណលោកស្រី សយ ណារឿន។ ឥឡូវនេះសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់ទុក្ខសោកវេទនារបស់លោកស្រី បានដល់ទីបញ្ចប់ហើយ។ ហើយសូមឱ្យលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ បានតែសេចក្តីសុខ សេចក្តីចម្រើន។ ហើយអង្គជំនុំជម្រះក៏សូមអរគុណ – លោកស្រី តើមានបំណងអីថ្លែងរៀបរាប់ចុងក្រោយដែរទេ? ហើយបើសិនជាមានលោកស្រីអាចធ្វើចុងក្រោយបានណ៎ា ព្រោះយើងបានប្រាប់លោកស្រីតាំងពីដំបូង។

[១១:៣៥:១៥]

**លោកស្រី សយ ណារឿន៖**

ចាស លោកប្រធាន នាងខ្ញុំមានសំណួរពីរសំណួរលោកប្រធាន។ សំណួរទី១ នាងខ្ញុំសួរថា សួរទៅលោកប្រធាន ឱ្យលោកប្រធានជួយបកស្រាយទៅចុងចោទថា ហេតុអ្វីបានជាប្រើមនុស្សឱ្យធ្វើការដូចជាសត្វធាតុ ហើយការហូបចុកមិនឱ្យគ្រប់គ្រាន់ ចុះស្រូវអង្ករ ដែលប្រជាពលរដ្ឋខំប្រឹងធ្វើទាំងយប់ទាំងថ្ងៃ តើយកបញ្ចេញទៅណា? ចាស នេះសំណួរទី១។ សំណួរទី២ ហេតុអ្វីបានជាច្បាប់បង្កើតឱ្យមកចាប់រៀបការដោយបង្ខំ ដោយមនុស្សពុំដែលស្គាល់គ្នា? សួរថាហេតុអ្វីបានជាច្បាប់នេះចែងមក សួរថាគ្រួសារនីមួយៗសេចក្តីស្រឡាញ់ មានស្នេហាគឺកើតមកពីសេចក្តីស្រឡាញ់ មនោសញ្ចេតនារៀងខ្លួនហ្នឹងទើបយើងមានចិត្តស្រឡាញ់គ្នា? នាងខ្ញុំសូមសំណួរ សូមសួរសំណួរពីរសំណួរនេះទៅលោកប្រធាន។ សូមអស់យោបល់។

**ប្រធានអង្គជំនុំ៖**

សួរលោកប្រធាន ឬក៏សួរទៅជនជាប់ចោទតាមរយៈប្រធាន?

**លោកស្រី សយ ណារឿន៖**

នាងខ្ញុំសួរទៅចុងជាប់ចោទតាមរយៈប្រធាន។ ចាស សូមទោសលោកប្រធាន។

[១១:៣៦:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនលោកស្រី សយ ណារឿន ថា នៅក្នុងកិច្ចដំណើរការសវនាការលើអង្គសេចក្ដីពិនិត្យភស្ដុតាងនៅក្នុងសំណុំរឿង០០២/០២នេះ ហើយតាំងពីពេលដំបូងនៃសវនាការ ជនជាប់ចោទទាំងពីររូប នួន ជា និងលោក ខៀវ សំផន បានប្រកាន់ជំហរ និងអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ខ្លួន។ ហើយក៏ប្រការនេះ ក៏បានបញ្ជាក់បន្ថែមនៅសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ផងដែរ។ ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះមិនបានទទួលដំណឹងអំពីការផ្លាស់ប្ដូរជំហរពីការដែលរក្សានៅស្ងៀមមិនឆ្លើយតបមកជាឆ្លើយតបនឹងសំណួររបស់ភាគី ឬក៏ចៅក្រមនៃអង្គជំនុំជម្រះនោះទេ។ ហើយតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ អង្គជំនុំជម្រះមិនអាចបង្ខំឲ្យជនជាប់ចោទឆ្លើយតបទៅនឹងសំណួរបានឡើយ។ នេះជាសិទ្ធិមូលដ្ឋានរបស់ជនជាប់ចោទ ហើយមានចែងច្បាស់លាស់នៅក្នុងវិធានផ្ទៃក្នុង ដែលប្រើប្រាស់ផ្ទាល់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ សូមលោកស្រីជ្រាប។

ហើយអង្គជំនុំជម្រះអរគុណលោកស្រី។ ហើយនេះ ឥឡូវនេះដល់ពេលសវនាការស្ដាប់សេចក្ដីថ្លែងរៀបរាប់ទុក្ខសោកវេទនារបស់លោកស្រីបានដល់ទីបញ្ចប់ហើយ។ ហើយលោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ អង្គជំនុំជម្រះក៏សូមអរគុណលោក ប៊ុន លឹមហួរ ហើយសវនាការស្ដាប់សេចក្ដីថ្លែងរៀបរាប់ទុក្ខសោកវេទនារបស់ដើមបណ្ដឹងរដ្ឋប្បវេណីបានដល់ទីបញ្ចប់ហើយ លោកអាចសម្រាកបានហើយ។

ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ -- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ លោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៨ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:៤៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-859 ពាក់ព័ន្ធនឹងអង្គហេតុនៃលក្ខណៈនៃជម្លោះប្រដាប់អាវុធ។ ហើយអង្គជំនុំជម្រះកត់សម្គាល់ថា សាក្សីរូបនេះ ត្រូវបានស្តាប់ចម្លើយនៅក្នុងកិច្ចស៊ើបអង្កេត ដែលកំពុងដំណើរការនៅក្នុងសំណុំរឿងផ្សេង។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់សាក្សីរូបនេះ ស្ថិតនៅក្នុងក្រុម "ក" នៃក្រុមទាំងបីប្រភេទនៅក្នុងអនុស្សរណៈរបស់ខ្លួន (សូមមើលឯកសារ E319/35) ហើយបានស្នើថា សាក្សីរូបនេះ ត្រូវប្រើរហស្សនាមក្នុងគោលបំណងការពារនូវភាពសម្ងាត់នៃកិច្ចដំណើរការស៊ើបអង្កេត។

អង្គជំនុំជម្រះយល់ឃើញថា វិធានការដែលមានកម្រិតបែបនេះ គឺត្រឹមត្រូវសមស្របតាមច្បាប់នៅក្នុងករណីបែបនេះ ហើយការបង្គាប់នេះ គឺត្រូវធ្វើឲ្យមានតុល្យភាពគ្នា រវាងតម្រូវការនៃសាធារណភាពនៃសវនាការជាមួយនឹងការការពារសុចរិតភាពនៃការស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះក៏សូមរំឭកដល់ភាគីផងដែរ ថាសូមគោរពឲ្យបានខ្ជាប់ខ្ជួននូវសេចក្តីណែនាំ នៅក្នុងឯកសារ E319/7 ក្នុងការប្រើប្រាស់ឯកសារដាក់បង្ហាញពីសំណុំរឿងផ្សេងៗ។

ហើយមុននឹងអញ្ជើញសាក្សីចូលមកកាន់បន្ទប់សវនាការ អង្គជំនុំជម្រះចេញសេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិជាមុនសិន។

[១៣:៣៥:៣១]

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំឲ្យទទួលយកឯកសារចំនួនប្រាំបី ធ្វើជាឯកសារភស្តុតាងអនុលោមតាមវិធាន៨៧(៣) និង៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E319/56)។ ឯកសារមួយដែលត្រូវបានស្នើឲ្យទទួលយកមានលេខឯកសារ E319/56.3.2 គឺជាកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី 2-TCW-859 ពីសំណុំរឿង០០៣ ដែលត្រូវបានកំណត់ឲ្យមកផ្តល់សក្ខីកម្មនាពេលនេះ។

អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា ចម្លើយតបរួមរបស់សហមេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន៨៧(៣) និង ៨៧(៤)នៃវិធានផ្ទៃក្នុង (ឯកសារ E319/56 និង E319/58) ត្រូវបានដាក់កាលពីថ្ងៃចន្ទ ទី១០ ខែតុលា ឆ្នាំ២០១៦ ដែលនៅក្នុងចម្លើយតបនោះ មេធាវីការពារក្តីមិនបានជំទាស់ទៅនឹងការទទួលយកឯកសារ E319/56.2.3 ឡើយ។

អង្គជំនុំជម្រះរំឭកពីការអនុវត្តរបស់ខ្លួន ទាក់ទងទៅនឹងការទទួលយកធ្វើជាឯកសារភស្តុតាងនូវចម្លើយពីមុនៗរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី ដែលចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន៨៧(៣) និង៨៧(៤)នៃវិធានផ្ទៃក្នុង។ វាជាប្រយោជន៍នៅក្នុងការស្វែងរកការពិត ដែលអង្គជំនុំជម្រះ និងភាគីអាចចូលទៅមើលចម្លើយទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ដែលត្រូវបានកំណត់ឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០២នោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះទទួលយកឯកសារ E319/56.3.2 ធ្វើជាឯកសារភស្តុតាង និងដាក់លេខសម្គាល់ឯកសារនេះ ជា E3/10713។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី 2-TCW-859 រួមទាំងមេធាវីប្រឹក្សាសាក្សី ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៣:៣៨:០៤]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន សូមអរគុណ។ ឆ្លៀតពេលសាក្សីមុនចូលមកនេះ ខ្ញុំចង់បានការបំភ្លឺពីអង្គជំនុំជម្រះ។ <ខ្ញុំនិយាយនេះ>តាមការចងចាំ <ព្រោះ>ខ្ញុំមិន<មាន>សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត<នៅចំពោះមុខខ្ញុំ>ទេ។ ប្រភេទ “ក” ហ្នឹងគឺថាអាចនិយាយអំពីបញ្ហាពាក់ព័ន្ធនឹងគ្រួសារបាន។ អ៊ីចឹងតើមានការរឹតត្បិតអីបន្ថែមទៀតទេលោកប្រធាន? ពីព្រោះថាមានការនិយាយយោងច្រើនទៅប្រតិចារឹកនៃសវនាការសំណុំរឿង០០២/០១។ អ៊ីចឹង ខ្ញុំចង់ដឹងឲ្យប្រាកដ ថាតើខ្ញុំមានលទ្ធភាពអាចលើកឡើងអំពីមុខងាររបស់សាក្សីបានដែរឬទេ? ព្រោះថា បើមិន អ៊ីចឹងទេ វាមានលក្ខណៈស្មុគស្មាញបន្តិច។ បើយើងព្យាយាមសង្ខេបខ្លាំងពេកទៅ វាពិបាកណាស់ លោកប្រធាន។ អ៊ីចឹងខ្ញុំមិនដឹងថាតើសាក្សីប្រភេទ “ក” ហ្នឹង វាមានលក្ខខណ្ឌរឹតត្បិតយ៉ាងម៉េចខ្លះ។ សូមអង្គជំនុំជម្រះមេត្តាបំភ្លឺត្រង់ចំណុចហ្នឹងផង ដើម្បីឲ្យខ្ញុំចងចាំឡើងវិញ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកស្រីអត់មានសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតហ្នឹងទេឬ? អ៊ីចឹងតើមានភាគីណាមានលេខឯកសារសេចក្តីសម្រេចហ្នឹងទេ ដើម្បីឲ្យយើងអាចយល់បានទាំងអស់គ្នា?

**ចៅក្រម ក្ឌួឌា ហ្វេនស៍៖**

ប្រសិនបើមាន តើនៅមានសំណួរទេ? <ក្រោយពីមានឯកសារនេះតើអ្នក>សំណួរចង់សួរទៀត

ទេ?

[១៣:៣៩:៥៥]

**កញ្ញា អង់តា ហ្គីសសេ៖**

<ប្រហែលជាខ្ញុំនឹងមានសំណួរតិចតួច។ ប៉ុន្តែដើម្បីជាការចាប់ផ្ដើម> ខ្ញុំនឹងពឹងផ្អែកទៅលើការប្រយ័ត្នប្រយែងរបស់សហព្រះរាជអាជ្ញា នៅពេលដែលគាត់ធ្វើសេចក្តីជំទាស់ ប្រសិនបើការសួររបស់ខ្ញុំហ្នឹងវាចេញក្រៅវិសាលភាពនោះ។

ខ្ញុំទុកវេទិកានេះជូនអង្គជំនុំជម្រះជាមុនសិន។

*(សម្រាករយៈពេលខ្លី)*

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកស្រីអាចចាប់ផ្ដើមទៅលើសំណួរ ដែលមិនមានផលប៉ះពាល់ទៅលើបញ្ហាអង្គហេតុក្រៅតែពីអត្តសញ្ញាណដែរឬទេ? ប្រសិនបើមាននោះ គឺថាយើងត្រូវពិនិត្យមើលទៅលើចំណុចទាំងអស់នេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

<វានឹងផ្អែកទៅលើវិសាលភាពនៃអ្វីដែលគេចាត់ទុកថាជាព័ត៌មានផ្ទាល់ខ្លួន ប៉ុន្តែ>វាពាក់ព័ន្ធនឹងមុខងារ ឬក៏មុខតំណែងរបស់សាក្សីដែលគាត់បានបំពេញនៅក្នុងឆ្នាំ៧៥ ដល់ឆ្នាំ៧៩ <ហើយវាជាមូលហេតុដែលនាំឲ្យគាត់ត្រូវបានកោះហៅ>។ <>គាត់ធ្លាប់ផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១ ជាសាធារណៈរួចមកហើយ។ អ៊ីចឹងវាជាន់គ្នារវាងផលប្រយោជន៍របស់អង្គជំនុំជម្រះ និងផលប្រយោជន៍របស់សហចៅក្រមស៊ើបអង្កេតនោះ។

លោកប្រធាន តើលោកប្រធានត្រូវការសួរសំណួរបឋមទៅកាន់សាក្សីសិន ឬក៏ឲ្យខ្ញុំចាប់ផ្ដើមតែម្តង?

*(សម្រាករយៈពេលខ្លី)*

[១៣:៤៣:០៨]

**ប្រធានអង្គជំនុំ៖**

សួស្ដីលោកសាក្សី នៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ ហើយលោកបានស្នើសុំឲ្យមានមេធាវីប្រឹក្សា ហើយឥឡូវហ្នឹងអង្គជំនុំជម្រះបានចាត់តាំងតាមរយៈអង្គភាពគាំពារសាក្សីអ្នកជំនាញ គឺចាត់តាំងមេធាវីលោកស្រី សុក សុជាតា ជាមេធាវីប្រឹក្សាសាក្សីសម្រាប់ធ្វើសក្ខីកម្មស្តាប់

សក្ខីកម្មរបស់លោក។ ហើយនិង -- ហើយតាមសំណើ នៅក្នុងកិច្ចដំណើរការសវនាការនេះផងដែរ តាមសំណើសុំរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យើងនឹងប្រើប្រាស់តែរហស្សនាមរបស់លោក តែប៉ុណ្ណោះ។ ហើយរហស្សនាមរបស់លោកដែលយើងកំណត់នេះគឺ 2-TCW-859 ហើយជាទូទៅភាគី តែងតែប្រើប្រាស់ហៅលោកថា លោកសាក្សីតែប៉ុណ្ណោះ អ៊ីចឹងហើយសូមលោកយល់ថា អង្គជំនុំជម្រះ នឹងមិនអនុញ្ញាតឲ្យភាគីពាក់ព័ន្ធ រួមទាំងអង្គជំនុំជម្រះខ្លួនឯងប្រើប្រាស់នាមត្រកូល និងនាមខ្លួនរបស់ លោកជាសាធារណៈនៅក្នុងសវនាការនេះទេ។

ហើយមន្ត្រីរដ្ឋបាលតុលាការសូមយកឯកសារ យកឯកសារមួយនេះទៅជូនទៅលោកសាក្សី ដើម្បីពិនិត្យមើលលើត្រង់ចំណុចដែលមាន *ហាយឡាយ*ពណ៌ទឹកក្រូច។

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនសាក្សី)*

[១៣:៤៥:០១]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកសាក្សី ហើយអង្គជំនុំជម្រះសុំឲ្យលោកបញ្ជាក់អំពីអត្តសញ្ញាណរបស់លោកដែល មាននៅក្នុងឯកសារ E3/4593 ដែលមានលេខ ERN ជាភាសាខ្មែរ 00485621, ERN ជាភាសា អង់គ្លេស 00513312 និង ERN ជាភាសាបារាំង 00520455។ សូមលោកសាក្សីពិនិត្យមើលកន្លែង ដែលមាន *ហាយឡាយ*ពណ៌ទឹកក្រូច ថាតើឈ្មោះលោក នាមត្រកូល សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែង កំណើត មុខរបរ ឈ្មោះឪពុក ឈ្មោះម្ដាយ ឈ្មោះប្រពន្ធរបស់លោក និងចំនួនកូនរបស់លោក ពិតជា ត្រឹមត្រូវដែរឬទេ?

លោកសាក្សីគ្រាន់តែឆ្លើយ មើលរួច អានរួច គ្រាន់តែឆ្លើយថា តើការសរសេរនេះពិតជាត្រឹមត្រូវ ឬមិនត្រឹមត្រូវទេ? បើឃើញថា វាមិនត្រឹមត្រូវត្រង់ចំណុចណានោះ គឺសូមប្រាប់ថា មានតែចំណុចមិន ត្រឹមត្រូវ យើងនឹងពិនិត្យលើចំណុចនោះទៀត។ ឧបមាចំណុចឈ្មោះ ឪពុក ឬក៏ចំណុចទីលំនៅសព្វថ្ងៃ ជាដើម។ ហើយបើសិនជាត្រឹមត្រូវហើយ លោកឆ្លើយថា ត្រឹមត្រូវទៅជាការស្រេចហើយ។

**លោក ជួន ធី៖**

**ឆ៖** ខុសឈ្មោះឪពុក គឺអត់ – ឈ្មោះ ឆេ, អត់មាន “ឆេង” ទេ ឈ្មោះ ឆេ។

**ស៖** ទៅបញ្ជាក់គាត់មើលឈ្មោះអី? ឲ្យចប់សិនទៅ។

*(កំពុងពិនិត្យឈ្មោះឪពុករបស់សាក្សី)*

បាទ អរគុណដែលលោកបានបញ្ជាក់ចំណុចនេះ គឺដែលឯកសារដើមគឺ សរសេរដូច្នេះ។ អ៊ីចឹងលោកសូមកែសម្រួលត្រង់ឈ្មោះឪពុករបស់លោកគឺ លុបអក្សរ "ង" នៅខាងចុងចេញ។ អ៊ីចឹងអ្វេ?

[១៣:៤៨:០៩]

**ឆ៖** បាទ។

**ស៖** បាទ អរគុណ។ ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ក៏ដូចជាបុគ្គលទាំងឡាយដែលទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ។ តើរបាយការណ៍នេះ ពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** ពិតជាត្រឹមត្រូវ។

**ស៖** បាទ អរគុណ។ ហើយលោកមុននឹងចូលមកកន្លែងផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែករួចហើយឬនៅ?

**ឆ៖** ធ្វើរួចហើយ។

**ស៖** បាទ អរគុណ។ ហើយជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬសុំឲ្យលោកធ្វើអត្ថាធិប្បាយរៀបរាប់ណាដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សី ត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតប ឬការធ្វើអត្ថាធិប្បាយរបស់លោក នាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អម្បាញ់មិញរួចហើយ។ ហើយក្នុងឋានៈជាសាក្សី លោកត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

តើលោកសាក្សី តើលោកបានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងពេលកន្លងមក? ហើយប្រសិនបើធ្វើ ៗប៉ុន្មានដង?

ធ្វើនៅទីកន្លែងណា?

[១៣:៥០:១៨]

**ឆ៖** ខ្ញុំសូមគោរពដូច្នេះ គឺបានធ្វើ ខ្ញុំបានចូលមកធ្វើនៅកន្លែងនោះម្តង ពីរដងហើយ។

**ស៖** អរគុណ។ ហើយមុននឹងចូលមកចំពោះអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើលឬបានអាននូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុននោះ ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** ខ្ញុំបានមើល និងបានអានហើយ។

**ស៖** តាមសមត្ថភាពដែលលោកអាចដឹងបាន តើលោកអាចបញ្ជាក់បានដែរទេថា កំណត់ស្តាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំនោះ គឺវាពិតជាត្រឹមត្រូវ សមស្របស៊ី សង្វាក់គ្នាទៅនឹងសក្ខីកម្មដែលលោកធ្វើផ្តល់កិច្ចសម្ភាសន៍ ជាមួយនឹងអ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេតនាពេលមុននោះដែរឬទេ?

**ឆ៖** នេះហើយប៉ុន -- បានមើល និងបានអានរួចហើយ ប៉ុន្តែមើលទៅឃើញមានចំណុចខ្លះដែលមិនសមស្រប ត្រង់ៗថា ដែលខ្ញុំនៅកងពលភូមិភាគបស្ចិម កងពលទី១។ ដូច្នេះមានតែកងមកវ៉ៃដែលមកធ្វើការនៅ ដែលព្រំប្រទល់នេះ ដូច្នេះមានកងពលទៅដាក់កងពលប៉ុន្មាន ២២១, ៣៨៨ ដូច្នេះខ្ញុំហើយនិងនោះ ខ្ញុំគ្រាន់តែវាមិនមានអី ដូច្នេះភាគខុសគ្នា ដូច្នេះខ្ញុំមិនស្គាល់អ្នកដឹកនាំគេទេ មិនស្គាល់អីហ្នឹងគេទេ។ ដូច្នេះវាមានឃើញការខុសប្លែកត្រង់ហ្នឹង។

[១៣:៥១:៥៧]

**ស៖** ប៉ុន្តែជាទូទៅគឺលោកយល់ថា លោកឃើញថា កត់សម្គាល់ថា វាសមស្របនឹងអ្វីដែលលោកបានផ្តល់កិច្ចសម្ភាសន៍ពេលមុនហើយ ដែលលោកបានផ្តល់ជាមួយអ្នកស៊ើបអង្កេតមែនទេ?

**ឆ៖** អត់ទាន់មានការសមស្របទេ។

**ស៖** មិនសមស្របយ៉ាងម៉េច? ឥឡូវចង់និយាយថា វាខ្លឹមសារទូទៅ និងទម្រង់ទូទៅដែលលោកផ្តល់សក្ខីកម្មពីពេលមុន លោកអានឯកសារដែលបានផ្តល់ឲ្យលោកអាននេះ តើវាសមស្រប វាប្រហាក់ប្រហែលគ្នាទៅនឹងសក្ខីកម្មដែលលោកផ្តល់ឲ្យពីពេលមុនដែរទេ គ្រាន់តែមានចំណុចតិចតួចដែលវាមានភាពខុសៗពីជាក់ស្តែងដែលលោកបានៗដឹង អ៊ីចឹងមែនទេ?

**ឆ៖** ក្នុងការដែលបទដែលធ្វើពីថ្ងៃមុនដែលមកឆ្លើយថ្ងៃនេះ ឃើញថាមានការខុសដែល -- ត្រឹមត្រូវហើយ តែខុសកន្លែងខ្លះដែលខ្ញុំបានបញ្ជាក់ជូន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី ខៀវ សំផន សួរដេញដោលសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសហមេធាវីការពារក្តី ខៀវ សំផន រួមទាំងមេធាវីការពារក្តីលោក នួន ជា មានរយៈពេលបីវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញ!

[១៣:៥៣:៣២]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានពិនិត្យមើលសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត គឺឯកសារ E319/56 នៅកថាខណ្ឌ៧ ចំណុច "គ" មានការបញ្ជាក់ថា មានករណីលើកលែងចំពោះសាក្សីរូបនេះ<និងសាក្សីផ្សេងៗទៀត ហើយថា អត់មានបញ្ហាអីទេក្នុងការ>ប្រើឈ្មោះគាត់<>។ ខ្ញុំសូមយោងទៅលើ ERN ជាភាសាអង់គ្លេសដើម្បីឲ្យភាគីទាំងអស់អាចរកឃើញ 01321198។ អ៊ីចឹងករណីហ្នឹងក៏អនុវត្តចំពោះ សៅ <សារុន> ដែរ ដែលពេលនោះ គឺសហចៅក្រមស៊ើបអង្កេតអនុញ្ញាតឲ្យបង្ហើបអត្តសញ្ញាណរបស់គាត់បាន។ ខ្ញុំឃើញដូចជាលោកចៅក្រម ឡាវ៉ែន៍ គ្រវីក្បាល ប្រហែលជាគាត់អត់យល់ព្រមជាមួយខ្ញុំ ឬក៏យ៉ាងម៉េច? អ៊ីចឹង<នឹងទុក>ឲ្យលោកចៅក្រមពិនិត្យមើលទៅ<លើការសម្រេចនោះ ប៉ុន្តែខ្ញុំឃើញថា>នៅកថាខណ្ឌ៧ ចំណុច "គ" គឺថាមានករណីលើកលែង អនុញ្ញាតឲ្យបង្ហាញអត្តសញ្ញាណសាក្សីរូបនេះបាន។

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

<ខ្ញុំជឿថាមានសេចក្តីសម្រេច-->

**ប្រធានអង្គជំនុំ៖**

អញ្ជើញ! អញ្ជើញលោក វ៉ិចទ័រ កូប៉េ!

[១៣:៥៤:៥៦]

**លោក វ៉ិចទ័រ កូប៉េ៖**

បន្ថែមលើចំណុចនេះលោកប្រធាន ប្រសិនបើអនុញ្ញាត។ ភស្តុតាងចេញពីសាក្សីរូបនេះ ដែលយើងបានរាប់ពិនិត្យមើលត្រូវបានប្រើប្រាស់១៩ដងនៅក្នុងសេចក្តីសម្រេច ឬសាលក្រមជាសាធារណៈ។

បន្ថែមពីនេះ សាក្សីនេះបានផ្តល់សក្ខីកម្មជាសាធារណៈ។ ដូច្នេះហើយយើងសន្មតថា យើងមិនអាចយោងទៅលើកាលបរិច្ឆេទ<ពិតប្រាកដ>នៃការផ្តល់សក្ខីកម្មរបស់គាត់ទេ នៅពេលដែលមានកត់ត្រានៅក្នុងប្រតិចារឹក ឬយ៉ាងម៉េច? តើយើងអាចទេ? បើសិនជាមិនអាចទេ វាជាករណីចម្លែក។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

នេះជាប្រភេទ "ក"។ ហើយយើងដឹងហើយថា យើងប្រើតែរហស្សនាម មិនប្រើឈ្មោះនោះទេ។ សេចក្តីសម្រេច ឬសាលក្រមនោះ គឺដូចដែលលោកបានលើកឡើងនោះគឺខ្ញុំនឹងពិនិត្យ ប៉ុន្តែយើងបានកំណត់នៅក្នុងហ្នឹងហើយចំពោះសាក្សីមួយចំនួន។

**កញ្ញា អង់តា ហ្គីសសេ៖**

ឯកសារដែលខ្ញុំដកស្រង់ហ្នឹង មិនមែនជាសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទេ <ប៉ុន្តែ>ជាសំណើរបស់សហព្រះរាជអាជ្ញា ដែលដកស្រង់នូវអនុសាសន៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ អ៊ីចឹងប្រហែលជាខាងសហព្រះរាជអាជ្ញាអាចបំភ្លឺត្រង់ចំណុចនេះបាន។ ខ្ញុំយល់ថា សំណើរបស់សហព្រះរាជអាជ្ញាហ្នឹង គឺលេខ E319/56ហ្នឹង គាត់បានដកស្រង់អនុសាសន៍របស់សហចៅក្រមស៊ើបអង្កេត ហើយក្នុងនុំងមានបញ្ជាក់ថា គឺអាចលើកលែងបានចំពោះសាក្សី<ជាក់លាក់មួយចំនួន រួមបញ្ចូលទាំងសាក្សី>រូបហ្នឹង គឺជាភាសាអង់គ្លេស ERN គឺ 01321198។

[១៣:៥៦:៥៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ យើងហាក់ដូចជាបង្ហាញថា សាក្សីហ្នឹងជាករណីលើកលែង។ ក៏ប៉ុន្តែខ្ញុំត្រូវការពេលវេលា២នាទី ហើយនិងពិនិត្យមើលដីកាសម្រេចចេញពីចៅក្រមស៊ើបអង្កេតដើម្បីបញ្ជាក់ចំណុចហ្នឹងបាន។ មេធាវីបានលើកឡើងត្រឹមត្រូវ ដែលថានៅក្នុងឯកសារដែលយើងបានដាក់នេះ វាហាក់ដូចជាសាក្សីនេះគឺជាករណីលើកលែង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងដឹងហើយថា មានពេលមួយនោះ មានការកំណត់ដោយចៅក្រមស៊ើបអង្កេតទៅលើប្រភេទនៃសាក្សី<ដោយនិយាយថា "ចាប់ពីពេលនេះទៅ មានតែប្រភេទ ក">។ ប្រសិនបើប្រភេទ <ក>អ៊ីចឹង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មែន គឺបានន័យថា យើងមិនអាចប្រើឈ្មោះបាននោះទេ អាចប្រើតែរហស្សនាមតែប៉ុណ្ណោះ ក៏ប៉ុន្តែយើងចាំមើលការបញ្ជាក់របស់សហព្រះរាជអាជ្ញាសិន។ យើងមិនដឹងថា តើសាក្សីរូបនេះបានបញ្ជាក់នៅក្នុងប្រភេទសាក្សីដែលមានអាទិភាពខ្ពស់ ឬក៏យ៉ាងណានោះទេ។

[១៣:៥៨:០០]

**កញ្ញា អង់តា ហ្គីសសេ៖**

បញ្ហាឈ្មោះហ្នឹងមិនមែនជារឿងសំខាន់សម្រាប់ខ្ញុំទេ គឺខ្ញុំផ្តោតទៅលើបញ្ហាមុខងាររបស់គាត់មុខ គឺយើងកោះហៅគាត់មកហ្នឹង ដោយសារតែមុខតំណែងគាត់នៅសម័យនុ៎ងហើយ។ អ៊ីចឹងខ្ញុំអាចប្រាប់មុខងារបាន ឬក៏អត់?

**ប្រធានអង្គជំនុំ៖**

ដូចជាបទប្បញ្ញត្តិ ដែលលើកឡើងអំមិញ តែរឿងត្រឹមប្រើប្រាស់រហស្សនាម វាមិនប្រើឈ្មោះប្រើនាមគាត់ប៉ុណ្ណឹងទេ។ បញ្ហាផ្សេងទៀត គឺអត់មានហាមទេ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សីជម្រាបសួរ។ សូមអភ័យទោសផង ដែលមានការពិភាក្សាគ្នាទៅវិញទៅមកនេះ។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំមានសំណួរចំនួនសួរទៅកាន់លោក ជាពិសេសពាក់ព័ន្ធនឹងបទពិសោធន៍របស់លោកក្នុងពេលដែលលោកវាយប្រយុទ្ធជាមួយកងទ័ពវៀតណាមក្នុងឋានៈលោកជាទាហាន។ លោកបានផ្តល់សក្ខីកម្មរួចមកហើយនៅចំពោះមុខអង្គជំនុំជម្រះនេះ រូបនេះ នៅក្នុងសំណុំរឿង០០២/០១។ អ៊ីចឹងខ្ញុំព្យាយាមសួរតែសំណួរបន្ថែម មិនសួរសំណួរដដែលទេ។ សុំជម្រាបផងដែរថា សុំឲ្យលោករៀបរាប់អំពីខ្សែជីវិតជាយោធារបស់លោកជូនអង្គជំនុំជម្រះ។ អ៊ីចឹងឥឡូវខ្ញុំសុំចាប់ផ្តើមអ៊ីចេះ នៅក្នុងសំណុំរឿង០០២/០១ លោកបាននិយាយថាលោកចូលបដិវត្តន៍ជាយុទ្ធជនធម្មតា ក្រោយមកគេដំឡើងឋានៈរបស់លោក។ អ៊ីចឹងលោកអាចរៀបរាប់រំឭកជូនអង្គជំនុំជម្រះឡើងវិញ ថាតើលោកបានតំណែងអ្វីខ្លះនៅក្នុងចន្លោះពីឆ្នាំ៧៥ រហូតទៅដល់ឆ្នាំ៧៩ ពេលដែលវៀតណាមវាយចូលកម្ពុជា?

[១៤:០០:១២]

**លោក ជួន ធី៖**

**ឆ៖** ខ្ញុំសូមគោរព។ ហើយបញ្ហានេះ ខ្ញុំបានបញ្ជាក់ជូនជាលើកទី១រួចមកហើយ អំពីតួនាទី និងតំណែងរបស់ផងខ្ញុំ។ ដូច្នេះខ្ញុំក៏គ្មានអីបញ្ជាក់ថែមដែរ ព្រោះបញ្ជាក់រួចមួយសាហើយ។

**ស៖** ខ្ញុំនឹងព្យាយាមសួរបញ្ជាក់ឱ្យបានច្បាស់ជាងនេះ។ អ៊ីចឹងត្រឹមត្រូវទេ ៤ខែក្រោយពីរំដោះទីក្រុងភ្នំពេញបាន គេដំឡើងឋានៈលោកជាមេបញ្ជាការវរសេនាតូច? ខ្ញុំសូមយោងទៅសវនាការថ្ងៃទី២៤ មេសា ឆ្នាំ២០១៣ គឺម៉ោងប្រហែលជា១១:៤២:០៣វិនាទី។

**ឆ៖** ក្រោយពីរំដោះបានប្រហែលបីបួនខែហ្នឹង ខ្ញុំបានគេដំឡើងជាឋានៈជាវរសេនាតូចមែន។

**ស៖** នៅសវនាការនៃសំណុំរឿង០០២/០១ដដែល លោកបានឆ្លើយថា ក្រោយពីរំដោះទីក្រុងភ្នំពេញបាន លោកធ្វើស្រែនិងជួសជុលផ្លូវ។ ហើយនៅឆ្នាំ១៩៧៨ បានគេចាត់តាំងឱ្យលោកទៅព្រំដែននៅស្វាយរៀង គឺនៅខែមិថុនា ឆ្នាំ១៩៧៨។ អ៊ីចឹងខ្ញុំរៀបរាប់អ៊ីចឹង ត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[១៤:០២:២៨]

**ស៖** នៅក្នុងសវនាការដដែលនោះ លោកក៏បាននិយាយអំពីពេលដែលលោកត្រូវបានគេបញ្ជូនទៅស្វាយរៀង។ ហើយលោកបាននិយាយថា មានការប្រជុំមួយនៅកំពង់ឆ្នាំង។ ខ្ញុំសុំយោងទៅលើសវនាការដដែល គឺថ្ងៃទី២៤ ខែមេសា គឺនៅម៉ោង ០៩:៤៦នាទី លោកថា ក្នុងពេលប្រជុំនោះ ប៉ុល ពត បាននិយាយក្នុងឋានៈជាអគ្គលេខាធិការបក្សកុម្មុយនីស្តកម្ពុជា ហើយលោកថា លោកបាននិយាយជាមួយ ប៉ុល ពត ហើយគាត់ប្រាប់លោកឱ្យទៅស្វាយរៀងឱ្យបានឆាប់។ អ៊ីចឹងលោកនឹកឃើញទេ ត្រង់ចំណុចនេះ?

**ឆ៖** ខ្ញុំនឹកឃើញ ហើយពិត។

**ស៖** នៅពេលនោះ លោកអាចជម្រាបបានទេ អ្នកណាជាមេផ្ទាល់របស់លោក?

**ឆ៖** គឺមេផ្ទាល់របស់ខ្ញុំ គឺឈ្មោះពេទ្យ សឿង កងពល ៗទី១។

**ស៖** សំណួរខ្ញុំច្បាស់ជាងអ្វីដែលលោកបានឆ្លើយនៅក្នុងសំណុំរឿង០០២/០១ គឺខ្ញុំចង់ដឹងថា ពេលប្រជុំមួយនោះ ឬក៏មុនពេលទៅស្វាយរៀង តើលោកធ្លាប់ទទួលបានព័ត៌មានលម្អិត ពាក់ព័ន្ធនឹងស្ថានភាពដែលលោកនឹងត្រូវជួបប្រទះ នៅពេលដែលលោកទៅដល់ស្វាយរៀងទេ?

**ឆ៖** មុននឹងពេលទៅ -- សួរ សូមសួរសំណួរហ្នឹងម្តងទៀត ខ្ញុំស្តាប់មិនទាន់។

**ស៖** មិនជាបញ្ហាអ្វីទេ។ លោកឆ្លើយថា លោកបាននិយាយជាមួយ ប៉ុល ពត ហើយ ប៉ុល ពត

ប្រាប់លោកឲ្យទៅស្វាយរៀង។ អ៊ីចឹងខ្ញុំចង់ដឹងថា នៅពេលដែលលោកនិយាយគ្នាជាមួយ ប៉ុល ពត ឬក៏ នៅពេលដែលលោកនិយាយជាមួយ តាសឿង ជាដើមហ្នឹង មាននរណានិយាយប្រាប់លោក អំពីស្ថាន-ភាពដែលកើតមាននៅស្វាយរៀងទេ មុនពេលលោកទៅនោះ?

[១៤:០៥:០៩]

**ឆ៖** ខ្ញុំបានទទួលការនិយាយហ្នឹងហើយ ដូច្នេះបានយកទ័ពទៅស្វាយរៀង។ ដូច្នេះអត់មានដែលបានឮអ្នកណានិយាយអាម៉េចទេ គឺគ្រាន់តែប្រាប់ថា យួនចូលមកដល់ស្វាយរៀងហើយ។ ដូច្នេះឲ្យខ្ញុំយកទ័ពទៅការពារនៅព្រំដែន។

**ស៖** លោកឆ្លើយថា ពេលនុំងៗ លោកអាចបញ្ជាក់ឲ្យច្បាស់បន្តិចបានទេ? លោកដឹងសភាពការណ៍នៅស្វាយរៀងហ្នឹង គឺទាល់តែលោកទៅដល់ស្វាយរៀងតែម្តង ឬក៏ពេលដែលលោកជួប ប៉ុល ពត ហ្នឹង ប៉ុល ពត ប្រាប់លោកឲ្យដឹងជាមុនបាត់ទៅហើយ អំពីសភាពការណ៍ដែលកើតមាននៅស្វាយរៀង ហើយលោកត្រូវប្រមូលកម្លាំងទៅកន្លែងនុំង?

**ឆ៖** គឺ ប៉ុល ពត ហៅខ្ញុំទៅជួប ហើយប្រាប់សភាពការណ៍នៅព្រំដែនយ៉ាងម៉េច អីយ៉ាងម៉េចរួចអស់ហើយ បានឲ្យខ្ញុំរៀបចំកម្លាំងទ័ពទៅការពារនុំង។

**ស៖** *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអធ្យាស្រ័យដែលខ្ញុំកាត់។ អ្វីដែលខ្ញុំបានបញ្ជាក់អម្បាញ់មិញ ហើយខ្ញុំបានពិនិត្យមើលទៅការអនុញ្ញាតពីចៅក្រមស៊ើបអង្កេត ជាការពិតទៅ មានការកំណត់ជាក់លាក់ចំពោះសាក្សីរូបនេះ <និងសាក្សីពីរ<ឬបី>នាក់ទៀតថា> "គ្មានវិធានការណាមួយតម្រូវឲ្យដាក់កំណត់ទៅលើអត្តសញ្ញាណរបស់សាក្សីរូបនេះនោះទេ។" ដូច្នេះនៅក្នុងដីកាសម្រេចរបស់ចៅក្រមស៊ើបអង្កេត មិនមានការកំណត់លក្ខខណ្ឌដែលថា ត្រូវរក្សាឈ្មោះសាក្សីរូបនេះជាសម្ងាត់នោះទេ។ <នេះគឺជាសេចក្តីសម្រេចមកពីសំណុំរឿង០០៣> គឺឯកសារ <D132> កថាខណ្ឌ៥៤ និង<៥៧(ឃ)>។ នេះជាចំណុចយោងសម្រាប់លោកចៅក្រមពិនិត្យមើល។

[១៤:០៧:២៥]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដូច្នេះបានន័យថា មិនយោងទៅលើ<កថាខណ្ឌ (ខ)>ឯកសារ <319/35> នៅក្នុងប្រភេទ(ខ) ដែលថាសាក្សីទាំងអស់នោះត្រូវការនូវវិធានការ<ការពារបន្ថែមដើម្បី>រក្សាការសម្ងាត់។ អ៊ីចឹងបានន័យថា សាក្សី<ទាំងឡាយណាដែល>មិនស្ថិតនៅក្នុងប្រភេទ(<ក>) នោះទេ មែនដែរទេ?

**លោក ឌេល លីសាក់៖**

អត់ទេ។ <នៅក្នុងសេចក្ដីសម្រេចនោះនិយាយថា> ចំពោះសាក្សីដទៃៗទៀត គឺ<ពួកគេចាំបាច់>នៅក្នុងប្រភេទ(ក) ដែលថាមិនអាចប្រើឈ្មោះបាន ក៏ប៉ុន្តែសាក្សីរូបនេះជាការលើកលែងសម្រាប់គាត់ ដែលយើងអាចប្រើឈ្មោះបាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ លោកសហព្រះរាជអាជ្ញារង សូមលោកនិយាយលេខឯកសារហ្នឹងម្ដងទៀតមើល ខ្ញុំឮ D4 យ៉ាងម៉េច ដូចស្ដាប់មិនទាន់។ <តើវាពិតជា D4 មែន ឬក៏វាជាឯកសារយោងមួយផ្សេងទៀត?>

[១៤:០៨:២៨]

**លោក ឌេល លីសាក់៖**

<លោកចៅក្រម> ខ្ញុំមើលដីកាសម្រេចនៅក្នុងសំណុំរឿង<០០៣>។ អ៊ីចឹងគឺឯកសារហ្នឹងមានលេខសម្គាល់ “D” ចេញពីសំណុំរឿង០៣។ ខ្ញុំដឹងថា យើងធ្លាប់បានផ្ដល់ជូនចៅក្រមអំពី នូវដីកាសម្រេចនោះ។ ខ្ញុំបានពិនិត្យមើលដីកាហ្នឹង ថាតើវាមានលេខសម្គាល់ផ្សេងទៀត<នៅក្នុងសំណុំរឿង ០០២>ដែរឬទេ ក៏ប៉ុន្តែ<ខ្ញុំចង់ឲ្យលោកចៅក្រមដឹងដែរថា យ៉ាងហោចណាស់>ដីកា<សម្រេចនេះគឺមានលក្ខណៈច្បាស់លាស់ណាស់អំពីបញ្ហា>នេះ <ហើយខ្ញុំសន្និដ្ឋានថា យើងបានរក្សា>ការអនុវត្តរបស់យើង<ក្នុងការផ្ដល់សិទ្ធិដល់សេចក្ដីសម្រេច ក៏ប៉ុន្តែពេលនេះយើងអត់មាន>លេខឯកសារទៅតាមសំណុំរឿងដែលបានកំណត់<នោះទេ គឺសំណុំរឿង០០២>។

**កញ្ញា អង់តា ហ្គីសសេ៖**

ដូច្នេះអ្វីៗគឺច្បាស់លាស់អស់ហើយ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី សូមអភ័យទោសដែលមានការកាត់ផ្តាច់ជាថ្មីម្តងទៀត។ លោកឆ្លើយថា លោកបានប្រជុំខ្លីជាមួយ ប៉ុល ពត ដែលគាត់ពន្យល់ពីសភាពការណ៍ប្រាប់លោក។ អ៊ីចឹងពេលប្រជុំនោះ តើ តាសឿង មានវត្តមានទេ? ហើយ សុន សេន វិញ តើគាត់មានវត្តមានដែរឬទេ?

**លោក ជួន ធី៖**

**ឆ៖** បាទ គឺប្រជុំនោះគឺមាន ៗខ្ញុំផង ហើយនិង តាសឿង នោះផង ហើយឯ សុន សេន និង ផ្សេងទៀត ខ្ញុំពេលនោះ អត់ ខ្ញុំអត់ទាន់ដែលស្គាល់ទេ ហើយ តាប៉ុល ពត ក៏ទើបស្គាល់ពេលនុ៎ងដែរ។

[១៤:១០:១៥]

**ស៖** ដូច្នេះពេលដែលលោកនិយាយជាមួយ ប៉ុល ពត និង តាសឿង ក្នុងពេលប្រជុំហ្នឹង។ <តើគេមានបានសង្ខេបប្រាប់លោក>អំពី<ប្រវត្តិនៃ>ការវាយប្រយុទ្ធផ្សេងៗដែលបានកើតឡើង មុនពេលដែលលោកទៅដល់ស្វាយរៀងទេ?

**ឆ៖** ពេលនោះគ្រាន់តែដឹងថា គាត់ក៏អត់ដឹងទេ គ្រាន់តែដឹងថា យួនចូលមកដល់ស្វាយរៀងហើយ។ ដូច្នេះឲ្យខ្ញុំយកទ័ពទៅ រៀបចំទប់ទល់ ដឹងតែប៉ុណ្ណឹង។

**ស៖** លោកបានឆ្លើយថា លោកប្រមូលកូនទាហានរបស់លោកទៅស្វាយរៀង។ អ៊ីចឹងលោកអាចបញ្ជាក់ចំនួនបានទេ ថាលោកប្រមូលបានកូនទាហានប៉ុន្មាន? ហើយលោកយកមកពីកន្លែងណាខ្លះដើម្បីយកទៅស្វាយរៀងហ្នឹង?

**ឆ៖** ខ្ញុំប្រមូលទាហាននោះ បានបីវរសេនាតូច ដូច្នេះប្រហែលជាជិត១.០០០នាក់ គឺអង្គភាពខ្ញុំដែលខ្ញុំគ្រប់គ្រងផ្ទាល់ហ្នឹងហ្មង។

**ស៖** លោកធ្វើយ៉ាងម៉េច ដើម្បីទៅប្រមូលទាហានទាំងអស់នុ៎ង <ហើយតើលោក>ទៅស្វាយរៀង<ដោយវិធីណា?>?

**ឆ៖** ព្រោះអង្គភាពមួយៗ សុទ្ធតែមានអ្នកដឹកនាំ មានកម្មាភិបាល ដូច្នេះប្រាប់កម្មាភិបាលគេទៅ ហៅមកជួបជុំ ឲ្យមកជួបជុំគ្នា កំណត់ពេលវេលាទៅ និងទីកន្លែង ហើយ។

**ស៖** លោកទាក់ទងជាមួយនឹងកម្មាភិបាលដែលគ្រប់គ្រងទាហានទាំងអស់ហ្នឹងយ៉ាងម៉េច? លោកធ្វើទូរលេខ ឬក៏លោកធ្វើជាសារ ឬក៏ធ្វើយ៉ាងម៉េច? ហើយកងវរសេនាតូចផ្សេងៗហ្នឹង ឈរជើងនៅកន្លែងណាខ្លះ?

01376821



[១៤:១២:៥៦]

**ឆ៖** វរសេនាតូចដែលទាក់ទងគ្នាបាន ដោយតាមការហៅប្រាប់នីរសារ ដូច្នេះពេលនោះមិនមានស្ទីទាក់ទងសំខាន់ទេ ខាងវិទ្យុអី អត់មានទេ។ ដូច្នេះឲ្យតាមកន្លែងមួយៗ មាននីរសារ មានអីគេហ្នឹងឲ្យទៅហៅ ទៅប្រមូលមក ជួបជុំគ្នា។ ហើយកងទ័ពពេលនោះ គឺនៅធ្វើការតាមផ្លូវលេខ៤នោះ តាំងពីវាលរេញមករហូតមក ស្ទឹងច្រាល់នេះ ស្ទឹងសំរោងអីនេះ។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក នៅចំពោះសហចៅក្រមស៊ើបអង្កេត ឯកសារ E3/4593 នៅចម្លើយទី១៤ លោកបានឆ្លើយដូចតទៅ៖ "ភ្លាមនោះ ខ្ញុំបានជិះឡានឡង់រ៉ូវែតម្រង់ឆ្ពោះទៅព្រៃនប់ និងកោះកុង ដើម្បីប្រមូលកម្លាំង។ ការទៅប្រមូលកម្លាំងនោះ គឺជិះឡានផង ជិះកាណូតផង។ វេលាម៉ោងប្រាំមួយព្រឹក កម្លាំងរបស់ខ្ញុំចំនួនជាង១០ឡាន ហ្សេ.អឹម.សេ បានចេញពីព្រៃនប់ ឆ្ពោះទៅស្វាយរៀង ដោយកាត់តាមភ្នំពេញ។ យើងមិនបានឈប់នៅភ្នំពេញទេ គឺទៅដល់ស្វាយរៀងប្រហែលម៉ោងពីរកន្លះព្រឹក។" សូមបញ្ចប់ការដកស្រង់។ តើចម្លើយនេះ វាត្រឹមត្រូវទៅនឹងអ្វីដែលលោកបានធ្វើនៅពេលនុ៎ងទេ? ហើយកម្លាំងដែលលោកទៅប្រមូលនោះគឺមានឈរជើងនៅព្រៃនប់ និងកោះកុងមែនទេ?

**ឆ៖** ខ្ញុំសូមឆ្លើយ ចំពោះសំណួរហ្នឹងគឺត្រូវមួយចំនួន តែខុសមួយចំនួនត្រង់ថា រឿងខ្ញុំទៅយកពួកទ័ពខ្ញុំ អត់មាននៅកោះកុងទេ នៅម្តុំព្រៃនប់ វាលរេញ ស្រុកព្រៃនប់ហ្នឹង វាលរេញទេ។ គឺអត់មានជិះកាណូតទៅយកទេ ខ្ញុំអត់មានឆ្លើយ កាលនុ៎ងអត់មាន គឺបដិសេធ។ ហើយទៅយកមកហ្នឹង គឺបានជួបជុំគ្នាហើយ គឺម៉ោងប្រាំមួយព្រឹក គឺចេញដំណើរការមកៗស្វាយរៀងហ្នឹងបណ្តោយ។

[១៤:១៥:២៥]

**ស៖** តើលោកអាចរៀបរាប់អំពីសភាពការណ៍ នៅពេលដែលលោកទៅដល់ស្វាយរៀងភ្លាមបានទេ?

**ឆ៖** គ្រាន់តែ -- ជម្រាបបាន។ គ្រាន់តែទៅដល់ស្វាយរៀង គឺមាន គឺទៅដល់នុ៎ង គឺគេចង្អុលប្រាប់ថា ចង្អុលសមរភូមិឲ្យចូលទៅតែម្តង គឺនៅតាមព្រំដែនហ្នឹងបណ្តោយ គឺដឹងតែប៉ុណ្ណឹង។ ទៅដល់គឺរៀបចំធ្វើ មានបានសម្រាកអី ទៅដល់រៀបចំដឹកត្រង់សេ ដឹកអី នៅព្រំប្រទល់ហ្នឹងតែម្តង។

**ស៖** តាមរយៈការបកប្រែជាភាសាបារាំងហ្នឹង ខ្ញុំឮថា "គេចង្អុលបង្ហាញសមរភូមិមកខ្ញុំ"។ លោកអាចជម្រាបបានទេ អ្នកណាជាអ្នកចង្អុលបង្ហាញសមរភូមិប្រាប់លោកនោះ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** អ្នកចង្អុលសមរភូមិប្រាប់ខ្ញុំពេលនោះ គឺៗឈ្មោះ រ៉ែន – ឈ្មោះ តារ៉ែន ដែលកូនប្រសា តាម៉ុក នោះ។

**ស៖** លោកអាចបញ្ជាក់មុខងាររបស់ រ៉ែន ហ្នឹងបានទេ គាត់ធ្វើអ្វីដែរ?

**ឆ៖** ខ្ញុំទៅដល់ ឮគាត់ថាធ្វើ គេទទួលខុសត្រូវរួមនៅសមរភូមិនៅស្វាយរៀងហ្នឹង មិនដឹងគេទទួលខុសត្រូវនៅស្វាយរៀង សមរភូមិហ្នឹង ទ័ពដែលទៅប៉ុន្មាន គឺគាត់គ្រប់គ្រងចាត់ចែង។

**ស៖** ដូច្នេះពេលដែលលោកទៅដល់ហ្នឹង គឺលោកស្ថិតនៅក្រោមបញ្ជារបស់គាត់មែនទេ?

**ឆ៖** ហ្នឹងហើយនៅក្រោមបញ្ជារបស់គាត់។

[១៤:១៧:៤១]

**ស៖** លោកពេលទៅដល់ស្វាយរៀងហ្នឹង ហើយលោកស្ថិតនៅក្នុងវរសេនាធំ វរសេនាតូចលេខប៉ុន្មាន? វរសេនាធំលេខប៉ុន្មាន? ហើយកងពលលេខប៉ុន្មាន? ហើយ តាសឿង ហ្នឹងក៏នៅតែជាមេរបស់លោកដដែល ឬក៏ពេលទៅដល់ស្វាយរៀងហ្នឹងលោកដូរមេថ្មី?

**ឆ៖** ខ្ញុំទៅដល់ស្វាយរៀង គឺពួក តាសឿង ហ្នឹងគាត់ដូចអត់ឃើញគាត់ទៅទៀតផង ដូច្នេះមានតែ តារ៉ែន ទេចាត់ចែងហ្នឹង។ ដូច្នេះដូចៗដូរមេហើយដល់អ៊ីចឹងនោះ ព្រោះអត់ដែលឃើញផង តាសឿង ហ្នឹង។

**ស៖** ក្រៅពី រ៉ែន លោកមានបានឃើញទាហានណាផ្សេងណាទៀត ឬក៏មេណាផ្សេងទៀតទេ? ហើយនៅពេលដែល រ៉ែន មកទទួលលោកហ្នឹងពេលលោកទៅដល់ស្វាយរៀងហ្នឹង គាត់មានកូនទាហានមកជាមួយទេ?

**ឆ៖** ដូចអារឿងដែលពេលខ្ញុំទៅដល់ស្វាយរៀង ពេលដែល រ៉ែន ហ្នឹងមកជួបខ្ញុំប្រាប់គ្រាន់ឃើញនេះមកហ្នឹង ចង្អុលប្រាប់ថាទៅរៀបចំនៅកន្លែងនេះ ចង្អុលពីទិស ខ្វែងខ្វាត់ ចង្អុលទិសដៅទៅ ខ្ញុំទៅធ្វើទៅ ត្រង់មកឃើញមានកម្លាំងពីរបីនាក់មកជាមួយនេះដែរ។

**ស៖** លោកនិយាយថា មានកម្លាំងពីរបីនាក់មកហ្នឹង លោកអាចជម្រាបបានទេអ្នកណាខ្លះ? ហើយមានមុខងារអ្វីខ្លះដែរ?

**ឆ៖** កម្លាំងពីរបីនាក់ដែលមកជាមួយហ្នឹងគឺខ្ញុំអត់ស្គាល់ទេ ហើយក៏មិនដឹងជាមានតួនាទីអីដែរនៅពេលនោះ រ៉ែន ក៏ខ្ញុំមិនដែលស្គាល់ទេ ទើបជួបហ្នឹងទេ គ្រាន់តែគេប្រាប់ថា ហ្នឹងហើយឈ្មោះ រ៉ែន ទទួលខុសត្រូវនៅសមរភូមិហ្នឹង។ ខ្ញុំគ្រាន់តែដឹងប៉ុណ្ណឹង។

[១៤:១៩:៥២]

**ស៖** លោកឆ្លើយថា ពេលដែលលោកទៅដល់ គេបញ្ជាឲ្យលោកជីកត្រង់សេ លោកអាចបញ្ជាក់បានទេថា លោកទៅដល់បានប៉ុន្មានថ្ងៃ បានលោកចាប់ផ្ដើមប្រយុទ្ធគ្នាជាមួយនឹងទាហានវៀតណាម?

**ឆ៖** ខ្ញុំទៅដល់ជីកត្រង់សេហើយៗ ក៏ត្រៀមចាំហ្នឹង បើកាលណាទ័ព កងទ័ពយួនចូលមកទឹកដីរបស់ខ្ញុំ គឺអាហ្នឹងបានខ្ញុំការពារទៅ បើគេអត់ចូល ខ្ញុំអត់នេះដែរ អត់ប្រយុទ្ធដែរ។

**ស៖** លោកថា មានកងទ័ពចូលលុកលុយក្នុងទឹកដីខ្មែរ។ អ៊ីចឹងពេលដែលលោកនិយាយគ្នាជាមួយ រ៉ែន ហ្នឹង រ៉ែន មានបានប្រាប់ទេថា វៀតណាមហ្នឹង លុកលុយចូលចុងក្រោយគេបំផុតហ្នឹងនៅពេលណាដែរ?

**ឆ៖** អត់មានប្រាប់។ អត់មាន -- រ៉ែន ហ្នឹងអត់មានប្រាប់ថា យួនចូលមកទឹកដីយើងនៅពេលណាគឺអត់ដឹងទេ។ តែបើសិនជាវាមានចូល គឺយើងត្រូវតែការពារ។ អាហ្នឹងគ្រាន់តែបញ្ជាក់ប៉ុណ្ណឹងរៀបចំកម្លាំង។

**ស៖** ពេលដែលលោកទៅដល់ តើលោកមានឃើញប្រជាជនស៊ីវិលនៅស្វាយរៀងទេ?

**ឆ៖** កាលខ្ញុំទៅដល់ហ្នឹង គឺប្រជាជននៅស្វាយរៀង អត់មានឃើញទេ មានឃើញតែកងទ័ពដែលនេះហ្នឹងទេ អត់មានឃើញប្រជាជន តែម្នាក់ក៏អត់មានផង។

**ស៖** លោកដឹងទេថា ពេលណាដែលប្រជាជនត្រូវបានគេជម្លៀសចេញពីស្វាយរៀង? លោកមានបានទទួលព័ត៌មានហ្នឹងទេ ពេលដែល ប៉ុល ពត គាត់បានប្រជុំខ្លីជាមួយលោកហ្នឹង?

**ឆ៖** ពេលដែលជួបជាមួយ ប៉ុល ពត គាត់អត់មានបានបញ្ជាក់ពីរឿងប្រជាជនចេញថ្ងៃណាខែណាទេ គ្រាន់តែប្រាប់ថា ឥឡូវយួនចូលមកដល់ស្វាយរៀងហើយ ឲ្យខ្ញុំនាំទ័ពទៅទប់ទល់ប៉ុណ្ណឹង មានប្រាប់តែប៉ុណ្ណឹង។

[១៤:២២:៥២]

**ស៖** ខ្លួនលោកផ្ទាល់ លោកថា លោក<បានទៅដល់ជាមួយ>កូនទាហានប្រហែលជា១.០០០នាក់។ អ៊ីចឹងលោកចាំទេថា តើមានកង<ពល>តូច ឬក៏កងវរសេនាធំអ្វីខ្លះដែលប្រចាំការនៅស្វាយរៀងនោះ?

**ឆ៖** វរសេនាតូច និងវរសេនាធំ ដែលប្រចាំការនៅស្វាយរៀង ខ្ញុំក៏មិនចាំឈ្មោះដែរ តែគ្រាន់ភាគច្រើនក៏អត់មានឃើញទៀតផង ឥឡូវមិនដឹងស្លាប់ ឬក៏រស់ ទៅណាអស់ហើយ អត់មានឃើញទៀត

ផង ហើយក៏ចាំឈ្មោះមិនអស់ដែរ វាភ្លេចអស់ហើយ យូរហើយ។

**ស៖** ខ្ញុំដឹងហើយថាលោកពិបាកនឹងចាំលម្អិតណាស់ អ៊ីចឹងខ្ញុំសូមព្យាយាមរំឭកការចងចាំរបស់លោក។ នៅក្នុងឯកសារ E3/4593 នៅចម្លើយទី១៥ លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ "រ៉ន ទទួលបន្ទុកក្ដាប់រួមកងទ័ពនៅស្វាយរៀង ដែលពេលនោះគាត់ជាមេបញ្ជាការកងពលធំ។ កងពលដែលស្ថិតនៅក្រោមបញ្ជាកងពលធំ មានកងពលតូច៧០៣ ដែលមាន ស៊ុង មកពីនិរតីជាមេបញ្ជាការ, កងពលតូច៣៤០ មានខ្ញុំជាមេបញ្ជាការ និង ធី ពូសសេ ជាមេបញ្ជាការរង។" ខ្ញុំសូមបញ្ចប់ត្រឹមហ្នឹង ពីព្រោះថា នៅពេលដែលលោកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកថាកន្លែងហ្នឹងមានកំហុស។ លោកថាអ្នកដែលជាមេបញ្ជាការកងពលតូចហ្នឹង គឺ៣៤០ហ្នឹងគឺពី ធី ពូសសេ ទេ ហើយលោកទេជាមេបញ្ជាការរង។ តើចំណុចហ្នឹងត្រឹមត្រូវទេ? លោកអាចបញ្ជាក់ចំណុចហ្នឹងឡើងវិញម្ដងទៀតបានទេ? ធី ពូសសេ ហ្នឹងជាមេបញ្ជាការ ហើយលោក<ជា>មេបញ្ជាការរងមែនទេ?

[១៤:២៥:២៧]

**ផ៖** ធី ពូសសេ ជាបញ្ជាការ ខ្ញុំជាបញ្ជាការរង មែន។

**ស៖** ខ្ញុំបានលើកឡើងអំពីកងពលតូច៧០៣ ដែលមាន ស៊ុង ជាមេបញ្ជាការ។ លោកចាំត្រង់ចំណុចហ្នឹងឡើងវិញទេ?

**ផ៖** ខ្ញុំចាំគ្រាន់តែពួគេប្រកាសទេ ប៉ុន្តែអត់ដែលស្គាល់ឈ្មោះហ្នឹងផង ហើយ៧០៣ក៏ខ្ញុំអត់ដែលបានឃើញដែរ។ គ្រាន់តែគេជួបជុំ ពួគេប្រកាសអ៊ីចឹង ដូចថាមាន ស៊ុង នៅក្ដាប់៧០៣អ៊ីចឹង គ្រាន់ពួគេថាអ៊ីចឹង អត់ស្គាល់មនុស្សហ្នឹងឈ្មោះអាម៉េច មុខអាម៉េច។

**ស៖** ខ្ញុំសូមបន្តអានចម្លើយទី១៥ របស់លោកតទៅទៀត។ លោកក៏បានលើកឡើង<ថា> "កងពល៤៦០ មាន ផន មកពីនិរតីជាមេបញ្ជាការ សួយ ជាមេបញ្ជាការរង។" ខ្ញុំសូមផ្អាកត្រឹមហ្នឹងសិន លោកនឹកឃើញឡើងវិញទេ លោកចាំថាមានកងពលតូច៤៦០ហ្នឹងទេ?

**ផ៖** ខ្ញុំៗពួគេប្រកាសមាន ប៉ុន្តែដូចខ្ញុំបញ្ជាក់បដិសេធអំមិញថាទាំងអស់នេះវាជា គេនៅភាគនិរតី ខ្ញុំនេះមកចូលក៏អត់ដែលបានទេ គ្រាន់បានតែជួប មេគេប្រាប់ថា មានពួកនិរតីមកហ្នឹងប៉ុន្មានកងពលអ៊ីចឹងមកចូលរួម។ គ្រាន់គេបានប្រកាសតែប៉ុណ្ណឹង ប្រាប់អ៊ីចឹង។ ថាឲ្យស្គាល់គ្នា អត់ស្គាល់ទេ អត់ដែលឃើញផង ពួតែឈ្មោះអីខ្លះហើយ។

**ស៖** នៅចម្លើយទី១៥ដដែល លោកបាននិយាយអំពីកងពល២២១ ជាកងពលអន្តរាគមន៍ដែល

មាន អៀង ផាន មកពីនិរតីជាមេបញ្ជាការ និង សុខ ឈាន ជាមេបញ្ជាការរង។ លោកនឹកឃើញត្រង់ចំណុចហ្នឹងឡើងវិញទេ? អ្នកទាំងអស់ហ្នឹងសុទ្ធតែមនុស្សដែលលោកមិនស្គាល់ទេ មែនទេ ហើយលោកគ្រាន់តែស្ដាប់ឮគេប្រកាសឈ្មោះ ហើយនិងមុខតំណែងរបស់ពួកគាត់ មែនទេ?

[១៤:២៨:០២]

**ផ៖** ឈ្មោះទាំងអស់នេះ ខ្ញុំអត់បានស្គាល់ បានឃើញទេ គ្រាន់តែឮគេប្រកាសតែឈ្មោះទេ ហើយអង្គភាពទេ ព្រោះដូចខ្ញុំបដិសេធអ៊ីចឹង ថាគេ ពួកនេះមកពីនិរតី ហើយនៅខាងភាគបស្ចិម ដូច្នេះអត់ស្គាល់គ្នាទេ។

**ស៖** កងកម្លាំងទាំងអស់ហ្នឹងនៅស្វាយរៀង អ៊ីចឹងខ្ញុំចង់ដឹងថាតើលោកមានបានសហការគ្នាជាមួយកងពលទាំងអស់ហ្នឹងទេ ដើម្បីប្រយុទ្ធជាមួយកងទ័ពវៀតណាមនោះ?

**ផ៖** រឿងសហការ ដូច្នេះគឺគ្រាន់តែគេចែកមុខសញ្ញាគ្នា ថាខ្ញុំពីត្រង់ណាទៅត្រង់ណាអ៊ីចឹងទៅប្រហែល២គីឡូគេណោះ ត្រឹមណោះទៅមានព្រំប្រទល់ តែដូច្នេះគ្រាន់តែ ដូចជាមិនឃើញមានសហការផង។ ដូច្នេះវ៉ៃតាមមុខសញ្ញារៀងខ្លួន ធ្វើតាមមុខសញ្ញារៀងខ្លួនតែម្ដង អត់មាន។

**ស៖** នៅក្នុងឯកសាររបស់លោកដដែល គឺក្នុងចម្លើយទី១៤ លោកថា ពេលដែលលោកទៅដល់ស្វាយរៀង "រ៉ែន បានប្រាប់ខ្ញុំឲ្យរៀបចំផែនការទ័ពដើម្បីប្រយុទ្ធ" សូមបញ្ចប់ការដកស្រង់។ លោកអាចបញ្ជាក់បានទេ ថាផែនការប្រយុទ្ធហ្នឹងមានអ្វីខ្លះ? ហើយលោកត្រូវរៀបចំជាមួយអ្នកណាខ្លះ?

**ផ៖** ផែនការប្រយុទ្ធហ្នឹង ខ្ញុំរៀបចំជាមួយកម្លាំងទ័ពខ្ញុំហ្នឹង នៅនេះហ្នឹង គឺរៀបចំជាមួយទ័ពខ្ញុំមានអ្នកណាមកជួយរៀប អត់ទេ។

**ស៖** ដូច្នេះទោះបីជា រ៉ែន ជាថ្នាក់លើរបស់ក៏ដោយហ្នឹង គឺថាលោកទេ ជាអ្នករៀបចំផែនការហ្នឹងយកទៅឲ្យគាត់មើល អ៊ីចឹងមែនទេ?

[១៤:៣០:២៩]

**ផ៖** ផែនការគឺរៀបចំនេះគឺអត់ទេ គឺដូច្នេះ ផែនការគឺក្នុងនាមខ្ញុំជាមេបញ្ជាការ គឺខ្ញុំត្រូវចេះរៀបចំចាត់ចែង ហើយរៀបចំវិធីទប់ទល់យ៉ាងម៉េច គឺរៀបចំខ្លួនឯងហើយ គ្រាន់តែនេះហើយ ទៅជួយប្រាប់ទៅខាងលើដឹងថា ខ្ញុំរៀបចំពីត្រង់នេះ ទៅត្រង់នោះ។ អ៊ីចឹងទៅដឹងច្បាស់លាស់ហើយ គ្រាន់តែនេះមានអ៊ីចឹង។

**ស៖** លោកនៅស្វាយរៀងហ្នឹងរហូតដល់តែវៀតណាមវាយចូលតែម្ដង<មែនទេ>?

**ឆ៖** ខ្ញុំនៅស្វាយរៀងរហូតដល់យួនវៃបុកចូលមកហ្នឹង។

**ស៖** <ចន្លោះ>ពេលដែលលោកទៅដល់នៅខែមិថុនា ឆ្នាំ៧៨ និងពេលដែលវៀតណាមលុកលុយចូលនុ៎ង លោកធ្លាប់មានប្រជុំជាមួយ សុន សេន ដែរឬទេ?

**ឆ៖** នៅពេលនោះគឺខ្ញុំបានជួប គឺ តាវ៉ែន ហ្នឹងហៅខ្ញុំទៅធ្វើការកន្លែងគាត់ ដូច្នេះឃើញជួប សុន សេន ម្ដង។ ជួបបានម្ដង គ្រាន់សួរពីសភាពការណ៍ សុខភាពកងទ័ពនៅខាងមុខអីយ៉ាងម៉េច សភាព-ការណ៍អីយ៉ាងម៉េច គ្រាន់តែសួរប៉ុណ្ណឹង។ ខ្ញុំបានជួបម្ដង។

**ស៖** ក្នុងពេលដែលលោករៀបចំផែនការប្រយុទ្ធ លោកធ្វើតែម្នាក់ឯងទេ ឬក៏នៅពេលណាមួយនោះលោកទទួលបានបញ្ជា ឬក៏សេចក្ដីណែនាំពី សុន សេន ក្នុងការរៀបចំផែនការប្រយុទ្ធនេះ?

[១៤:៣២:៤៣]

**ឆ៖** ផែនការ រៀបចំផែនការប្រយុទ្ធនេះ គឺបានបញ្ជាក់ច្បាស់លាស់រួច ធ្វើការនោះរួចហើយ ដូច្នេះគ្មានពេលវេលាឯណានឹងបានជួបជុំគ្នាញឹកទេ ព្រោះសមរភូមិ។ ដូច្នេះបានដាក់ទិសមុខសញ្ញាខ្ញុំ ថាចំត្រង់ណា ធ្វើត្រង់ណា ការពារត្រង់ហ្នឹងឲ្យបាន។ ដូច្នេះបើមានសត្រូវចូលមក គឺវៃការពារទប់ទល់ ដូច្នេះតាមមុខសញ្ញារៀងខ្លួន។ អាហ្នឹងគឺបញ្ជាក់ច្បាស់លាស់អ៊ីចឹង។ ហើយគ្មានពេលណាមកបានទៅជួបខាងលើទៀតទេ ព្រោះខាងលើបានជួបតែម្ដងម្កាលអ៊ីចឹងទេ អត់ដែលបានជួបញឹកញាប់ទេ ព្រោះធ្វើទៅតាមថ្នាក់ តាមតួនាទីរបស់ផងខ្លួន។

**ស៖** នៅខែណាដែរ ដែលលោកបានប្រយុទ្ធគ្នាជាលើកដំបូងនោះ នៅស្វាយរៀង? លោកទៅដល់ខែមិថុនា ឆ្នាំ៧៨ អ៊ីចឹងខ្ញុំចង់ដឹងថា នៅខែណាដែលលោកបានចាប់ផ្ដើមប្រយុទ្ធគ្នាជាមួយនឹងកងទ័ពវៀតណាមនោះ?

**ឆ៖** គឺទៅដល់ពីរបីថ្ងៃក្នុងខែមិថុនា គឺចាប់ប្រយុទ្ធគ្នា។ គេចេះតែចូលមកទឹកដីយើង ចេះតែប្រយុទ្ធ ចេះតែទប់ទល់ទៅ កុំឲ្យវាមក។

**ស៖** លោកថា លោកវៃកុំឲ្យកងទ័ពវៀតណាមបុកចូល។ អ៊ីចឹងខ្ញុំចង់ដឹងថា <តើការវាយប្រយុទ្ធគ្នាដំបូងនោះវាចាប់ផ្ដើមឡើងដោយរបៀបណា ដែលលោកថាពីរបីថ្ងៃក្រោយទៅដល់ស្វាយរៀង>នុ៎ង? លោកឃើញកងទ័ពវៀតណាមចូលមកដំបូងហ្នឹងនៅពេលណា ហើយនៅកន្លែងណាដែរ? ហើយលោកធ្វើយ៉ាងម៉េចចំពោះកងទ័ពទាំងអស់ហ្នឹង?

**ឆ៖** ពេលវេលាខ្ញុំចាំ ខ្ញុំអត់ចាំបានទេ ក៏ប៉ុន្តែការរៀបចំ គឺទ័ពយួននោះ គឺមកពីមុខ ៗខ្សែត្រៀម

ព្រោះត្រង់ហ្នឹងស្វាយរៀង វាព្រំប្រទល់ជាប់នឹងយួនគឺជិតបង្កើយ។ ដូច្នេះគឺវាចូលមក លើកមកចូលមកតាមហ្នឹង ខ្ញុំទប់ទល់មុខសញ្ញាខ្ញុំហ្នឹងទៅ គេៗទប់ទល់មុខសញ្ញាអង្គភាពគេ អ៊ីចឹងតាមរៀងខ្លួនទៅ។

[១៤:៣៥:១០]

**ស៖** លោកដឹងថា ទាហានវៀតណាមវាយចូលហ្នឹង ប៉ុន្មាននាក់ទេ? ហើយមានកាំភ្លើងប្រភេទណាខ្លះ? ហើយមានពួកកងពលថ្មើរជើងវៀតណាមនោះ មានរថក្រោះ មានអីទេ ពេលវាយបុកចូលមកហ្នឹង?

**ឆ៖** ខ្ញុំដឹងថា កងទ័ពយួនដែលចូលមកវាយបុកទម្លុះកម្ពុជាហ្នឹង គឺអត់ដឹងមានចំនួនប៉ុន្មានទេ ប៉ុន្តែគ្រាន់តែកាំភ្លើងមានគ្រប់ធុន ហើយរថក្រោះក៏មានដែរ កាំភ្លើងធំក៏មានដែរ ដូច្នេះចូល បុកចូល។ ខ្ញុំដឹងប៉ុណ្ណឹង ឯចំនួនមនុស្ស ខ្ញុំអត់ក្តាប់បាន។

**ស៖** ពេលដែលលោកនិយាយថា មានកាំភ្លើងគ្រប់ប្រភេទហ្នឹង លោកអាចបញ្ជាក់<ឲ្យច្បាស់> បានទេ ព្រោះថា លោកជាទាហាន អ៊ីចឹងលោកស្គាល់ទេ ប្រភេទកាំភ្លើងហ្នឹង ប្រភេទអីខ្លះដែរ?

**ឆ៖** កាំភ្លើង មានកាំភ្លើង១០៥, ១២០, ៣០លី, ៣៧ និងកាំភ្លើងយន្តគ្រប់មុខទាំងអស់ គឺមានប៉ុណ្ណឹង មាន។

**ស៖** ចុះខាងកម្លាំងលោកវិញនោះ លោកមានកាំភ្លើងប្រហាក់ប្រហែលគ្នាហ្នឹងទេ? ឬក៏កាំភ្លើងលោកហ្នឹងមិនសូវល្អ បើធៀបជាមួយនឹងកាំភ្លើងរបស់ខាងវៀតណាមនោះ?

**ឆ៖** ចំពោះបញ្ហាកាំភ្លើង បើប្រៀបធៀបទៅ មិនជាងគ្នាទេ ប៉ុន្តែខ្ញុំៗគ្រប់គ្រងតែកម្លាំងថ្មើរជើងទេ ឯបញ្ហាកាំភ្លើងធំ កាំភ្លើងអីរបស់ខាងកម្ពុជាធិបតេយ្យនេះ ហ្នឹងគេមានអង្គភាពគេ មានមេបញ្ជាការគេដឹកនាំប្រយុទ្ធហើយ ហើយខ្ញុំ ៗប្រយុទ្ធតែកងទ័ពថ្មើរជើងទេ។ ដូច្នេះខ្ញុំបញ្ជាក់ជូនបានអ៊ីចឹង។

[១៤:៣៧:៣០]

**ស៖** <តើ>កងពលផ្សេងទៀតហ្នឹង គឺនៅឆ្ងាយពីកន្លែងលោក<ទេ?> អ៊ីចឹងមានកន្លែងណាដែលថា មានវាយប្រយុទ្ធគ្នាខ្លាំង កន្លែងដែលវៀតណាមវាយចូលខ្លាំង ហើយទាមទារឲ្យមានកាំភ្លើងហ្នឹងទំនើបខ្លាំង មានអានុភាពខ្លាំងទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថែមថា ពេលដែលកងទ័ពយួនវាយខ្លាំង ចូលកន្លែងមួយៗនេះ ខាងអង្គភាពកាំភ្លើងធំ កាំភ្លើងអីផ្សេងៗ អាហ្នឹងស៊ីសងទៅមុខសញ្ញាគេទេ។ បើគេត្រូវការ ហ្នឹងគេហៅខាងកាំភ្លើងធំឲ្យជួយអន្តរាគមន៍តែម្តង។ ហ្នឹងតាមគេ មេបញ្ជាការអង្គភាពគេមួយៗដែលមាន ដែលគេត្រូវការ។

**ស៖** លោកទាក់ទងគ្នាយ៉ាងម៉េច នៅពេលដែលលោកត្រូវការកម្លាំងជំនួយនោះ?

**ឆ៖** សូមបញ្ជាក់ ត្រូវការកម្លាំងជំនួយ អត់មានត្រូវការកម្លាំងជំនួយទេ គឺអង្គភាពខ្ញុំគឺដោះស្រាយហ្នឹងតែម្តង គឺហ្នឹងតែម្តង អត់មានត្រូវកម្លាំងជំនួយអីទេ។ គឺថាវាយជាខ្សែត្រៀម វាយទប់អ៊ីចឹងទៅ ដូចយើងនេះអ៊ីចឹង។ ដូច្នេះមានកម្លាំងអីជំនួយអីពីណាទេ អត់ទេ។

**ស៖** លោកថា លោកត្រូវវាយបក អ៊ីចឹងខ្ញុំចង់ដឹងថា ពេលដែលត្រូវវាយបកការរុលចូលរបស់កងទ័ពវៀតណាមហ្នឹង អ្នកណាអ្នកសម្រេច? គឺលោកផ្ទាល់ លោកសម្រេចខ្លួនឯងថា ត្រូវវាយបកទៅវិញ ឬក៏យ៉ាងម៉េច?

**ឆ៖** អាហ្នឹងគឺ តាមនោះគឺ ដែលទិសណែនាំពីមេៗពីខាងដើមមកថា ទៅវាយ ទៅព្រំដែនយួនព្រោះយួនចូលទឹកដីខ្មែរ បើវាយចូលគឺយើងវាយ។ ហ្នឹងគឺ ហើយគឺភារកិច្ចហ្នឹងគឺមានតែប៉ុណ្ណឹង។ បើៗគេផ្សេងចូលមកទឹកដីខ្លួន គឺត្រូវតែវាយវិញប៉ុណ្ណឹង។

[១៤:៤០:០៨]

**ស៖** ដូច្នេះបើខ្ញុំយល់មិនច្រឡំទេ គឺថាបើវៀតណាមបានឆ្លងព្រំដែនចូលមក គឺលោក តួនាទីលោកគឺដឹងតែវ៉ៃតែម្តង អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំឃើញថាឥឡូវនេះម៉ោងពីរ សែសិបនាទីហើយ ប្រហែលជាដល់ពេលសម្រាកហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការឆ្លើយតបទៅនឹងឋានៈរបស់សាក្សីរូបនេះ។ តាមដែលខ្ញុំយល់គឺថា នៅពេលដែល<>ចេញសេចក្តីសម្រេចនៅក្នុងសំណុំរឿង<០០៣> <ឬ>សំណុំរឿង<០០៤> គឺថាអង្គជំនុំជម្រះបានផ្ញើឯកសារ ដែលថាបានទទួលសេចក្តីសម្រេចនេះ។ ខ្ញុំមិន<ដឹងថាតើករណីនោះមាននៅក្នុងការអនុវត្តឬទេ ប៉ុន្តែគេ>បានបង្ហាញ<លោកចៅក្រមរួចហើយ ដូច្នេះ>យើង<មិនបានបង្ហាញនៅក្នុងការដាក់ឯកសាររបស់យើងទេ។ អ្វីដែលយើងធ្វើ គឺយើងបង្ហាញនៅក្នុងសារ-

ណា និង>តារាងបញ្ជីឈ្មោះសាក្សី ហើយបញ្ជាក់អំពីឋានៈរបស់សាក្សីរូបនេះ ថាសាក្សីរូបនេះមិនមានរហស្សនាមទេ មិនចាំបាច់ប្រើរហស្សនាមទេ <ហើយអាចធ្វើសវនាការសាធារណៈបាន>។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០៥ នាទី)*

[១៥:០៥:០៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដី ខៀវ សំផន អង្គជំនុំជម្រះសូមឆ្លើយបញ្ជាក់លើសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងទៅនឹងសាក្សី 2-TCW-859 នេះ។

ថាកាលពីថ្ងៃទី១៦ សីហា ២០១៦ សហចៅក្រមស៊ើបអង្កេតបានសេចក្ដីសម្រេចលើវិធានការការពារលើសាក្សីមួយចំនួន ដែលក្នុងនោះរួមមានសាក្សី 2-TCW-859 នេះផងដែរ ហើយបានបញ្ជាក់នៅក្នុងកថាខណ្ឌ៥៤ សាក្សីនេះ មិនត្រូវឲ្យមានវិធានការការពារទាក់ទងនឹងអត្តសញ្ញាណរបស់សាក្សីនោះទេ។ ដូច្នេះសាក្សីនេះ គឺភាគីអាចប្រើប្រាស់អត្តសញ្ញាណ និងនាមត្រកូល នាមខ្លួនរបស់គាត់ដូចធម្មតាបាន។ ហើយសាក្សីនេះមានឈ្មោះថា ជួន ធី។

បាទ សូមផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដី ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**កញ្ញា អង់តា ហ្គីសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក ជួន ធី លោកបាននិយាយអំពីជំនួបលើកទី១ ជាមួយ ប៉ុល ពត នៅខែមិថុនា ឆ្នាំ ១៩៧៨ ហើយខ្ញុំត្រឡប់មកនិយាយពេលក្រោយទៀត។ ខ្ញុំចង់សួរលោកថា តើលោកមានបានធ្លាប់ជួប ឬក៏ស្ដាប់គាត់និយាយតាមវិទ្យុដែរឬទេ ពីមុនមក?

[១៥:០៧:០១]

**លោក ជួន ធី៖**

**ឆ៖** ខ្ញុំសូមគោរព។ ចំពោះភាសា ប៉ុល ពត ពីមុនមក ក៏ខ្ញុំមិនដែលស្គាល់ គ្រាន់តែឈ្មោះមិន ដែលឮ ទើបបានមកទៅធ្វើការហ្នឹង នៅជួបហ្នឹងទេ គឺអត់ដែលបានជួបដែរ ហើយក៏មិនដែលស្គាល់។ ទើបតែស្គាល់ ថ្ងៃដែលធ្វើការនៅកំពង់ឆ្នាំងហ្នឹង ទើបស្គាល់ថ្ងៃហ្នឹង ឃើញ។

**ស៖** ដោយមិនធ្លាប់ឮសុន្ទរកថាគាត់ពីមុនមកនោះ តើមុនពេលទៅដល់ស្វាយរៀងនោះ ក្នុង ក្របខ័ណ្ឌនៃការបំពេញភារកិច្ចរបស់លោកជាទាហានខាងស៊ីវិល ហើយនិងខាងកសិកម្ម ហើយនិង កសាងផ្លូវអីជាដើមនោះ តើនៅចុងឆ្នាំ១៩៧៧នោះ តើលោកមានធ្លាប់ចូលរួមក្នុងការសិក្សារៀនសូត្រអី មានឮក្នុងការកិច្ចការសិក្សារៀនសូត្រហ្នឹង គេមានឮនិយាយអំពីការរំលោភបំពាន ឈ្លានពានរបស់ វៀតណាមដែរឬទេ វ៉ៃលុកលុយរបស់វៀតណាមមកលើខ្មែរដែរឬទេ?

**ឆ៖** កាល ដែលកាលមុន៧៧ ចិតសិបអី ដែលពេលដែលវៀតណាមចូលមក ដូច្នេះការប្រជុំ អស់ហ្នឹងគឺខ្ញុំមិនមែនប្រជុំស្ដាប់ពី ប៉ុល ពត ទេ គឺមេខាងលើហ្នឹង គេប្រជុំថា "ប្រទេសជិតខាងយើងនេះ គេចេះតែចង់ចូលមករករឿងយើងហើយ"។ ដូច្នេះ កាលនោះខ្ញុំធ្វើកងទ័ពនៅ ធ្វើតែស្រែដែរ មិនសូវនេះ ទេ ដល់ពេល ដែលមួយចំនួន ដល់ពេល ដែលដល់ពេលយួនបុកមក៧៨ហ្នឹង ដែលបុកខ្លាំងដែលខ្ញុំទៅ ហ្នឹង បាននាំគ្នាប្រមូលទ័ពទៅបណ្ដោយ។ ដូច្នេះគ្រាន់តែដឹងថាគេ គ្រាន់តែដឹងដំណឹងថាយួន អ្នកជិត ខាងហ្នឹង គេចូលមកប្រទេសយើង ចូលយកយើងហើយ វ៉ៃយើងហើយ គ្រាន់ដឹង។

[១៥:០៩:១៥]

**ស៖** លោកនិយាយអំពីការវាយលុកនៅឆ្នាំ១៩៧៨ តើលោកមានចាំ តើលោកមានចាំការវាយ លុកនៅចុងឆ្នាំ១៩៧៧ដែរឬទេ ពីសំណាក់ប្រទេសវៀតណាម?

**ឆ៖** ការវាយលុកពីប្រទេសវៀតណាម ឆ្នាំ៧២*(ស៊ីក)* ខ្ញុំអត់ដែលដឹងដែរ ព្រោះខ្ញុំនៅឆ្ងាយឯ ណោះ នៅខាងព្រំដែន ខ្ញុំនៅឯលិចណោះ ដូច្នេះចាប់អត់បានដែរ។ ខ្ញុំអត់ដឹង។

**សះ** តើលោកមានដឹងអំពីការផ្តាច់ទំនាក់ទំនងការទូតជាមួយវៀតណាមដែរឬទេ ហើយនិងការប្រកាសសង្គ្រាមដោយកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆះ** ខ្ញុំសូមឆ្លើយនេះ គឺខ្ញុំ អារឿងការងារខាងផ្តាច់ទូត ការទាក់ទងអីរឿងផ្នែកទូតនេះ ខ្ញុំក្តាប់អត់បានដែរ មិនដែលឮគេនិយាយទេ។ តែគ្រាន់ថារឿងប្រកាសថាវៃយួនវៃអី អាហ្នឹងគឺអត់មានប្រកាសទេ ក៏ប៉ុន្តែគ្រាន់តែទិសដៅថា ដូចខ្ញុំកងទ័ពអ៊ីចឹងការពារក្តីទឹកដី បើសិនមានសត្រូវដូចខ្ញុំបញ្ជាក់ខាងដើមថាបើមានសត្រូវចូលមកទឹកដីយើង ឈ្លានពានយើង គឺយើងវៃការពារ អាហ្នឹងគឺមានតែប៉ុណ្ណឹង។

[១៥:១០:៥៧]

**សះ** លោកបាននិយាយថា លោកទទួលបន្ទុកឈរជើងនៅប្រហែលជា២គីឡូម៉ែត្រពីព្រំដែន។ ខ្ញុំសូមអានសម្រង់មួយនៃសុន្ទរកថារបស់ ប៉ុល ពត ដែលគាត់បានថ្លែងនៅមុនពេលលោកទៅដល់ស្វាយរៀងបន្តិច ក៏ប៉ុន្តែគាត់និយាយអំពីរបៀបនៃកងទ័ពកម្ពុជាប្រជាធិបតេយ្យបានតស៊ូប្រឆាំង ហើយនិងអំពីសព្វាវុធដែលមាន។ អ៊ីចឹងខ្ញុំចង់ដឹងថា នៅពេលដែលលោកទៅដល់ស្វាយរៀងខ្លួនឯងនោះ តើស្ថានការណ៍ ឬក៏សភាការណ៍ហ្នឹងដូចគ្នាទៅនឹងស្ថានការណ៍ ដែលគាត់បាននិយាយនៅក្នុងសុន្ទរកថាគាត់ដែរឬទេ? គឺទង់បដិវត្តចុះខែមេសា ឆ្នាំ១៩៧៨ ឯកសារ E3/4604។ សម្រង់នេះនៅ ERN ជាភាសាបារាំងគឺ 00520345, ERN ជាភាសាខ្មែរគឺ <0064714>*(ស៊ុក)*, ERN ជាភាសាអង់គ្លេសគឺ 00519835។ ពេលភាគីកំពុងតែរកផ្នែកដែលខ្ញុំដកស្រង់នេះ លោកបាននិយាយនៅក្នុងសំណុំរឿង០០២/១ លោកនិយាយថាលោកមានទង់បដិវត្តនេះនៅក្នុងដៃហើយ។ តើលោកមានចាំថា លោកបានអានសុន្ទរកថារបស់ ប៉ុល ពត នេះនៅក្នុងទង់បដិវត្តហ្នឹងទេ?

**ឆះ** ខ្ញុំបានបញ្ជាក់ថាខ្ញុំមានមើលទង់នុំងមែន ប៉ុន្តែទង់ហ្នឹងមើល អត់មាននិយាយពីដែលការឈ្លានពានពីប្រទេសជិតខាងអីទេ គឺនិយាយអំពីការតម្រង់ទស្សនៈ គោលជំហរមនុស្សឲ្យខំប្រឹងប្រែងការពារទឹកដីធ្វើមនុស្សល្អហ្នឹងគឺមានតែអ៊ីចឹង អត់មាននិយាយពីរឿងវៃប្រទេសជិតខាង អត់មាននិយាយទេ ដែលខ្ញុំបានឃើញ បានដឹង។

[១៥:១៣:៤៣]

**សះ** ឥឡូវខ្ញុំនឹងអានសម្រង់ដែលខ្ញុំបានផ្តល់អត្តសញ្ញាណឲ្យនេះ ជាភាសាបារាំងគឺកថាខណ្ឌចុងក្រោយគេនៅចុងទំព័រ។ ប៉ុល ពត គាត់ពិណ៌នាអំពីការប្រយុទ្ធគ្នា ហើយនិងរបៀបដែលកម្ពុជាប្រជាធិបតេយ្យត្រៀមខ្លួន នៅចុងឆ្នាំ១៩៧៧ ដូចតទៅនេះ៖ “យើងបានរៀបចំការប្រយុទ្ធទ្រង់ទ្រាយតូច

ដោយបែងចែកជាក្រុម ក្រុមហ្នឹងបែងចែកជាពួក។ យើង<បានជួប>ខ្មាំង <ពេលដែល>យើងវ៉ៃខ្មាំង ប៉ុន្តែយើងមានតែក្រុមទេ <ហើយពួកគេមានក្រុមអង្គភាពដឹកនាំ។> ហើយក្រុមយើងហ្នឹងក្រុមទ័ពស្រួច ។ ហើយបើនិយាយពីសព្វាវុធវិញ យើងមាន បេ-៤០, អឹម៧៩, អា.កា ហើយនិងមាន<មីនប្រឆាំង> រថក្រោះ, គ្រាប់បង្កៃ, គ្រាប់បែក។ ដូច្នេះយើងមានគ្រប់គ្រាន់ដែរ ខ្លាំងដែរ។ កងក្រុមរបស់យើងដែលចូលទៅវ៉ៃបរិវេណខ្មាំងហ្នឹង វាខ្លាំង យើងអាចទប់នឹងរថក្រោះបាន។ ហើយយើងទប់នឹងរថក្រោះ ដោយប្រើមីន ហើយនិងបេ-៤០ ហើយនិងទៅវាយថ្មើរជើងវាដោយប្រើអា.កា ហើយនិងដាក់មីនដែរ។”

អ៊ីចឹងសំណួរខ្ញុំហ្នឹង ខ្ញុំចង់ដឹងថា ផែនការវាយប្រយុទ្ធរបស់លោកនៅនឹងកន្លែងនេះ នៅលើសមរភូមិនោះ តើលោកបានបង្កើតជាក្រុមតូចៗ ដើម្បីដឹកនាំការវាយប្រហារ ការប្រយុទ្ធ ឬក៏យ៉ាងម៉េច? ឬក៏លោកបានទទួលការណែនាំបែបនេះពីថ្នាក់លើមក? ខ្ញុំចោទសំណួរទាំងអស់នេះ ដោយសារគេតែងតែនិយាយអំពីចំនួនទាហានរបស់កម្ពុជាប្រជាធិបតេយ្យ ដែលមិនស្មើគ្នានឹងកងកម្លាំងរបស់វៀតណាម។ តើលោកសម្របសម្រួលផែនការប្រយុទ្ធ ហើយនិងវិធីសាស្ត្រប្រយុទ្ធហ្នឹងដោយគិតអំពីចំនួនទាហានរបស់លោកដែលតិចជាងទាហានវៀតណាមដែរឬទេ?

[១៥:១៦:៣១]

**ឆ៖** នេះការ អានេះការប៉ាន់ប្រមាណមើល បើយើងគ្រាន់តែឃើញថាប្រជាជនយួន ហើយនិងប្រជាជនខ្មែរ គឺមានចំនួនខុសគ្នាដែរ។ ដូច្នេះបានន័យថា ក៏ដឹងដែរ ថាយួនច្បាស់ជាមានកម្លាំងប្រដាប់អាវុធច្រើនជាងខ្មែរ។ ដូច្នេះយើងធ្វើសង្គ្រាម យើងធ្វើតាមយើងម្ចាស់ទឹកម្ចាស់ដី សង្គ្រាមប្រជាជនគឺសង្គ្រាមល្បបហ្នឹង ការពារដាក់មីនដាក់អី បង្កៃហ្នឹង។ អ៊ីចឹងដែលហ្នឹង ដូច្នេះមិនទៅយកមនុស្សទៅប្រើយកមនុស្សទៅប្រើដោយទល់នឹងមនុស្សទេ។ ហើយផែនការរៀបចំអីយ៉ាងម៉េចៗដែលរបស់ខាងលើមកគឺតែចូលសមរភូមិអ៊ីចេះហើយ គឺមិនដែលបានទទួលផែនការអីពីខាងលើ គ្មានវិទ្យុអីនឹងទាក់ទង ឬវិទ្យុស្តាប់ អាម៉េចៗក៏មិនមានដែរ។ ដូច្នេះគឺនាំគ្នាធ្វើឯករាជ្យម្ចាស់ការតែម្តង នាំគ្នា តែមុខសញ្ញាណាគឺខ្លួនការពារមុខសញ្ញានោះ កុំឲ្យគេចូលបានតែប៉ុណ្ណឹង គឺធ្វើអ៊ីចឹង។

**ស៖** ពេលដែលលោកនិយាយថា យើងមិនបានចាំទទួលផែនការពីថ្នាក់លើហ្នឹង តើលោកចង់និយាយថា ពេលដែលលោកមានវត្តមាននៅស្វាយរៀងហ្នឹង យុទ្ធវិធីសំខាន់របស់លោកហ្នឹងគឺលោកកំណត់ បង្កើតឡើងដោយខ្លួនឯង ឬក៏យ៉ាងម៉េច?

**ឆ៖** វិធីប្រយុទ្ធ ឬមាគ៌ាប្រយុទ្ធនេះ ឬយុទ្ធសាស្ត្រប្រយុទ្ធ គឺបានរៀនសូត្រជាបន្តបន្ទាប់មក

ហើយ។ ដូច្នេះពេលដែលទៅ -- គឺបានចេះ បានចាំ បានដឹងអស់ហើយ ដូច្នេះធ្វើតាមរូបភាពហ្នឹង។

**ស៖** នៅពេលដែលលោកនិយាយថា លោកបានរៀនយុទ្ធសាស្ត្រហ្នឹងមុនហើយ តើពេលលោកនិយាយថាពាក្យថា "បានរៀនយុទ្ធសាស្ត្រហ្នឹងពីមុនមកហើយ" ហ្នឹង លោកសំដៅលើការសិក្សាពីមុនខែមេសា ឆ្នាំ១៩៧៥ ឬក៏យ៉ាងម៉េច?

[១៥:១៨:៤៨]

**ឆ៖** ក្បួននេះគឺបានរៀនសូត្រតាំងពីឆ្នាំ១៩៧០ មកចូលធ្វើ គឺចាប់បានរៀនទាំងបច្ចេកទេសប្រយុទ្ធ ទាំងអីទាំងអស់ គឺចាប់បានរៀនតាំងពីមុនមក ហូរហែបន្តបន្ទាប់មក។

**ស៖**ឲ្យជាក់លាក់តែម្តងទាក់ទងទៅនឹងយុទ្ធវិធីនេះ ខ្ញុំសូមដកស្រង់សម្រង់មួយទៀតនៃសុន្ទរកថាដដែល គឺឯកសារដដែល ERN ជាភាសាបារាំងគឺ 00520348, ERN ជាភាសាខ្មែរគឺ 0064716 -- 7 (សូមទោស), ERN ជាភាសាអង់គ្លេសគឺ <00519836>។ គឺ ប៉ុល ពត គាត់និយាយនិយាយដដែល គឺឯកសារ E3/4604។ "ពួកហ្នឹងវាគិតថា យើងមិនអាចឈ្នះវាបានទេ ព្រោះវៀតណាមមាន ៥០លាននាក់ ហើយយើងមានតែ៨លាននាក់ទេ។ យើងកុំជឿគេ គេនិយាយថា យើងមិនអាចឈ្នះយួនបាននោះ ដោយហេតុថា យួនគេមានទាហានគេជាង១លាននាក់នេះ ហើយទាហានយើងនឹងមានតែ<ជិត> ១០០.០០០នាក់ទេ។ <នេះជាភាពសមហេតុផលរបស់យើង> ព្រោះយើងមិនដឹងថា យើងធ្វើយ៉ាងម៉េចដើម្បីឲ្យឈ្នះសង្គ្រាមជាប្រវត្តិសាស្ត្រនេះ។ យើងមិនយល់ថា មាគ៌ាណាដែលធ្វើឲ្យយើងឈ្នះ។ បើទាក់ទងនឹងមាគ៌ារបស់យើងនេះ យើងវាយយ៉ាងម៉េចឲ្យឈ្នះ? ត្រូវដោះស្រាយយ៉ាងម៉េច? វាមានកងទ័ពវាជិត១លាន ហើយយើងមានតែ ១០០.០០០នាក់ទេ។ បើអ៊ីចឹងយើងតិចជាងវា១០ដងឯនោះ។ បើគិតឲ្យមែនទែនកងកម្លាំងរបស់យើង តិចជាងវាឆ្ងាយណាស់ តើយើងត្រូវដោះស្រាយបញ្ហាហ្នឹងយ៉ាងម៉េច ដើម្បីឲ្យឈ្នះសង្គ្រាម? អ៊ីចឹងរបៀបដោះស្រាយរបស់យើងហ្នឹង គឺត្រូវប្រើកម្លាំងតូចៗ ដើម្បីកម្ទេចកម្លាំងធំ។ ដើម្បីឲ្យអាតូចឈ្នះអាធំ យើងត្រូវតែធ្វើយ៉ាងណាឲ្យអាតូច ហើយចំនួនតិចតួចហ្នឹងចេះប្រើកម្លាំងតិចតួចរបស់ខ្លួន ដើម្បីវ៉ៃឲ្យចំកន្លែង ហើយផ្តួលអាកម្លាំងធំឲ្យបាន។ ដូចដែលខ្ញុំបានជម្រាប<រួចមកហើយ នេះ>គឺជាគោលការណ៍ ១ទល់នឹង៣០។ បើ១ទល់នឹង៣០ យើងធ្វើបានហើយ យើងអាចធ្វើសង្គ្រាម<រយៈពេល>៧០០ឆ្នាំ ក៏នៅតែឈ្នះដែរ។ ហើយបើយើងវាយ មិនធ្វើរបៀបនេះទេ យើងមិនអាចឈ្នះគេទេ។ ហើយបើយើងខ្លាច ឃើញថា គេមានដល់៥០លាននាក់ ហើយយើងមានតែ៨លាននាក់ហ្នឹង យើងចាញ់គេបាត់ហើយ បើខ្លាចពីមុនទៅហើយនោះ យើងដែលដកថយមុននឹងសង្គ្រាម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

E1/489.1

ទៀតនោះ។" សូមបញ្ចប់ការដកស្រង់។

ឥឡូវខ្ញុំប្រៀបធៀបអ្វីដែលលោកទើបបាននិយាយអំមិញ ហើយនិងផ្នែកនេះនៃសុន្ទរកថារបស់ ប៉ុល ពត។ សំណួរខ្ញុំ ខ្ញុំចង់ដឹងថា តើនៅពេលដែលលោកបានឃើញ ប៉ុល ពត មុននឹងមកស្វាយរៀង នេះ តើ ប៉ុល ពត នេះមានបាននិយាយពីកម្លាំងទាំងពីរភាគីហ្នឹង ខុសគ្នាឆ្ងាយដែរឬទេ? ហើយតើគាត់មានបានផ្តល់សេចក្តីណែនាំដល់លោកឲ្យគ្រប់គ្រងកងកម្លាំងរបស់លោកហ្នឹងយ៉ាងម៉េចដែរឬទេ នៅស្វាយរៀងនោះ? <តើគេមានបានប្រាប់ឲ្យលោកទាញយកបទពិសោធន៍ពីការប្រយុទ្ធដែលបានធ្វើមុនឆ្នាំ ៧៥ទេ?>

[១៥:២៣:០៦]

**ឆ៖** ខ្ញុំសូមឆ្លើយ ពេលដែលមកជួបនឹង ប៉ុល ពត នៅកំពង់ឆ្នាំង ដែលមុននឹងទៅស្វាយរៀង ហ្នឹង ក៏គាត់គ្មានបញ្ជាក់ហេតុផលអី ណែនាំអីច្រើនដែរ ព្រោះមានសេនាធិការគាត់គឺពេទ្យ សឿង ដែលកងពលហ្នឹង គាត់ជាអ្នកដឹកនាំ ហើយគាត់ណែនាំ ហើយគាត់មិនបញ្ជាក់រឿងអីទេ។ ដូច្នេះគ្រាន់តែដឹងថា សំខាន់គឺអ្នកដែលទៅធ្វើជាក់ស្តែង គ្រាន់តែប្រៀបធៀបកម្លាំងដូចខ្ញុំនិយាយខាងដើមអ៊ីចឹង។ និយាយវែងបន្តិចចុះថា កម្លាំងដែលទាហានយួន ហើយនិងទាហានខ្មែរ វាមានកម្លាំងខុសគ្នា។ ដូច្នេះគេមើលឃើញ ១ទល់នឹង៣០។ អាហ្នឹងក៏ ខាងខ្ញុំក៏មិនទាន់ដែលបានឮគាត់និយាយប្រាប់ដែរ តែគ្រាន់ បើពិនិត្យទៅជាក់ស្តែងអ្នកធ្វើ បើគេមកច្រើនពេកហ្នឹង មុខតែចាញ់គេ មុខតែរត់ហើយ មិនមែន ប៉ុល ពត អ្នកធ្វើសង្គ្រាមឯណា។ អាហ្នឹងសំខាន់ គឺដែលកងទ័ព ក៏មានទស្សនៈយល់ខ្លាចដាប់ដែរ ខ្លាចអីដែរ។ ដូច្នេះបើគេមកច្រើនក៏ចាញ់ នាំគ្នារត់ទៅ ដូចនេះអ៊ីចឹង។ អាហ្នឹងខ្ញុំគ្រាន់តែបញ្ជាក់ថែមប៉ុណ្ណឹង។

**ស៖** ឥឡូវខ្ញុំសូមពិភាក្សាជាមួយលោកអំពីទីតាំងមួយចំនួន ហើយនិងរំឭកការចងចាំរបស់លោកទាក់ទងទៅនឹងការច្បាំងគ្នាជាច្រើនអន្លើនៅស្វាយរៀង។ ក៏ប៉ុន្តែមុននឹងនិយាយពីចំណុចនេះ ខ្ញុំចង់សួរលោកថា តើមានការផ្តល់ព័ត៌មានរវាងកងពលផ្សេងៗ ឬក៏វរសេនាធំផ្សេងៗដែរឬទេ? ហើយបើសិនជាមានមែនទ៉ុង តើគេផ្តល់ព័ត៌មានទៅវិញទៅមកហ្នឹង ដោយតាមមធ្យោបាយណាដែរ?

[១៥:២៤:៥១]

**ឆ៖** អង្គភាពផ្សេងៗដែលនៅជុំវិញជិតគ្នា គឺអត់មានផ្តល់ព័ត៌មានអីនឹងគ្នាទេ ដូច្នេះគឺ ដូច្នេះពេលនោះគឺធ្វើ មិនមានអីទាក់ទងផង។ ដូច្នេះមានតែឮសូរកាំភ្លើងគ្នា នៅចាប់ដៃគ្នាជាប់ ឮសូរកាំភ្លើងមើលឃើញគ្នាទាំងសងខាងហ្នឹង ព្រំប្រទល់ ដូច្នេះគ្មានអីទេ។ យូរៗខាង តារ៉ែន ណោះគេមកប្រាប់

សភាពការណ៍អ៊ីចេះអ៊ីចុះម្ដង ខាងនុ៎ងទៅ ហើយឲ្យមកពង្រឹងកម្លាំងធ្វើម៉េចទប់ទល់។ ហ្នឹងគ្រាន់គេមានគេប្រាប់អ៊ីចឹង អត់មានអីនឹងវែងឆ្ងាយទៀតទេ។

**ស៖** តើលោកមានទទួលព័ត៌មាន ពាក់ព័ន្ធទៅនឹងកងកម្លាំងរបស់ខ្មាំងដែរឬទេ?

**ឆ៖** អត់ដែលទទួល។

**ស៖** ខ្ញុំលើកចំណុចនេះឡើងនេះ ពីព្រោះថានៅក្នុងចម្លើយរបស់លោក គឺឯកសារ E3/4593 នៅចម្លើយទី១៩ លោកបាននិយាយអំពីទូរលេខមួយដែលលោកបានមើល ហើយលោកបាននិយាយដូចតទៅនេះ៖ "ខ្ញុំធ្លាប់ទទួលទូរលេខ ពាក់ព័ន្ធទៅនឹងផែនការ និងសកម្មភាពទ័ពត្រឹមតែថ្នាក់កងពលទេ។ ហើយទូរលេខនោះ គឺជាទូរលេខដែលបកប្រែមកពីទូរលេខដើម ដែលជាលេខសម្ងាត់ ហើយមិនមានចម្លងជូនថ្នាក់ដឹកនាំណាមួយទេ ក្រៅតែពីយកមកឲ្យខ្ញុំផ្ទាល់។ ហើយទូរលេខនេះនិយាយតែពីសកម្ម-ភាព<ខ្មាំង>តែប៉ុណ្ណឹងទេ។" តើខ្ញុំអាននេះ ធ្វើឲ្យលោកនឹកឃើញទេ? គឺថាអង្គាល់នោះនុ៎ង លោកទទួលទូរលេខដែលក្នុងទូរលេខហ្នឹង គេរៀបរាប់ប្រាប់ពីផែនការខ្មាំងដែរ<ឬទេ>?

[១៥:២៦:៥៧]

**ឆ៖** ខ្ញុំៗចាំ ពាក្យហ្នឹង។ ដូច្នេះដែលទទួលផែនការហ្នឹង គឺមេរបស់ខ្ញុំ គឺដូចខ្ញុំថាអ៊ីចឹង តែ តា សឿង ហ្នឹងកងពល គឺទទួលមក គឺបកពីលើមក គាត់មកទទួលមុខផ្ទាល់ ឲ្យខ្ញុំមកផ្សព្វផ្សាយក្នុងអង្គ-ភាពហ្នឹង ពេទ្យសឿង ដែលជាកងពល។

**ស៖** អ៊ីចឹងយើងយល់ស្របនឹងខ្ញុំទេ គឺថាព័ត៌មានដែលលោកទទួលបាន ទូរលេខទាំងអស់ហ្នឹង គឺលោកទទួលបាននៅស្វាយរៀងហ្នឹង មែនទេ?

**ឆ៖** អត់ទេៗ ទទួលបានតាំងពីខ្ញុំនៅមិនទាន់មកដល់ស្វាយរៀងនោះ ដែលខ្ញុំទទួលបានដែលគាត់រៀបចំឲ្យមកនោះ រៀបផែនការហ្នឹងគឺខ្ញុំរៀប គេរៀបចំឲ្យតាំងពីកាលមុនមកស្វាយរៀងនុ៎ង។ រៀបចំមកហ្នឹង គឺផែនការនោះប្រាប់អ៊ីចឹងតែម្ដង ហើយគាត់ក៏ជួបផ្ទាល់ទៀត ហើយខ្ញុំ នាំខ្ញុំហ្នឹងមកជួប តា ប៉ុល ពត ហ្នឹងទៀត គឺរៀបចំកម្លាំងចុះមកប៉ុណ្ណឹងបណ្ដោយ។ តែមកដល់ស្វាយរៀងហើយ អត់មានទាក់ទងអីបានជាមួយ ប៉ុល ពត ទៀតទេ អត់មានទេ គឺអត់ទេ អត់មាន គឺចប់។

**ស៖** អ៊ីចឹងគឺថា លោកបានទទួលព័ត៌មានលម្អិតតែអំពីសភាពការណ៍នៅសមរភូមិនោះ <នៅ> ពេលដែលលោកបានជួបសំណេះសំណាលជាមួយ ប៉ុល ពត។ អ៊ីចឹងខ្ញុំចង់ដឹងថា តើឯកសារដែលយើងមាននៅក្នុងសំណុំរឿងនេះ អាចធ្វើឲ្យលោកនឹកឃើញដែរឬទេ ទៅដល់អំពីព័ត៌មានដែលលោកបាន

ទទួល តាមរយៈទូរលេខទាំងអស់នេះ? ខ្ញុំនឹងចាប់អារម្មណ៍លើរយៈកាល មុនពេលលោកមកដល់ស្វាយរៀង គឺនៅខែមេសា, ឧសភា ឆ្នាំ១៩៧៨។ ឯកសារទី១ ដែលខ្ញុំចង់បង្ហាញគឺឯកសារ E3/946, ERN ជាភាសាបារាំងគឺ 00332727, ជាភាសាអង់គ្លេសគឺ 00185205, ជាភាសាខ្មែរគឺ 00021015។ ជាបឋមខ្ញុំចង់ដឹងថា តើលោកនៅចាំនៅក្នុងក្របខ័ណ្ឌនៃព័ត៌មានដែលលោកបានទទួល ថាតើលោកនៅចាំអំពីការវាយប្រហារ ឬក៏ការប្រយុទ្ធគ្នានៅព្រៃទន្លេដែរឬទេ?

[១៥:៣០:០៣]

**ឆ៖** ខ្ញុំអត់ស្ដាប់បានទេ ព្រៃទន្លេណា អត់ស្គាល់ឈ្មោះផង ព្រៃទន្លេ អត់ដែលមាន។

**លោក គង់ សំអុន៖**

បាទ សូមបញ្ជាក់គឺ ព្រះទន្លេ។

**លោក ជួន ធី៖**

**ឆ៖** ព្រះទន្លេក៏អត់មាន សមរភូមិខ្ញុំអត់មានឈ្មោះព្រះទន្លេ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សំណួរខ្ញុំវាខុសពីហ្នឹង។ ខ្ញុំមិនសួរលោកថាលោកធ្លាប់បានប្រយុទ្ធនៅព្រះទន្លេទេ តែខ្ញុំចង់សួរលោកថា មុននឹងពេលទៅដល់ស្វាយរៀងហ្នឹង គេមានបាននិយាយអំពីព្រះទន្លេហ្នឹង ប្រាប់លោកដែរឬទេ? សមរភូមិព្រះទន្លេនេះ អ៊ីចឹងដើម្បីឲ្យគ្រប់ជ្រុងជ្រោយ ខ្ញុំសូមអានសម្រង់មួយនៃសារទូរលេខដែលគេផ្ញើជូនទៅ នៅថ្ងៃទី២៦ មេសា ឆ្នាំ១៩៧៨ ផ្ញើទៅ អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវន, មន្ទីរ និងឯកសារ។ នៅកថាខណ្ឌទី១ មាននិយាយដូចតទៅនេះ៖ "សភាពការណ៍ដូចដែលខ្ញុំបានរាយការណ៍ជូនបងពីព្រឹកមិញថែមត្រង់ខ្នាំងព្រះទន្លេមែន។ វាបុកមួយឆាប់ឡើងត្រង់ស្ពានធ្លក តម្រង់ផ្ទះអក្សរ-ស ហើយឆាបទៅរកព្រះព្រំដែនតាមកក់វិញ តែទៅដល់ខាងជើងកក់នោះ វាជាប់នឹងប្រឡាយ។"

[១៥:៣១:៥៣]

ខ្ញុំបន្តទៅចំណុចទី៣៖ "វាខំបុកពីមុខ ដើម្បីមកជួយ តែយើងវាយងាប់ច្រើនទៀត ហើយមកមិនរួចដែរ។ មានរថក្រោះ១៨គ្រឿងទៀតមកបុកមុខសញ្ញា មិត្តម៉ុន <ផ្លោះ>ទៅខាងជើង<ទៅ>រកតាអី។ ពួក<នៅសល់>ចង់<ចូល>មកតាមគគីសោម មកស្រោចស្រង់ពួកអានៅ<ជាប់>ខាងជើងកក់"។ កថាខណ្ឌទី៥៖ "ប្រជាជនត្រូវរបួស និងពលីមួយចំនួនដែរនៅព្រះទន្លេ ពេលដែលវាវាយឆាប់ -- វាវាយឆាប (សូមទោស)។ យើងមានវិធានការទៅសង្គ្រោះហើយ។" សូមបញ្ចប់ការដកស្រង់។

អ៊ីចឹងសំណួរខ្ញុំចង់ដឹងថា នេះជារបាយការណ៍រៀបរាប់អំពីការវាយប្រហារ ដែលកើតមានឡើងនៅព្រះទន្លេ។ តើលោកមាននៅចាំថា គេមានបាននិយាយអំពីការវាយប្រហារនេះនៅខែមេសា ឆ្នាំ ១៩៧៨ នៅពេលដែលលោកអានរបាយការណ៍ទាក់ទងនឹងភូមិភាគបូព៌ា ដែលគេនឹងបញ្ជូនលោកទៅទីនោះៗ លោកមាននៅចាំទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ចំពោះសមរភូមិដែលបញ្ជាក់អំមិញ គឺខ្ញុំអត់ដែលឮដំណឹងប្រាប់ ឬក៏ហើយក៏មិនស្គាល់ទៀតផង នៅខាងអី ដែលបឹងទន្លេ បឹងអីឯណា គឺខ្ញុំអត់មានទេ គឺអត់មានស្គាល់ហើយក៏អត់បានដឹងឮទៀត ហើយក៏គ្មានតិណែនាំអីបានទទួលដែរ អត់។

[១៥:៣៤:០១]

**ស៖** ឥឡូវខ្ញុំមានឯកសារមួយទៀត ដើម្បីពិគ្រោះជាមួយលោក ដើម្បីឱ្យដឹងថាលោកដឹងពីទីតាំងកន្លែងផ្សេងទៀតដែរទេ លោកនឹកឃើញដែរឬទេ ទោះបីតាមរយៈព័ត៌មានដែលគេបានផ្ដល់ទៅឱ្យលោកមុន<ពេលលោកទៅដល់នៅ>ខែ<មិថុនា> ឆ្នាំ១៩៧៨ ហើយនិងកន្លែង ឬក៏ទីតាំងផ្សេងទៀតដែលលោកធ្លាប់បានធ្វើការប្រយុទ្ធ <ដែលលោកបានទទួលព័ត៌មាន ពេលដែលលោកមានតួនាទី>ស្វាយរៀង។ គឺឯកសារ E3/862 គឺជាកម្លាំង វាយការណ៍ពីសភាពការណ៍គ្រប់ផ្នែក និងក្នុងតំបន់ភ្ជោះទាំងមូលនៅ<សប្ដាហ៍ទី១ ខែឧសភា> ឆ្នាំ១៩៧៨។ ERN ជាភាសាបារាំងគឺ <00814597>, ERN ជាភាសាខ្មែរគឺ <00021019>, ERN ជាភាសាអង់គ្លេសគឺ 00185207។ លេខ១ នៅក្នុងរបាយការណ៍នេះ សរសេរដូចតទៅនេះ៖ “សភាពការណ៍ការពារប្រទេស។ ខ្មាំងមកពីខាងក្រៅ នៅតំបន់២៤ យើងបានបោសសម្អាតពួកខ្មាំងយួនលេបទឹកដី មិនឱ្យវានៅតាមព្រំប្រទល់បានទេ ហើយយើងវាយរុញច្រានវាជាប់ជានិច្ច។ ខ្មាំងត្រូវដកថយ ឆ្ងាយពីព្រំដែនហើយ។ នៅតំបន់២៣ ខ្មាំងយួនដែលចូលឈ្លានពានក្នុងទឹកដីយើង តាំងពីថ្ងៃទី២៦ ខែ៤ <១៩៧៨>នោះមកនោះ ត្រូវបានធ្លាក់ទៅក្នុងការហ៊ុមព័ទ្ធរបស់យើង។ ខ្មាំងត្រូវរួញក្ដោបទៅបីកន្លែង គឺ<ទី១>នៅខាងកើត គឺវត្តបុសឃ្លាំង ឃុំ<បុសមន> ស្រុកសំរោង, <ទី២>នៅម្ដុំកក់ ឃុំស្វាយរំពារ ស្រុកប្រសូត្រ ហើយនិង<ទី៣>នៅភូមិតានី ឃុំបន្ទាយក្រាំង ស្រុកកំពង់រោទិ៍។ សកម្មភាពរបស់ខ្មាំង រថក្រោះរបស់វា ចល័តចុះឡើងត្រង់ព្រំប្រទល់ភូមិវាលស្រុកសំរោង។ វាបាញ់ផ្លោងកាណុងធុនធំ នៅលើឃុំជ្រុងពពេល ឃុំចក និងឃុំសង្កែ ជាច្រើនគ្រាប់។ នៅក្នុងស្រុកកំពង់រោទិ៍ វាបាញ់រះ ហើយនិងវាផ្លោងទៅលើប្រជាជនដែលកំពុងច្រូតកាត់ប្រមូលផលស្រូវជាបន្តបន្ទាប់។” សូមបញ្ចប់ការដកស្រង់។

[១៥:៣៦:៥៣]

អ៊ីចឹងខ្ញុំសួរលោកថា តើការដែលខ្ញុំអានរបាយការណ៍អំពីសភាពការណ៍ខែឧសភា ឆ្នាំ១៩៧៨នេះ វាធ្វើឱ្យ<លោកនឹកឃើញឡើងវិញនូវរឿងរ៉ាវដែលគេបានប្រាប់លោក មុនពេលលោកទៅដល់នៅខែមិថុនា ឆ្នាំ១៩៧៨ នោះទេ? ហើយតើទីតាំងផ្សេងៗដែលខ្ញុំបានលើកឡើងនោក្នុងសំណួរនេះ> -- ប្រហែលជាមេធាវី គង់ សំអុន គាត់នឹងអានឈ្មោះហ្នឹង ជាភាសាខ្មែរឱ្យលោកស្ដាប់ម្ដងទៀត។ អ៊ីចឹងខ្ញុំចង់សួរថា អ្វីដែលខ្ញុំអាន ស្ដាប់ទាំងប៉ុន្មាន ទីតាំងប៉ុន្មាននេះ លោកមានទទួលព័ត៌មានណា ទាក់ទងនឹងទីតាំងសមរភូមិទាំងអស់នេះដែរឬទេ ឬក៏នៅក្នុងក្របខ័ណ្ឌនៃការចូលទៅសមរភូមិនៅខេត្តស្វាយរៀងនោះ លោកស្គាល់ទីតាំងទាំងអស់នេះដែរ?

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់ពីទីតាំង ទី១ គឺនៅម្ដុំខាងកើតវត្តបុសផ្លាំង ឃុំបុសមន ស្រុកសំរោង។ ទី២ នៅម្ដុំកក់ ឃុំស្វាយរំពារ ស្រុកប្រសូត្រ, ទី៣ នៅភូមិតានី ឃុំបន្ទាយក្រាំង ស្រុកកំពង់រោទិ៍។ បាទ អ៊ីចឹងក្នុងការអំណានរបស់អ្នកបកប្រែអំមិញ គឺមានកំហុសឆ្គងនៅផ្នែកទី១ គឺវត្តបុសផ្លាំង ឃុំបុសមន ស្រុកសំរោង។ សូមអរគុណ។

**លោក ជួន ធី៖**

**ធ៖** ខ្ញុំសូមឆ្លើយ ចំពោះសមរភូមិដែលទីតាំងដែលបញ្ជាក់អំមិញនេះ គឺតាំងពីមុន តាំងពីខែសីហា ដូច្នេះខ្ញុំមិនទាន់បានទៅដល់នុ៎ងផង ខ្ញុំមិនទាន់បានចេញពីខាងខ្ញុំទៅផង។ ដូច្នេះខ្ញុំទៅដល់ស្វាយរៀង ដូចខ្ញុំបញ្ជាក់លើកមុនអ៊ីចឹង ថាខ្ញុំទៅដល់នោះ គឺឃើញខ្មាំងយួន គេវៃដកថយអស់ហើយ។ ខ្ញុំទៅឃើញតែកន្លែងខ្មោចខ្មីទេ។ ដូច្នេះខ្ញុំទៅអត់ទាន់ ហើយក៏ក្ដាប់សមរភូមិអត់បានដែរ ព្រោះខ្ញុំទៅក្រោយ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំមិនដឹងថា មានបញ្ហាបកប្រែ ឬក៏យ៉ាងម៉េចទេ។ <ប៉ុន្តែ>ឯកសារដែលខ្ញុំបានដកស្រង់អម្បាញ់មិញនោះ គឺនិយាយពីខែឧសភា ឆ្នាំ១៩៧៨។ ខ្ញុំជ្រើសរើសយករយៈកាលហ្នឹង ដោយសារវាជិតដល់ពេលលោកដែលលោកទៅស្វាយរៀង។ តាមរយៈចម្លើយរបស់លោកអម្បាញ់មិញនេះ លោកថា ទីតាំងទាំងអស់ហ្នឹង លោកចាំថាមាន -- លោកនិយាយអម្បាញ់មិញហ្នឹង គឺថាទីតាំងដែលខ្ញុំបានអានរៀបរាប់អម្បាញ់មិញហ្នឹង គឺគេបានពង្រាយកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យទៅទីតាំងទាំងអស់ហ្នឹង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែរ។ តើខ្ញុំយល់ហ្នឹងត្រឹមត្រូវទេ?

[១៥:៣៩:៣៦]

**ឆ៖** គឺពេលនុ៎ងគេបានវ៉ៃជ្រុញ រុញទៅកើតអស់ហើយ ខ្ញុំដែលនិយាយថា មានកម្លាំងផ្សេង គេមុន គេនៅនុ៎ងដែរ គ្រាន់តែខ្ញុំទៅបន្ថែម។ ដូច្នេះវា ដូចលោកនិយាយហ្នឹង អត់ខុសទេ គឺត្រូវហើយ។

**ស៖** សូមអរគុណ។ ហើយព័ត៌មានដែលថា ពួកទាំងអស់ហ្នឹង<ត្រូវ>បាន<វាយរុញច្រានចេញពីទីនោះ> តើព័ត៌មានហ្នឹងលោកទទួលបាននៅមុនពេលលោកទៅឈរជើងនៅស្វាយរៀង ឬក៏ទៅដល់នុ៎ងហើយបានទទួលបានព័ត៌មានហ្នឹង?

**ឆ៖**ដែលខ្ញុំទទួលបានផែនការត្រង់ថា ទី១ យួនចូលមកវ៉ៃដល់ស្វាយរៀង តែគេវ៉ៃបកទៅវិញអស់ហើយ ដូច្នេះបានយកខ្ញុំពីក្រោយ មកដាក់បន្ថែមកម្លាំងនៅកន្លែងហ្នឹងទៀត អ៊ីចេះ។ ខ្ញុំចង់និយាយអ៊ីចឹងបញ្ជាក់អ៊ីចឹង។ ហើយដកទៅប៉ូព៉ាឯណាឯណី ហ្នឹងខ្ញុំភ្លាប់អត់បានដែរ ដឹងដកត្រង់ណា ឬគ្រាន់តែ--។

**ស៖** សូមសួរបញ្ជាក់មួយទាក់ទងនឹងចំណុចហ្នឹង យើងកំពុងនិយាយពីព្រឹត្តិការណ៍ នៅខែឧសភា ឆ្នាំ១៩៧៨ ដែលយើងបានរុញច្រានកងទ័ពវៀតណាមទៅ<>វិញ<តាមព័ត៌មានដែលលោកទទួលបាន>។ តើគេមានបាននិយាយប្រាប់លោកថា មានការវាយលុករបស់វៀតណាមមកលើប្រទេសខ្មែរមុនឆ្នាំ១៩៧៨ដែរឬទេ គឺសំដៅនៅក្នុងអំឡុងឆ្នាំ១៩៧៧? តើលោកមានបានទទួលព័ត៌មានបែបហ្នឹងទេ?

[១៥:៤១:២៩]

**ឆ៖** ខ្ញុំអត់មានដែលបានទទួលព័ត៌មានហ្នឹងទេ អត់ដែលបានទទួល។

**ស៖** អម្បាញ់មិញខ្ញុំបានអានចម្លើយរបស់លោក ចម្លើយទី១៥ នៅក្នុងចម្លើយរបស់លោកគឺឯកសារ E3/4593 ដែលមានសរសេរ -- ដែលមានលើកឡើងពីឈ្មោះ<មេបញ្ជាការ>កងពលមួយចំនួន ដែលលោកបាននិយាយថា លោកបានស្តាប់ឮគេហៅឈ្មោះពួកគាត់។ អ៊ីចឹងសំណួរខ្ញុំចង់សួរថា នៅពេលដែលលោកទៅស្វាយរៀងនោះ តើលោកមានបានទទួលព័ត៌មានទាក់ទងទៅនឹងកងពល២២១ កងពលតូច២២១ដែរឬទេ? តើលោកមានដឹងថា កងពលនេះឈរជើងនៅកន្លែងណាដែរឬទេ? ហើយសភាពការណ៍នៃការទប់នៅតាមព្រំដែនដែលគេមានតួនាទីគេខាងការពារកន្លែងមុខសញ្ញារបស់គេហ្នឹង តើស្ថានការណ៍ហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ត្រង់ថា សភាពការណ៍ និងមុខសញ្ញាមួយៗ មុខសញ្ញា ឬក៏អង្គភាពមុខ

សញ្ញាមួយៗ ដូច្នេះខ្ញុំក្តាប់មុខសញ្ញាខ្ញុំបាន ប៉ុន្តែដល់ក្តាប់មុខសញ្ញាអង្គភាពដទៃ គឺស្តាប់អត់បានទេ។ ហើយឈ្មោះអង្គភាពផ្សេងៗដែលខ្ញុំបញ្ជាក់ខាងដើមហ្នឹង ដែលបញ្ជូនទៅ ខ្ញុំបញ្ជាក់ថែមថា នេះជាអង្គភាពផ្សេង មកពីភាគផ្សេង ហើយដឹកនាំផ្សេង គ្រាន់តែឮតែឈ្មោះ ហើយក៏មិនដែលឃើញអ្នកដឹកនាំនោះយ៉ាងម៉េច អីយ៉ាងម៉េច ក៏ខ្ញុំមិនដែលឃើញ គ្រាន់តែឮឈ្មោះ គេថា អ៎! អង្គភាពនេះ ឈ្មោះនេះ ឈ្មោះនេះដឹកនាំអ៊ីចឹង គ្រាន់តែដឹងតែប៉ុណ្ណឹង ហើយដឹងឈ្មោះដែរ អត់ដែលឃើញមុខទេ។ ហើយឮតែគេថា ជួបក៏មិនស្គាល់ដែរ។ ហើយឯបញ្ហាសហការគ្នា ក៏អត់មានអីសហការផង។ ដូច្នេះដូចខ្ញុំបញ្ជាក់ខាងដើម អ៊ីចឹងគឺម្នាក់ៗគឺទប់ ទប់គឺទប់មួយខ្លួនឯង ទុកមុខសញ្ញាខ្លួនឯងឲ្យតែនឹងទៅ ឲ្យតែទប់បានឲ្យៗទៅជួយគេ គឺអត់ទេ គឺកម្លាំងមាន។ គឺសូមបញ្ជាក់បន្ថែមមានប៉ុណ្ណឹង។

[១៥:៤៤:០២]

**សៈ** អ៊ីចឹងគឺបានន័យថា លោកមិនមានការសម្របសម្រួល ប្រតិបត្តិការសឹកជាមួយគ្នាទេ គឺដោយមិនមានសារាចរ ការផ្តល់ព័ត៌មានរវាងអង្គភាពមួយទៅអង្គភាពមួយទេ ឬក៏យ៉ាងម៉េច?

**ឆៈ** អត់ៗទេគឺអាហ្នឹងគឺធ្វើការ កាលហ្នឹងបើនៅជាអ៊ីចឹង គឺឯករាជ្យ ម្ចាស់ការរៀងខ្លួន។ ព្រោះបើ កាលណាបើខ្មាំងខ្លាំង វ៉ៃខ្លាំង យើងមានអី មានតែកម្លាំងយកទៅទប់ខ្លាំង ទប់តិចតួច កម្លាំងខ្មាំងវ៉ៃខ្លាំង យើងថយអ៊ីចឹងទៅ។ អាហ្នឹងគឺប្រើរូបភាពហ្នឹង។

**សៈ** លោកបាននិយាយថា មុនពេលទៅដល់ស្វាយរៀងហ្នឹង គឺលោកធ្វើការស៊ីវិលទេ ខាងកសិកម្ម ហើយនិងសំណង់។ នៅពេលដែលគេសួរចម្លើយរបស់លោកនៅថ្ងៃទី<២៤> មេសា ឆ្នាំ២០១៣ នៅក្នុងសំណុំរឿង០០២/០១ ឯកសារ E1/183.1។ លោកបានឆ្លើយដូចតទៅនេះ កាលនោះគេនិយាយអំពីបេសកកម្មរបស់លោក--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សុំលោកស្រីបង្ហាញអំពីឈ្មោះឯកសារផង ដើម្បីឲ្យអ្នកបកប្រែងាយស្រួល។

**កញ្ញា អង់តា ហ្គីសសេ៖**

គឺកំណត់ត្រាប្រតិចារឹក នៅថ្ងៃទី<២៤> ខែមេសា ឆ្នាំ២០១៣ ឯកសារ E1/183.1 គឺនៅម៉ោង <១៥:៥២:៤២>វិនាទី។

[១៥:៤៦:០៦]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

01376841



**សៈ** ពេលនោះលោកសាក្សីនិយាយអំពីថា ៣ឆ្នាំក្រោយ<ពេល>រំសាយ <លោកបាន>កាន់អាវុធវិញ។ លោកនិយាយថា៖ “ក្រោយពីសង្គ្រាមហ្នឹង គេដកយកអាវុធទៅដាក់ឃ្លាំងអស់ហើយ ៗគេឲ្យយើងទៅធ្វើស្រែចម្ការ។ ពេលវៀតណាមប្រកាសសង្គ្រាម ហើយមកឈ្លានពាន ទាហានទាំងអស់នុ៎ង<ត្រូវបានគេកែនប្រមូលឡើងវិញ>។ អ៊ីចឹងហើយស៊ីពេលច្រើនដើម្បីកែនទាហានមកប្រមូលផ្តុំទាហានវិញ ហើយវាហួសពេលបាត់ទៅហើយ។ ហើយនៅពេលដែលត្រៀមលក្ខណៈរួចហើយហ្នឹង វៀតណាមចូលមកដល់ទឹកដីខ្មែរបាត់ទៅហើយ។” សូមបញ្ចប់ការដកស្រង់។

អ៊ីចឹងខ្ញុំចង់ដឹងថា នៅក្នុងអំឡុងរយៈពេល៣ឆ្នាំដែលលោកត្រូវបានគេរំសាយចេញពីកងទ័ពនេះ តើក្នុងអំឡុងពេលហ្នឹង តើលោកមានបានទទួលព័ត៌មានដែលថា កម្ពុជាប្រជាធិបតេយ្យចង់វាយប្រហារវៀតណាមដែរឬទេ? ហើយដែលលោកនោះ លោកត្រូវបានគេប្រមូលកែនចូលទៅវិញដើម្បីទៅវ៉ៃវៀត-ណាមវិញ។ លោកមានបានទទួលព័ត៌មានហ្នឹងទេ?

**លោក ជួន ធី៖**

**ធៈ** ខ្ញុំសូមបញ្ជាក់ ចំពោះបញ្ហាអំមិញនេះ គឺលោកបញ្ជាក់អំមិញគឺថា ពេលនោះគឺពេលចប់សង្គ្រាម គឺនាំគ្នាមួយផ្នែក កងទ័ពមួយផ្នែក ដាក់កាំភ្លើងធ្វើកសិកម្មដើម្បីចិញ្ចឹមខ្លួនឯង។ ហើយមួយផ្នែកទៀត ក៏មិនដាក់កាំភ្លើងដែរ នៅការពារព្រៃ ការពារព្រំដែនអីខ្លះ មិនដាក់ទាំងអស់ទេ។ តែដូច្នេះដល់ពេល ដល់អ៊ីចឹងដល់ពេលយួនបុក ដូចអង្គភាពខ្ញុំអ៊ីចឹង គឺនៅការពារនៅតាមនេះអ៊ីចឹង។ ដូច្នេះពេលដែលមានសភាពការណ៍អ៊ីចឹងមក ខ្ញុំអាចប្រមូលកម្លាំងខ្ញុំបានរហ័សដែរ មកទប់ទល់ជាមួយយួនខាងកើតនោះ ព្រំដែនខាងកើតនោះ។ នេះខ្ញុំបញ្ជាក់ជូនអ៊ីចឹង។ មិនរំសាយទាំងអស់ទេ រំសាយខ្លះ។

[១៥:៤៨:២៥]

**សៈ** ខ្ញុំយល់ហើយថា រំសាយតែខ្លះទេ ក៏ប៉ុន្តែសំណួរ<របស់>ខ្ញុំ <ខ្ញុំ>ចង់ដឹងថានៅពេលដែលលោកធ្វើការខាងស៊ីវិលនេះ តើលោកមានបានទទួលព័ត៌មានដែលថា ផែនការរបស់កម្ពុជាប្រជាធិប-តេយ្យក្នុងការវាយប្រហារវៀតណាមហ្នឹងដែរឬទេ? ឬក៏លោក<ទើបតែចូលអន្តរាគមន៍ដោយសារលោកត្រូវបានគេវាយប្រហារ>?

**ធៈ** នៅៗពេលនោះគឺខាងអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យគឺអត់មានទិសដៅ និងគោលការណ៍ទៅវ៉ៃយួនទេ។ តែដូចខ្ញុំបញ្ជាក់ខាងដើម តែបើយួនចូលមកឈ្លានពានគឺវ៉ៃ។ តែពេលនោះយើងឃើញថាអត់ឈ្នះគេ ដូចបញ្ជាក់ខាងដើមអ៊ីចឹង ៥០លាន ហើយនិង៧, ៨លានឈ្នះ ម៉េចកេ? គេវ៉ៃរត់រប៉ាត់រប៉ាយ

ទាំងគេទាំងខ្ញុំ គឺបែកព្រាត់ប្រាសគ្នាអស់ទៅ គេមកនោះ។ ហ្នឹងដូច្នេះវាអត់ឈ្នះគេទេ ព្រោះគ្រាន់តែទប់ទល់កុំឱ្យថា គេចូលមកផ្ទះយើងហើយ មកសម្លែងយើងហើយ យើងឱ្យគេចូល អត់មានការទប់ទល់ ការពារហ្នឹង អាហ្នឹងដូចជាអន់ពេក។

**ស៖** រួបលោកផ្ទាល់ តើលោករត់នៅពេលណាដែរ នៅពេលដែលវៀតណាមចូលវាយលុកចូលប្រទេសកម្ពុជាហ្នឹង? តើលោកនៅចាំកាលបរិច្ឆេទទេ? លោករត់ពេលណាដែរ?

**ឆ៖** រត់នោះ ខ្ញុំរត់ហ្នឹងក្នុង ខ្ញុំសូមបញ្ជាក់រត់ហ្នឹង អំឡុងចិត ៗចុង៧៨ហ្នឹង គឺពេលហ្នឹងយួនដែលបុកខ្លាំងមក គឺទប់មានបានឯណា គឺចូលពេញទឹក ពេញដីហើយ នាំគ្នាដកចេញ រត់របើករយាងនៅពេលនុំងហើយ។ តែងថ្ងៃខែហ្នឹង គឺចាំអត់ច្បាស់លាស់ ដឹងតែចុង៧៨។ ចុង៧៨ ដើម៧៩ហ្នឹងគឺរត់ហើយ គឺចាញ់យួនហើយ ខ្មែរគឺចាញ់យួនហើយ យួនចូលពេញប្រទេសហើយ។

[១៥:៥០:៤៧]

**ស៖** នៅក្នុងចម្លើយរបស់លោកគឺឯកសារ E3/4593 នៅចម្លើយលេខទី២០ សំណួរចុងក្រោយគេដែលសហចៅក្រមស៊ើបអង្កេតបានសួរទៅលោកហ្នឹង គឺសំណួរដូចតទៅនេះ៖ "តើលោកមានសំណូមពរបែបណា ចំពោះការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម? លោកឆ្លើយដូចតទៅនេះ៖ ខ្ញុំមិនមានសំណូមពរបែបណាទេ ព្រោះខ្ញុំមិនមានចំណាប់អារម្មណ៍។ រឿងនេះវាមានការពាក់ព័ន្ធច្រើន បើឱ្យខ្ញុំពន្យល់ហ្នឹង ខ្ញុំត្រូវនិយាយតាំងពីដើមដល់ចប់ ហើយមិនមែនត្រឹមតែជំនាន់ខ្មែរក្រហមកាន់អំណាចនោះទេ។" តើលោកចង់និយាយយ៉ាងម៉េចដែរ នៅពេលដែលលោកនិយាយថា រឿងនេះវាពាក់ព័ន្ធច្រើន លោកចង់បានន័យថាយ៉ាងម៉េច?

**ឆ៖** ខ្ញុំសូមបញ្ជាក់ រឿងនេះដែលខ្ញុំមិននិយាយ អស់លោកទៅនិយាយថា ឱ្យខ្ញុំនិយាយតែក្នុងចន្លោះ៧៥ មក៧៩។ ដូច្នេះខ្ញុំនិយាយ ដូច្នេះខ្ញុំថាបើនិយាយចន្លោះពេលហ្នឹង គឺពិបាកនិយាយដែរ ព្រោះសង្គ្រាមនេះ ដែលចេះតែកើតឡើងតាំងពីឆ្នាំ៧៥។ នេះខ្ញុំគ្រាន់តែបញ្ជាក់អ៊ីចឹង។ ដូច្នេះនិយាយទៅចេះតែមានពាក់ព័ន្ធ និយាយចេះថាពាក់ព័ន្ធអី ពាក់ព័ន្ធនឹងរឿងការងារ និងពេលវេលាយូរហ្នឹងហើយ ដូច្នេះមានអីទេ។ ដូច្នេះគ្រាន់តែខ្ញុំបញ្ជាក់ថែម បញ្ជាក់ជូនប៉ុណ្ណឹង។

**ស៖** ឥឡូវនេះខ្ញុំសូមចូលទៅនិយាយអំពីចំណុចចុងក្រោយមួយ នៃការផ្តល់សក្ខីកម្មរបស់លោក គឺប្រធានបទនៃការរៀបការដែលលោកបាននិយាយចំពោះមុខសហចៅក្រមស៊ើបអង្កេត។ មុននឹងចោទសំណួរទូទៅទៅលោក ខ្ញុំសូមឱ្យលោកបញ្ជាក់ជូនតុលាការ ថាតើលោករៀបការនៅពេលណាដែរ?

ហើយរៀបការហ្នឹងនៅកន្លែងណាដែរ?

[១៥:៥៣:០៦]

**ឆ៖** ខ្ញុំរៀបការនៅឆ្នាំ១៩៧៩ នៅលង្វែក នៅបន្ទាយលង្វែក ខេត្តកំពង់ឆ្នាំង។

**ស៖** ខ្ញុំឮតាមរយៈការបកប្រែថា លោករៀបការនៅឆ្នាំ១៩៧៩។ អ៊ីចឹងខ្ញុំសួរលោកថាតើក្រោយរបបកម្ពុជាប្រជាធិបតេយ្យរលត់ផុតទៅហើយ ឬក៏យ៉ាងម៉េច? ព្រោះថាអម្បាញ់មិញនេះ ការបកប្រែហ្នឹងទាក់ទងនឹងទីតាំងហ្នឹង គាត់ស្ដាប់អត់ទាន់ទេ អ្នកបកប្រែអម្បាញ់មិញហ្នឹង។

**ឆ៖** ខ្ញុំសូមបញ្ជាក់ថែម អ្នកដែលទៅសួរខ្ញុំហ្នឹង ខ្ញុំថា ខ្ញុំការឆ្នាំ១៩៧៦ តែគ្រាន់ថាការនៅកន្លែងណា នៅកន្លែងណា អាហ្នឹងគាត់ក៏អត់សួរខ្ញុំដែរ។ តែពេលនេះ ខ្ញុំបញ្ជាក់ទីកន្លែងហ្នឹងទៀត ព្រោះលោកសួរខ្ញុំថា នៅកន្លែងណា? ខ្ញុំប្រាប់ថា នៅបន្ទាយលង្វែក។ ហើយ៧៦ទេ មិនមែន៧៩ទេ។ ៧៩ណា បើរត់យួនហើយហ្នឹង ចាញ់ ច្បាំងចាញ់យួនហើយហ្នឹង មានពេលណាការ។

**ស៖** អ៊ីចឹងគឺលោករៀបការនៅឆ្នាំ១៩៧៦ តើលោកអាចជម្រាបជូនបានដែរឬទេ អង្កាល់នុ៎ង លោករៀបការនៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំជម្រាបហើយថា ការនៅលង្វែក នៅបន្ទាយលង្វែក។

**ស៖** លង្វែកហ្នឹងជាកន្លែងដែលលោកឈរជើង មុនពេលដែលលោកទៅកាន់ការនៅស្វាយរៀង អ៊ីចឹងមែនទេ?

[១៥:៥៥:០៣]

**ឆ៖** លង្វែកហ្នឹងហើយ កន្លែងខ្ញុំឈរជើងនៅហ្នឹង អង្គភាពឈរជើងនៅហ្នឹង មុនដែលទៅស្វាយរៀងហើយ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានដែរឬទេថា ការរៀបការរបស់លោកហ្នឹង ប្រព្រឹត្តទៅយ៉ាងម៉េចដែរ? ដំណើរការការរៀបការហ្នឹង អ្នកណាអ្នកជ្រើសរើសប្រពន្ធរបស់លោក? ហើយគេរៀបចំពិធីហ្នឹងយ៉ាងម៉េចដែរ? ហើយតើលោកមានត្រូវសុំការអនុញ្ញាតដើម្បីរៀបការដែរឬទេ ពេលនុ៎ង?

**ឆ៖** ខ្ញុំសូមបញ្ជាក់។ ការរៀបការនៅពេលនោះ គឺខ្ញុំ និងគ្រួសារខ្ញុំដែលនៅជាប់រាល់ថ្ងៃហ្នឹង គឺមានការស្រឡាញ់គ្នាទៅវិញទៅមក អត់មានអ្នកណាចាប់បង្ខំទេ។ ការ គឺមេកង កាលនុ៎ងគឺមេកងពលដល់អ៊ីចឹង តាសឿង គាត់នៅនុ៎ង ដូច្នេះគាត់រៀបចំឱ្យអ៊ីចឹងទៅ ព្រោះយើងប្រាប់ថាយើងស្រឡាញ់ យើងស្នើ យើងប្រាប់ខាងលើថា ខ្ញុំចង់បានគ្រួសារឈ្មោះនេះ ឈ្មោះនោះ អ៊ីចឹងទៅ គឺឱ្យខាងលើរៀបចំឱ្យ។

គេរៀបចំឲ្យជាគូអ៊ីចឹងទៅ ហើយរៀបចំហើយ គេមានពិធីជប់លៀងអីខ្លះអ៊ីចឹងដែរ បាយទឹកអ៊ីចឹងទៅធម្មតា។ តែរបៀបចាប់ដៃទេ គ្មានម៉ែឪអីទៅទេ ប៉ុន្តែធ្វើក្នុងពិធីមានអ្នកទទួលដឹកនាំ ទទួលខុសត្រូវ។

**ស៖** លោកបាននិយាយថា លោកបានសុំទៅថ្នាក់លើ។ អ៊ីចឹងខ្ញុំសួរលោកថា តើថ្នាក់លើហ្នឹងថ្នាក់ណាដែរ អ្នកណាដែរ?

**ឆ៖** ថ្នាក់លើហ្នឹង កងពលខ្ញុំអ្នក ពេទ្យ សឿង ហ្នឹង។

**ស៖** ហើយប្រពន្ធរបស់លោក គាត់នៅក្នុងកងណាដែរ ឬក៏គាត់ហ្នឹងជាយោធាដូចលោកដែរ?

**ឆ៖** ប្រពន្ធខ្ញុំ ជាប្រជាជនធម្មតាហ្នឹង។

[១៥:៥៧:២៩]

**ស៖** នៅសវនាការថ្ងៃទី២៤ មេសា ឆ្នាំ២០១៣ ឯកសារ E1/183.1 ជាកំណត់ត្រាប្រតិចារឹក នៅមុនម៉ោង១០:០៣:៣០*សឹកុង*បន្តិច លោកបាននិយាយថា៖ “នៅក្នុងកងខ្លះហ្នឹង ប្រធានហ្នឹង គេត្រូវផ្ទៀងផ្ទាត់ថាត្រូវរៀបការអ្នកណា។ ហើយគេត្រូវ -- ក៏ប៉ុន្តែគេរៀបការ ត្រូវឲ្យមានការព្រមព្រៀងគ្នារវាងគូស្រករទាំងពីរហ្នឹង ហើយមិនមានការបង្ខិតបង្ខំអីទេ <ហើយយើងរៀបការដោយស្មគ្រចិត្ត>។” អ៊ីចឹងសំណួរខ្ញុំ ខ្ញុំសួរថា នៅក្នុងការរៀបការរបស់លោកដែលជាក់លាក់នេះ ដោយឡែកនេះ តើគេផ្ទៀងផ្ទាល់យ៉ាងម៉េចដែរលោក? គេផ្ទៀងផ្ទាត់ថា លោក និងប្រពន្ធលោកហ្នឹងព្រមព្រៀងគ្នា ស្រុះស្រួលគ្នាស្រឡាញ់គ្នាហ្នឹង តាមវិធីសាស្ត្រណាដែរ?

**ឆ៖** ខ្ញុំនិយាយអ៊ីចឹង ក៏ខ្ញុំពិបាកនិយាយប្រាប់ដែរ តែគ្រាន់តែខ្ញុំសូមបញ្ជាក់អ៊ីចេះ។ ដូច្នេះការទំនាក់ទំនងជាមួយគ្នារវាងយុវជន យុវនារីពេលនោះ ក៏មិនមានសភាពណាតឹងរ៉ឹងកំព្រឹសដែរ ដូច្នេះការជួបគ្នា ធ្វើការងារគ្នាបាន ដូច្នេះអាចប្រាស្រ័យទាក់ទងគ្នា រហូតដល់មានចងមេត្រីស្នេហានឹងគ្នាហ្នឹងទៅ ហើយស្នើទៅប្រាប់មេថា ខ្ញុំស្រឡាញ់នាងនោះ ហើយនាងនោះ ដោយស្នើទៅ គេយល់ព្រម អាហ្នឹងគេនេះទៅ មានអី អត់មានការបង្ខិតបង្ខំទេ។ ហ្នឹងគឺអ៊ីចឹងតើ ខ្ញុំសូមបញ្ជាក់ថែមប៉ុណ្ណឹង។

**ស៖** លោកបានឆ្លើយថា លោកបានស្នើទៅមេរបស់លោក។ តើប្រពន្ធលោកវិញនោះ គាត់ធ្វើយ៉ាងម៉េចដែរ<? តើ>គាត់បានស្នើទៅមេកងគាត់ ឬក៏មេអង្គភាពគាត់ដែរ<ឬទេ>?

**ឆ៖** ព្រោះដូចខ្ញុំបាននេះហើយ ខ្ញុំបានជួបទាក់ទងគ្នាពីមុនរួចហើយ ស្គាល់ចិត្តស្គាល់ថ្លើមគ្នា ហើយបានខ្ញុំស្នើទៅមេ។ ហើយនេះគេ អាហ្នឹងគ្រាន់ខ្ញុំបញ្ជាក់អ៊ីចឹង។ ហើយដល់មេ ដល់ស្នើទៅមេទៅ គេមេគេស្រាវជ្រាវទៅ ប្រាប់ថានៅកន្លែងណា អង្គភាពណា គេយកមករៀបចំឲ្យយើង។ ហ្នឹងអ៊ីចឹង។

[១៦:០០:០៥]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំមើលទៅម៉ោងបួនហើយ ប្រហែលជាសមល្មមនឹងសម្រាកហើយ ឬក៏យ៉ាងម៉េចលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទហើយសវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី២៦ ខែតុលា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក ហើយសវនាការនៅថ្ងៃស្អែកនេះអង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ជួន ធី បញ្ចប់ ហើយនិងអាចមានសាក្សីបម្រុង 2-TCW-1045 សូមភាគជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណ លោក ជួន ធី សវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោកស្រី សុក សុជាតា មេធាវីប្រឹក្សាសាក្សី អង្គជំនុំជម្រះក៏អញ្ជើញលោកស្រីមកបន្តប្រឹក្សាសាក្សីនេះ នៅថ្ងៃស្អែកទៀតដែរ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សី វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅ ហើយនិងឲ្យអញ្ជើញគាត់មកផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ហើយដែលនឹងចាប់ផ្ដើមពេលវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផនត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.កវិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*